# ហ្វាទីម៉ាស្ហ់ ម៉ាក្អ់ស៊ូម៉ាស្ហ់ سلام الله عليها

# ម្ចាស់ស្ត្រីរាជធានីគុម

និពន្ធដោយលោកស្រីបណ្ឌិត ម៉ាក្អ់ស៊ូម៉ាស្ហ់ យ៉្ជាហ្វ់ហ្វារ (Ma’suma Jaffer)

# បញ្ជីមាតិកា


១. ព្រះជីវប្រវត្តិរបស់ព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ........................ ១៣
១.១ ទំនាយកំណើតមហាស្ត្រីថ្លៃថ្លា........................................................ ១៣
១.២ កំណើតព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها........................................ ១៤
១.៣ ថ្ងៃខែព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ចូលទិវង្គត.................. ១៧
១.៤ ព្រះបិតា صلوات الله عليه والسلام ព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ។..................... ១៨
១.៥ ព្រះមាតា رضي الله عنها ព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ។........................ ២១
១.៦ នាមនិងបុណ្យស័ក្តិរបស់ព្រះនាងហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ។ ..... ២៣
១.៧ បារមីព្រះនាងហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ។.................................. ២៩
១.៨ មូលហេតុព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها មិនមាន ស្វាមី ....... ៣៧
១.៩ ព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها អ្នកតំណាល ហាឌីស្ទព្រះសាស្តា صلى الله عليه وآله وسلم............................................................................................. ៤០
១.១០ អានុភាពអ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام និងអ៊ីម៉ាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام លើព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها.................................................................. ៤៣
២. ដំណើរទៅគុម ............................................................................ ៤៨
២.១ ព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها បែកពី អ៊ីម៉ាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام..... ៤៨
២.២ ដំណើរព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ពី ម៉ាឌីណាស់........... ៤៩
២.៣ ដំណើរព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ពីស្រុក សាវេះប្ហ៍ទៅខេត្តគុម........................................................................................ ៥៤
២.៤ ព្រឹត្តិការណ៍នៅពេលបញ្ចុះព្រះរាជសពព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها................................................................... ៥៥
២.៥ សពឥស្សរជនឯទៀតបញ្ចុះនៅក្បែរព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ................................................................................ ៥៨
៣. ព្រះចេតិយព្រះនាង ហ្វាទ៏ីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها................................ ៦២

៣.១ ប្រវត្តិសង្ខេប ..................................................................................................៦២
៣.២ រជ្ជកាល ស្វ័ហ្វាវី ...............................................................................................៦២
៣.៣ រជ្ជកាល ក៏យ៉ារ (قاجار) ...................................................................................៦៤
៣.៤ ក្រោយបដិវត្តន៍អ៊ីស្លាមមានជ័យជំនះ .........................................................៦៥
៣.៥ ការសាងបន្ទប់បញ្ចុះព្រះរាជសព ................................................................៦៥
៣.៦ ព្រះបូជនីយចេតិយក្នុងបច្ចុប្បន្ន .....................................................................៦៩
៣.៧ ដោមមាស ........................................................................................................៧១
៣.៨ អក្សរចារឹកនៅក្នុងព្រះបូជនីយដ្ឋាន ...........................................................៧៤
៣.៩ អក្សរចារឹកនៅក្នុងដោម ..............................................................................៧៥
៣.១០ អក្សរចារឹកនៅពីលើព្រះរាជផ្នូរ ...............................................................៧៧
៣.១១ អព្ភូតហេតុអស្ចារ្យបានកើតឡើងនៅឯព្រះចេតិយ ....................................៧៩
១. ព្យាបាលដំបៅរលួយ .....................................................................................៨០
២. មូឡា ស្វាដ្រ៉ (ملا صدرا) សូមការណែនាំពីព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ...................................................................................................................៨១
៣. ដំណោះស្រាយបញ្ហារបស់ អាយ៉ាទុលឡោះហ៍ ណាយ៉ាហ្វី ដោយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ..........................................................៨២
៤. ព្រះបូជនីយរាជធានីគុម ...................................................................................៨៥
៤.១ អារម្ភកថា .........................................................................................................៨៥
៤.២ ប្រវត្តិខេត្តគុម ..................................................................................................៨៦
៤.៣ សិក្ខាសាលាទីក្រុងគុម .......................................................................................៨៨
៤.៤ កន្លែងឯទៀតនៅរាជធានីគុមដែលគួរចាប់អារម្មណ៍ ........................................៩២
៤.៥ ពាក្យពេចន៍ហ្ពាឌីស្វស៊ីអំពីបារមីរាជធានីគុម .....................................................៩៦
៥. ការទៅគោរពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها .............................១០០
៥.១ ផលបុណ្យនៃការទៅគោរពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها .. ១០០
៥.២ ពិធីធ្វើគារវៈកិច្ចព្រះបូជនីយដ្ឋាន .................................................................. ១០៣
៦. ស៊ីយ៉ារ៉េះត៍ (គារវៈកិច្ច) ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ........... ១០៥

បញ្ជីរាយឈ្មោះសៀវភៅស្តីអំពីប្រធានបទនេះ...................................... ១១៣

# អារម្ភកថា

សូមថ្វាយព្រះថោមនាការដល់អល់ឡោះហ៍ﷻ ដែលបានដឹកនាំអស់ទាំងយើងដោយព្រះធម៌សន្តោស ។

សូមអល់ឡោះហ៍ﷻព្រះរាជទានព្រះពរនិងព្រះសិរីសួស្តី ដល់ព្រះសាស្តាចុងក្រោយបង្អស់ ព្រះសាស្តាប្រសើរដាច់អស់ព្រះសាស្តាទាំងពួង មូហាំម៉ាដ៍ អាល់-មុស្ទត៍ហ្វាﷺ និងដល់ព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះអង្គﷺ ។

ចុងឆ្នាំ ២០០២ នាងខ្ញុំនិងក្រុមគ្រួសារមានកិត្តិយសបានទៅលេងទីក្រុងគុមនៃប្រទេសអ៊ីរ៉ង់ ។ ទៅដល់ភ្លាម នាងខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងដែលបានឃើញវត្តមានព្រះនាង ហ្វាទី៍ម៉ាស្ទ៍ ម៉ាក់ស៊្វម៉ាស្ទ៍سلام الله عليها (فاطمة المعصومة) ជះឥទ្ធិពលទៅលើប្រជារាស្ត្ររបស់ទីក្រុងនេះ ។

ភាសាពែរសង់ (ភាសាអ៊ីរ៉ង់) ពិបាករៀនណាស់ ។ ព្រោះតែចង់ស្គាល់ព្រះនាងពេក នាងខ្ញុំបានសច្ចារនឹងមហានារីរត្នអង្គនេះថា៖ "សូមព្រះនាងسلام الله عليهاសន្តោសខ្ញុំម្ចាស់ដោយអនុញ្ញាតឲ្យខ្ញុំម្ចាស់ចេះដឹងភាសានេះ ខ្ញុំម្ចាស់នឹងប្រើការចេះដឹងនេះដើម្បីសរសេរព្រះជីវប្រវត្តិរបស់ព្រះនាងسلام الله عليهاដំបូងបង្អស់ជាភាសាអង់គ្លេស ។"

កូនសៀវភៅតូចនេះជាលទ្ធផលនៃព្រះពរនិងសេចក្តីស្រឡាញ់ របស់មហាស្ត្រីថ្លៃថ្លាមកលើអស់ប្រជានិករនៃរាជធានីគុម ។

សូមថ្វាយព្រះថោមនាការដល់អល់ឡោះហ៍ﷻ ។ ការចងក្រងកូនសៀវភៅនេះបានចប់ក្នុងថ្ងៃបុណ្យខួបព្រះរាជបិតាصلوات الله عليه والسلامរបស់ព្រះនាងسلام الله عليها អ៊ីម៉ាំ មូសា អាល់-កាស្ទ៊ីមصلوات الله عليه والسلام ។

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណចំពោះអល់ឡោះហ្វ៍ عزّ وجلّ ដែលបានឲ្យនាងខ្ញុំបានស្នាក់នៅក្នុងទីក្រុងនេះ ៩ ខែ ។ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះបុត្រាបុត្រីនាងខ្ញុំដែរឈ្មោះ ស្វាហ្វ៊ីដ្ទ ហ្វាសាន់, ត្ហ៍ហ្វ៊ីរ៉ោះត្ហ៍ ម៉ាស្វ់ឌ្វីយ៉ាស្ទ់ និង មុច្ចតាបា ហ្វ៊ូសៃន៍ ដែលបានរៀបរៀងសៀវភៅនេះជាលាយលក្ខណ៍ដោយយកចិត្តទុកដាក់ ។

នាងខ្ញុំសូមអរគុណស្វាមីនាងខ្ញុំ អ៊ុប់បាស់ ដែលបានជួយផ្តល់កម្លាំងចិត្ត ជួយផ្តល់ការណែនាំ ជួយបោះពុម្ពនិងដែលមានអំណត់ ។

នាងខ្ញុំមិនភ្លេចគុណលោកគ្រូ អ៊ុក៉ា មូហ្ហាំម៉ាដ្ទ់ អ៊ុលី ស្វ៉ម៉ាលី (محمد على شمالى) ដែលបានជួយកែតម្រូវកូនសៀវភៅនេះនិងជួយផ្តល់គំនិត ។

នាងខ្ញុំចងក្រងកូនសៀវភៅនេះឡើង ក្នុងគោលបំណងផ្គាប់ព្រះរាជហឫទ័យអល់ឡោះហ្វ៍ عزّ وجلّ និងក្នុងឱកាសរំលឹកព្រះកិត្តិយសព្រះនាង ហ្វាទ្វីម៉ាស្ទ់ ម៉ាក់ស្វ៊ូម៉ាស្ទ់ سلام الله عليها និងព្រះបុព្វការី عليهم السلام របស់ព្រះនាង سلام الله عليها ព្រះរាជសាស្តាមូហ្ហាំម៉ាដ្ទ់ صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានបរិសុទ្ធ عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم ។

សូមអល់ឡោះហ្វ៍ عزّ وجلّ ទ្រង់សព្វព្រះរាជហឫទ័យនឹងការសាងផលបុណ្យនេះ !

ម៉ាក់ស្វ៊ូម៉ាស្ទ់ យ៉ាហ្វ់ហ្វារ (Ma'suma Jaffer)
ទីក្រុងគូម, ប្រទេសអ៊ីរ៉ង់
ថ្ងៃទី ៧ ស្វ៉ហ្វារ ឆ្នាំ ១៤២៤ សករាជហ៊ីច្ចរ៉ោះត្ហ៍
ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៣ ។

# សេចក្តីផ្តើម

ហ្វាទីម៉ាស្ញ់ ម៉ាក់ស្ហ៊ូម៉ាស្ញ់ سلام الله علیها (فاطمة المعصومة) ជាព្រះរាជបុត្រីរបស់អ៊ីម៉ាំទី ៧ មូសា អាល់-កាស៊ីម صلوات الله علیه والسلام ។ ព្រះនាង سلام الله علیها ជាព្រះរាជអនុជា (ប្អូនស្រី) របស់អ៊ីម៉ាំទី ៨ អាលី អាល់-រីដ្ហ៏ صلوات الله علیه والسلام ។ ព្រះនាងជាអភិនារីដែលបានបូជាជីវិតជូនព្រះសាសនាអ៊ីស្លាមនិងអល់ឡោះហ៊្វ عز وجل ។ ប្រកបដោយប្រាជ្ញាខ្ពស់ ដោយសារទទួលបាននូវការអប់រំពីព្រះបិតា صلوات الله علیه والسلام និងព្រះរៀម صلوات الله علیه والسلام ព្រះនាង سلام الله علیها ល្បីឈ្មោះនៅក្នុងសាសនាអ៊ីស្លាមជានារីប្រកបដោយការចេះដឹងនិងជានារីសទ្ធាធិមុត ។

ព្រះនាងមានព្រះជន្ម ៦ ព្រះវស្សាកាលព្រះបិតា صلوات الله علیه والسلام ព្រះនាងត្រូវ ហារូន (ស្តេចខ៊ុលិហ្វ ទី ៦) ចាប់ខ្លួន ។ បន្ទាប់ពីនោះព្រះនាង سلام الله علیها នៅក្នុងបន្ទុកព្រះរៀម صلوات الله علیه والسلام អ៊ីម៉ាំ រីដ្ហ៏ صلوات الله علیه والسلام ជាអាណាព្យាបាល ដែលចិញ្ចឹមបីបាច់ថែរក្សាព្រះនាង سلام الله علیها អស់រយៈពេលម្ភៃមួយឆ្នាំ ។

ឆ្នាំ ២០០ សករាជហ៊ីជ្រ៉ោះត៏ ម៉ាក់មូន ស្តេចខ៊ុលិហ្វទី ៧ ត្រកូល អាប់បាស់ បានបង្ខំអ៊ីម៉ាំ صلوات الله علیه والسلام ឲ្យភៀសខ្លួនពីម៉ាឌីណាស្ញ់ ទៅកាន់ដែនដីឃ៊ូរ៉សាននាប្រទេសអ៊ីរ៉ង់ ។ លើកនេះទៀត ព្រះនាងម៉ាក់ស្ហ៊ូម៉ាស្ញ់ سلام الله علیها ត្រូវឃ្លាតចាកពីអាណាព្យាបាល ។

ឆ្នាំ ២០១ សករាជហ៊ីជ្រ៉ោះត៏ ព្រះនាង سلام الله علیها បានសម្រេចចិត្តចាកចេញពីនគរម៉ាឌីណាស្ញ់ទៅកាន់ដែនដីឃ៊ូរ៉សាន ទៅរកព្រះរៀម صلوات الله علیه والسلام ។ អកុសល ព្រះនាង سلام الله علیها មិនបានទៅដល់ដែនដីនោះទេ ។

ក្បួនទូរចរនាំព្រះនាងធ្វើដំណើរត្រូវវាយឆ្មក់នៅឯស្រុក សាវ៉េះហ្វ៍ (ساوه) ។ ព្រះនាង سلام الله علیها បានឃើញសមាជិកគ្រួសារត្រូវកាប់សម្លាប់រង្គាល ។ ហេតុដូច្នេះ គេ

ប្រៀបធៀបព្រះនាងﷺនឹងព្រះនាង ស៊ែណាប់ﷺ ដែលធ្លាប់រងវាសនាមហាលំបាកដូចនេះដែរ ។

ហ្វាទីម៉ាស្វ ម៉ាក់ស៊្វម៉ាស្វﷺ ត្រូវគេធ្វើបាបនៅស្រុកសាវ៉េះហ្វ ។ ពួកស្ទីអាស្វអ្នកស្រុកជិតខាងរបស់ខេត្តគុមបាននាំព្រះនាងﷺពីស្រុកនេះ ទៅនៅឯស្រុកពួកគេ ។ ព្រះនាងﷺបានរស់នៅទីនេះច្រើនថ្ងៃមុនអស់ព្រះជន្មក្នុងខែ រ៉ាបីអ៊ុល-ស្សានី (رَبِيع اَلثَّانِي) ឆ្នាំ ២០១ សករាជហ៊ិជ្ជរ៉ោះត៍ ។



**សំយាបដាំបន្ទះបញ្ចក់នៃផ្លូវចូលទៅកាន់ព្រះបូជនីយចេតិយព្រះនាង ហ្វាទីម៉ាស្វ ម៉ាក់ស៊្វម៉ាស្វﷺ**

ព្រះរាជសពព្រះនាង ហ្វាទីម៉ាស្វ ម៉ាក់ស៊្វម៉ាស្វﷺ ត្រូវបានបញ្ចុះនៅឯខេត្តគុម

ប្រទេសអ៊ីរ៉ង់ ។ ដោយសារតែវត្តមានព្រះនាងسلام الله عليها ប្រកបដោយព្រះពរ ខេត្តនេះបានក្លាយទៅជាមជ្ឈមណ្ឌលនៃការសិក្សាស៊្វីអ៊ុស្មូមួយ ក្នុងបណ្ដាមជ្ឈមណ្ឌលស៊្វីអ៊ុស្មូដែលធំជាងគេក្នុងពិភពលោក ។ និស្សិតរាប់ពាន់នាក់មកពីប្រមានជាង ៨០ ប្រទេសសម្ដៅមុខព្រួញទៅរកមជ្ឈមណ្ឌលអ៊ីស្លាមនេះ ។

ជីវភាពរស់នៅមួយប៉ែកធំនៅឯទីក្រុងគុម វិលជុំវិញមហាគ្រឹះហ្សារ៉មព្រះនាងហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់سلام الله عليها ដែលជាចំណុចកណ្ដាលនៃទីក្រុងនេះ ។ រៀងរាល់ឆ្នាំ អ្នកធម្មយាត្រារាប់ពាន់នាក់មកពីគ្រប់ទិសដើម្បីសម្ដែងសេចក្ដីគោរពចំពោះមហាស្ត្រីថ្លៃថ្លាអង្គនេះ ។ យោលតាមពាក្យពេចន៍ដែលអាចទុកចិត្តបានរបស់អ៊ីម៉ាំបីអង្គعليهم السلام ព្រះអង្គعليهم السلام មានវចនៈដូចតទៅ ។

-អ៊ីម៉ាំទី ៦ យ៉ាក់ហ្វារ អាល់-ស៊្វឌិក្វصلوات الله عليه والسلام មានវចនៈថា៖

تُقْبَضُ فِيهَا اِمْرَأَةٌ مِنْ وُلْدِي، اِسْمُهَا فَاطِمَةُ بِنْتُ مُوسَى، وَ تُدْخَلُ بِشَفَاعَتِهَا شِيعَتِي اَلْجَنَّةَ بِأَجْمَعِهِمْ. (بحار الأنوار ج٥٧ ص٢٢٨ internet)

"មហាស្ត្រីមួយអង្គក្នុងបណ្ដាកូនចៅខ្ញុំصلوات الله عليه والسلام ឈ្មោះ ហ្វាទីម៉ាស់ រាជបុត្រីរបស់មូសាصلوات الله عليه والسلام នឹងអស់ជីវិតនៅឯគុម ។ ថ្ងៃជំនុំជម្រះ មហាស្ត្រីនេះនឹងធ្វើអន្តរាគមន៍ឲ្យស៊្វីអ៊ុស្មូទាំងអស់របស់ខ្ញុំصلوات الله عليه والسلام បានចូលឋានសួគ៌ ។" (بحار الأنوار 8: 228)[1]

-អ៊ីម៉ាំទី ៨ អ៊ាលី អាល់-រីដ្ហ៊ូصلوات الله عليه والسلام មានវចនៈថា៖

مَنْ زَارَ الـمَعْصُوْمَةَ بقم كَمَنْ زَارَنِيْ (رياحين الشريعة، ج١، ص٥٣٥ internet)

"អ្នកណាទៅគោរពម៉ាក់ស៊្វូម៉ាស់سلام الله عليها នៅឯគុម ដូចអ្នកនោះទៅសម្ដែងសេចក្ដី

[1] អ៊ាឡាម៉ាស់ មូហ៊ាំម៉ាដ់ បាគៀរ ម៉ាច់លីស៊ី (محمد باقر بن محمد تقي بن مقصود علي المجلسي), ប៊ីហ្សារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២២៨ ។ ក៏ដ្ហី នូរុលឡោះហ្ស៊ូស្ទ៊ូស្តារី (قاضي نور الله شوشتري) ម៉ាយ៉ាលីស៊ី អាល់-មុមីនីន (مجالس المومنين) ក្បាលទី ១ ទំព័រ ៨៣ ។

គោរពចំពោះខ្ញុំصلوات الله عليه والسلامដែរ ។" (535 :1 رياحين الشريعة)[2]

-អ៊ីម៉ាំទី ៩ មូហ៊ាំម៉ាដ់ អាល់-តាគ្គី អាល់-យ៉ាវ៉ាដ់صلوات الله عليه والسلام មានវចនៈថា៖

مَنْ زَارَ قَبْرَ عَمَّتِي بِقُمَّ فَلَهُ اَلْجَنَّةُ . (بحار الأنوار – الجزء : ١٠٢ صفحة : ٢٦٥ حديث : ٣ (internet

"អ្នកទៅសម្តែងសេចក្តីគោរពចំពោះផ្នូរព្រះបិតុច្ឆាسلام الله عليهاខ្ញុំصلوات الله عليه والسلامនៅឯគុម អ្នកនោះនឹងបានចូលឋានសួគ៌ ។" (3 /265 :102 بحار الأنوار)[3]

---

[2] មៀរស្សា មូហ៊ាំម៉ាដ់ តាគ្គី ខាន សេប៉េះរ៍ (محمد تقى سپهر) ណាស៊ីក្ខ អាល់-តាវ៉ារីក្ខ (ناسخ التواريخ) ក្បាលទី ៣ ទំព័រ ៦៨ ។ ស្ហៃខ៍ ស្សាប៊ីហ៊ុលឡោះហ្ម៍ មូហាឡាទី (ذبيح‌الله محلاتى مشتاق‌عسكرى) រ៉យ៉ាហ៊ីន អាល់-ស្សារីអ៊ាស្ហ៍ (رَياحين الشَريعَة) ក្បាលទី ៥ ទំព័រ ៣៥ ។

[3] ប៊ីហ៊ារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ១០២ ទំព័រ ២៦៥ ។

# ១. ព្រះជីវប្រវត្តិរបស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វមម៉ាស់سلام الله عليها

## ១.១ ទំនាយកំណើតមហាស្ត្រីថ្លៃថ្លា

គប្បីចាប់អារម្មណ៍ថាព្រះសន្តអ៊ីម៉ាំعليهم السلامបានទាយទុកថា មហាស្ត្រីថ្លៃថ្លាអង្គនេះسلام الله عليهاនឹងមកចាប់កំណើត ហើយព្រះនាងسلام الله عليهاនឹងមានព្រះវត្តមាននៅឯនគរគុម ច្រើនឆ្នាំមុនព្រះនាងسلام الله عليهاចាប់កំណើត ។

លោកអ្នកប្រាជ្ញ ក៏ហ្ស៊ី នូរុលឡោះហ៍ ស៊ូស្ទតារី (قاضي نور الله شوشتري) (ឆ្នាំសាកល 1549-1610, សករាជហ៊ិជ្រាះត៍ 956-1019)) បានរាយការណ៍តមកពីអ៊ីម៉ាំ យ៉ាក់ហ្វារ អាល់-ស្វ៉ាឌិកូصلوات الله عليه والسلام ថា៖

تُقْبَضُ فِيهَا اِمْرَأَةٌ مِنْ وُلْدِي، اِسْمُهَا فَاطِمَةُ بِنْتُ مُوسَى، وَ تُدْخَلُ بِشَفَاعَتِهَا شِيعَتِي اَلْجَنَّةَ بِأَجْمَعِهِمْ. (بحار الأنوار ج٥٧ ص٢٢٨ internet)

មហាស្ត្រីមួយអង្គក្នុងបណ្តាកូនចៅខ្ញុំصلوات الله عليه والسلامឈ្មោះ ហ្វាទីម៉ាស់ ព្រះរាជបុត្រីរបស់ មូសាصلوات الله عليه والسلام នឹងសោយព្រះទិវង្គតនៅឯគុម ។ ថ្ងៃជំនុំជម្រះ មហាស្ត្រីនេះនឹងធ្វើអន្តរាគមន៍ឲ្យស៊ីអ៊ាស់ទាំងអស់របស់ខ្ញុំصلوات الله عليه والسلامបានចូលឋានសួគ៌ ។"
(بحار الأنوار 8: 228)[1]

លោកអ្នកប្រាជ្ញ អាឡាម៉ាស់ អាល់-ម៉ាច់លីស៊ី (العلامة المجلسي - ឆ្នាំសាកល 1627-1690, សករាជហ៊ិជ្រាះត៍ 1037-1110) បានរាយការណ៍តមកពីអ៊ីម៉ាំ អាល់-ស្វ៉ាឌិកូصلوات الله عليه والسلام ថា៖

وَ سَتُدْفَنُ فِيهَا اِمْرَأَةٌ مِنْ أَوْلَادِي تُسَمَّى فَاطِمَةَ، فَمَنْ زَارَهَا وَجَبَتْ لَهُ اَلْجَنَّةُ. (بحار الأنوار ج٥٧

---

[1] ប៊ីហ្ការ អាល់-អានវ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២២៨ ។ ម៉ាយ៉ាលីស អាល់-មុមីន (مجالس المؤمنين) ក្បាលទី ១ ទំព័រ ៨៣ ។

(internet ص٢١٦

"មហាស្ត្រីមួយអង្គក្នុងបណ្តាកូនចៅខ្ញុំصلوات الله عليه والسلامឈ្មោះ ហ្វាទីម៉ាស់ នឹងត្រូវបញ្ចុះសាកសពនៅឯគូម ។ អ្នកណាទៅគោរព[ព្រះចេតិយ]ព្រះនាង អ្នកនោះត្រូវតែបានចូលឋានសួគ៌ ។" (بحار الأنوار 57: 216)[2]

លោកអ្នកប្រាជ្ញខាងលើនេះមានប្រសាសន៍ថាអ៊ីម៉ាំ អាល់-ស្វ៉ឌិក្វصلوات الله عليه والسلام បានប្រាប់ដំណឹងនេះតាំងពីមុនព្រះរាជបុត្រصلوات الله عليه والسلامព្រះអង្គصلوات الله عليه والسلامប្រសូតម្ល៉េះ អ៊ីម៉ាំទី ៧ គឺ អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីមصلوات الله عليه والسلام ព្រះបិតាصلوات الله عليه والسلامរបស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហ៊ូម៉ាស់سلام الله عليها ។

អ៊ីម៉ាំ អាល់-កាស្ហ៊ីមصلوات الله عليه والسلامប្រសូតក្នុងឆ្នាំ ១២៨ សករាជហ៊ីជ្រ៉ោះត៍ ឯព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហ៊ូម៉ាស់سلام الله عليها ប្រសូតក្នុងឆ្នាំ ១៧៣ សករាជហ៊ីជ្រ៉ោះត៍ បានសេចក្តីថាដំណឹងចាប់កំណើតព្រះនាងត្រូវបានទាយយ៉ាងតិច ៤៥ ឆ្នាំមុនព្រះនាងប្រសូតម្ល៉េះ ។

## ១.២ កំណើតព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហ៊ូម៉ាស់سلام الله عليها

សេចក្តីរាយការណ៍ខ្លះបានឲ្យដឹងថាព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហ៊ូម៉ាស់سلام الله عليها ប្រសូតថ្ងៃទី ១ ខែ ស៊្សុល-ក្វក៌ដ្ហាស់ ឆ្នាំ ១៧៣ សករាជហ៊ីជ្រ៉ោះត៍ នៅម៉ាឌីណាស់ ។

១. អាយ៉ាទុលឡោះហ៍ ស្សែខ៍ អ្កលី ណាម៉ាស៊ី (ទទួលអនិច្ចកម្មឆ្នាំ ១៩៨៥ ឆ្នាំសាកល ត្រូវនឹងឆ្នាំ ១៤០៥ សករាជហ៊ីជ្រ៉ោះត៍) បានសរសេរថា៖

---

[2] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ៣១៧, ក្បាលទី ៦០ ទំព័រ ២១៦, ក្បាលទី ១០២ ទំព័រ ២៦៦ ។

فاطمة المعصومة المولودة في غرة ذي القعدة سنة ١٧٣. (مستدرك سفينة البحار – جلد : ٨ صفحه : ٢٦١ internet)

ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺ ប្រសូតថ្ងៃទី ១ ខែ ស៊ុល-ក្វក់ដាស់ ឆ្នាំ ១៧៣ សករាជហ៊ីជ្រ៉ោះត៍ ។ (مستدرك سفينة البحار 8: 261)[3]

២. មុលឡា មុះហ៊ុសិន អាល់-ហ្វៃដ៍ (ملا محسن الفيض) បានរាយការណ៍ថា៖ "ហ្វាទីម៉ាស់ [ម៉ាក់ស៊្ហូម៉ាស់] ប្រសូតនៅម៉ាឌីណាស់ ដើមខែ ស៊ុល-ក្វក់ដាស់ ឆ្នាំ ១៧៣ សករាជហ៊ីជ្រ៉ោះត៍ សោយព្រះទិវង្គតនៅឯគុម ថ្ងៃទី ១០ ខែ រ៉ប៊ីអ៊ុ អាល់-ស្សានី ឆ្នាំ ២០១ សករាជហ៊ីជ្រ៉ោះត៍ ។[4]

បណ្ឌិតច្រើននាក់ទៀតក៏បានសរសេរដែរថាព្រះនាងﷺប្រសូតដើមខែ ស៊ុល-ក្វក់ដាស់ គឺ៖

-អ៊ុឡាម៉ាស់ បាស់រ៉នី បានរាយការណ៍នៅក្នុងសៀវភៅលោក អាល់-អ៊ុវ៉ាលីម អាល់-អ៊ុលូម (عوالم العلوم) ក្បាលទី ២១ ទំព័រ ៣២៨ ។

-ស្ហៃខ៍ ម៉ាស់ឌី ម៉ាន់ស៊ូរី បានរាយការណ៍នៅក្នុងសៀវភៅលោក ហ៊ាយ៉ាត់ អាល់-សាដាត់ (Hayat Al-Sadat) ទំព័រ ១០ ។

-បណ្ឌិត មូហ៊ាំម៉ាដ់ ហូឌី អាមីនី បានរាយការណ៍នៅក្នុងសៀវភៅលោក ហ្វាទីម៉ាស់ ប៊ិនត៍ អាល់-អ៊ីមុាំ មូសា អាល់-កាស៊្ហីម (Fatimah Bint Al-Imam

[3] ស្ហៃខ៍ អ៊ុលី ណាម៉ាស៊ី (شيخ على نمازى شاهرودى) មុសតាដ់រ៉ក់ សាហ្វីណាស់ អាល់-ប៊ីហ៊ារ (مُستَدرَك سَفينة البِحار) ក្បាលទី ៨ ទំព័រ ២៥៧ ។

[4] អ៊ុប់បាស់ ហ្វៃដ៍ (عباس فيض قمى) កាន់យ៉ីណាស់ អាស្សារ គុម (گنجینه آثار قم) ក្បាលទី ១ ទំព័រ ៣៨៦ ។

Musa Al-Kadim) ទំព័រ ២១ ។

-អាស៊ុម៉ាដ្ជ់ ស្មាដេះហ្វ៍ បានសរសេរនៅក្នុងសៀវភៅលោក ស្ទេនដេកានី ហាដ្ឌរ៉ត់ មូសា អ៊ីបន្ យ៉ាក់្វហ្វារ (Zendegani Hadrat Musa Ibn Ja’far) ទំព័រក្បាលទី ២ ៣៧៥

លោកអ្នកនិពន្ធខ្លះទៀតបានសរសេរថាព្រះនាងسلام الله عليهاប្រសូតក្នុងឆ្នាំ ១៨៣ សករាជហ៊ីជ្រ៉ោះត៍ មិនមែនឆ្នាំ ១៧៣ សករាជហ៊ីជ្រ៉ោះត៍ទេ តែមិនត្រឹមត្រូវទេ ដោយមានមូលហេតុពីរ ។

បើយើងសិក្សាព្រះជីវប្រវត្តិរបស់អ៊ីម៉ាំ មូសា អាល់-កាស៊ីមصلوات الله عليه والسلام យ៉ាងពិស្តារ យើងនឹងឃើញថាថ្ងៃទី ២៥ ខែ រ៉យ៉ាប់ ឆ្នាំ ១៨៣ សករាជហ៊ីជ្រ៉ោះត៍ ព្រះអង្គصلوات الله عليه والسلامសោយព្រះទិវង្គតនៅក្នុងមន្ទីរឃុំឃាំងខេត្តបាក់ដាដ់ ។ យើងដឹងទៀតថា ព្រះអង្គصلوات الله عليه والسلامបានជាប់ពន្ធនាគារយ៉ាងតិចបួនឆ្នាំ ។ ក្នុងអំឡុងពេលព្រះអង្គصلوات الله عليه والسلام ជាប់ពន្ធនាគារនេះ គ្រួសារព្រះអង្គصلوات الله عليه والسلامរស់នៅឯម៉ាឌីណាស៊ូ ។ អាស្រ័យហេតុនេះ ព្រះនាង ហ្វាទីម៉ាស៊្ហ ម៉ាក់ស៊្សូម៉ាស៊្ហسلام الله عليها មិនអាចសោយព្រះទិវង្គតឆ្នាំ ១៨៣ សករាជហ៊ីជ្រ៉ោះត៍ទេ ។

ម្យ៉ាងទៀត កំណត់ហេតុបានឲ្យដឹងថាអ៊ីម៉ាំ អាល់-កាស៊ីមصلوات الله عليه والسلام មានបុត្រីច្រើននាក់ដែលឈ្មោះ ហ្វាទីម៉ាស៊្ហ ។ ចំណែកព្រះនាង ហ្វាទីម៉ាស៊្ហ ម៉ាក់ស៊្សូម៉ាស៊្ហسلام الله عليها ជាព្រះរាជបុត្រីបងគេ (ហ្វាទីម៉ាស៊្ហ អាល់-គុបរ៉ា فَاطِمَة الكُبرى) ។ អាស្រ័យហេតុនេះ ឆ្នាំកំណើតព្រះនាងسلام الله عليها មិនអាចដូចឆ្នាំព្រះបិតាصلوات الله عليه والسلامព្រះនាងسلام الله عليهاសោយព្រះទិវង្គតទេ ។

ដូច្នេះយោលតាមព័ត៌មានខាងលើនេះ ព្រះនាង ហ្វាទីម៉ាស៊្ហ ម៉ាក់ស៊្សូម៉ាស៊្ហسلام الله عليها

មិនអាចប្រសូតក្នុងឆ្នាំ ១៨៣ សករាជហ៊ីជ្ជរ៉ោះត៏ទេ ។ អស់លោកអ្នកនិពន្ធដែលបានថាព្រះនាងﷺប្រសូតឆ្នាំនេះបានថាខុស ត្រូវថាប្រសូតឆ្នាំ ១៧៣ សករាជហ៊ីជ្ជរ៉ោះត៏ទើបត្រឹមត្រូវ ។

## ១.៣ ថ្ងៃខែព្រះនាង ហ្វាទ្វីម៉ាស្ម៍ ម៉ាក់ស៊្វូម៉ាស្ម៍ ﷺ ចូលទិវង្គត

ទាំងអស់គ្នាមូលមតិគ្នាថាព្រះនាង ហ្វាទ្វីម៉ាស្ម៍ ម៉ាក់ស៊្វូម៉ាស្ម៍ﷺ ចូលព្រះទិវង្គតនៅឯទីក្រុងគុម ឆ្នាំ ២០១ សករាជហ៊ីជ្ជរ៉ោះត៏ ។ ឆ្នាំចារនៅលើបន្ទះការ៉ូនៅក្នុងចេតិយព្រះនាង[5]ﷺត្រូវគ្នានឹងឆ្នាំព្រះនាងﷺចូលព្រះទិវង្គត ។

ក៏ប៉ុន្តែខែនិងថ្ងៃអាចខុសគ្នា គឺ៖
-ថ្ងៃទី ១០ ខែ រ៉ប៊ីអ៊ុល-ស្សានី[6]
-ថ្ងៃទី ១២ ខែ រ៉ប៊ីអ៊ុល-ស្សានី[7]
-ថ្ងៃទី ៨ ខែ ស្ហាក់បាន[8]

---

[5] ហាសាន់ អ៊ីបនូ មូហាំម៉ាដ់ គូម៉ី (حسن بن محمد قمي) តារីក កាឌីម គុម (تاريخ قم) ទំព័រ ២១៣ ។ ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ៣១៧ ក្បាលទី ៤៨ ទំព័រ ២៩០ ។ សៃយីដ មុះហ៊្សីន យ៉ាបាល់ អាល់-អាមីលី (السيد محسن الأمين العاملي) អាក់យ៉ាន់ អាល់-ស្ស៊ីអ៊ាស្ម៍ (أعيان الشيعة) ក្បាលទី ៨ ទំព័រ ៣៩១ ។ ស្សៃខ៏ អាប់បាស់ គូម៉ី (الشيخ عباس القمي) មុនតាហា អាល់-អាម៉ាល់ (مُنتَهى الآمال) ក្បាលទី ២ ទំព័រ ២៤២ ។ សៃយីដ ហាសាន់ អាល់-អាមីន (حسن الأمين) ដាអ៊ីរ៉ោះត៏ អាល់-ម៉ាអ៊ារីហ្វ (دائرة المعارف) ក្បាលទី ៣ ទំព័រ ២៣១ ។

[6] មៀរ អាប៊ូ ត៉ាលិប អាល់-តាប់រីស៊ី (مير ابو طالب التبريزي), វ៉ាស៊ីឡាស្ម៍ អាល់-ម៉ាក់ស៊្វូមីន, ទំព័រ ៦៥ ។ សៃយីដ ម៉ាស្ម៍ឌី ម៉ាន់ស៊្វូរី (مهدى منصورى) ស៊ីនដាកានី ហាដ់រ៉ត់ ម៉ាក់ស៊្វូម៉ាស្ម៍ (زندگانى حضرت معصومه) ទំព័រ ៣៧ ។ អាលី អាក់បារ ម៉ាស្ម៍ឌីពួរ (على اكبر مهدى پور) ស៊ីនដាកានី ការីម៉ាស្ម៍ អាស្ម៍លុល-បៃត៏ﷺ (زندگانى كريمه اهل بيت) ទំព័រ ១០៥ ។

[7] មុសតាដ់រ៉ក់ សាហ្វីណាស្ម៍ អាល់-ប៊ីហារ (مُسْتَدْرَك سَفينة البِحار) ក្បាលទី ៨ ទំព័រ ២៥៧ ។

ព្រោះតែមិនច្បាស់ថាថ្ងៃមួយណាជាថ្ងៃពិត លោកអ្នកប្រាជ្ញបានសម្រេចថា ព្រោះតែថ្ងៃដំបូងនិងថ្ងៃបន្ទាប់ជាថ្ងៃដែលកៀកនឹងការពិត ការកាន់មរណទុក្ខមហាស្ត្រីថ្លៃថ្លាអង្គនេះនឹងប្រព្រឹត្តទៅក្នុងអំឡុងពេលបីថ្ងៃ (ថ្ងៃទី ១០, ទី ១១ និងទី ១២ ខែ រ៉ប៊ីអ៊ុល-ស្ហានី) ។ គេហៅអំឡុងពេលបីថ្ងៃនេះថា "ថ្ងៃម៉ាក់ស៊្វម៉ាស់" (ايّام معصوميّة) ។

ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វម៉ាស់سلام الله عليها មានព្រះជន្ម ២៨ ព្រះវស្សាកាលព្រះនាងسلام الله عليهاសោយព្រះទិវង្គត ។ លោកអ្នកប្រាជ្ញខ្លះថាពេលព្រះនាងسلام الله عليهاចូលព្រះទិវង្គត ព្រះនាងسلام الله عليهاមានព្រះជន្ម ១៨ ព្រះវស្សា (ដោយយល់ខុសតាមឆ្នាំព្រះនាងسلام الله عليها ប្រសូត ឆ្នាំ ១៨៣ សករាជហ៊ិជ្រ៉ោះត៍ មិនមែនឆ្នាំ ១៧៣ សករាជហ៊ិជ្រ៉ោះត៍ទេ) ។ លោកអ្នកប្រាជ្ញឯទៀតថាព្រះនាងسلام الله عليهاមានព្រះជន្ម ២៣ ព្រះវស្សា តែសេចក្ដីរាយការណ៍នេះមិនគួរឲ្យជឿបានទេ ដោយសារបណ្ដាញអ្នកឲ្យព័ត៌មានខ្សោយ (មិនអាចយកជាការបាន) ។

## ១.៤ ព្រះបិតាصلوات الله عليه والسلامព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វម៉ាស់سلام الله عليها ។

ព្រះបិតាصلوات الله عليه والسلامរបស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វម៉ាស់سلام الله عليها គឺអ៊ីម៉ាំទី ៧ អ៊ីម៉ាំ មូសា អាល់-កាស៊ីមصلوات الله عليه والسلام ។ កំណត់ហេតុបានឲ្យដឹងថាអ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام មានបុត្រាបុត្រីច្រើន ។

លោក ស្ហៃខ៍ អាល់-មូហ្វីដ (الشيخ المفيد កើតឆ្នាំ ៣៣៦ ស.ហ៊.- ៩៤៨ គ.ស. ស្លាប់

[8] ស្ហៃខ៍ ហ៊ួរ អាល់-អ៊ាមីលី (الحر العاملي), អ៊ីស្ហ្សបាត់ អាល់-ហ៊ូដាស់ (إثباتُ الهُداة) ក្បាលទី ៣ ទំព័រ ២៣៣ ។ ស្ហៃខ៍ ហ៊ួរ អាល់-អ៊ាម៉ាលី (الحر العاملي) រីសាឡាស់ អាល់-អ៊ារ៉ាប៊ីយ៉ាស់ អាល់-អ៊ាឡាវីយ៉ាស់ (العربية العلويه واللغة المروية) ទំព័រ ១១ ។

ឆ្នាំ ៨១៣ ស.ហ្ង. - ១០២២ ធ.ស.) បានសរសេរថាអ៊ីមុាំ អាល់-កាស៊្ឋិម صلوات الله عليه والسلام មានបុត្រាបុត្រី ៣៧ នាក់ បុត្រា ១៩ នាក់ បុត្រី ១៨ នាក់ ។ បុត្រីពីរនាក់របស់ព្រះអង្គ صلوات الله عليه والسلام ឈ្មោះ ហ្វាទ្ទីម៉ាស្ហ៍ អាល់-គុបរ៉ា និង ហ្វាទ្ទីម៉ាស្ហ៍ អាល់-ស្ទុក្ររ៉ (فاطمة الصغرى) ។[9]

លោក ស៊ីបត៍ ប៊ីន យ៉ោ្ជស៊ុី (سبط بن الجوزي) អ្នកប្រាជ្ញអាស្ហ៍លុល-ស៊ុនណាស្ហ៍ល្បីម្នាក់ក្នុងសតវត្សរ៍ទី ៨ នៃសករាជហ៊ុីច្ជរ៉ោះត៍ បានឲ្យដឹងថាបុត្រីបួននាក់របស់អ៊ីមុាំ អាល់-កាស៊្ឋិម صلوات الله عليه والسلام មានឈ្មោះថាហ្វាទ្ទីម៉ាស្ហ៍ គឺ៖ ហ្វាទ្ទីម៉ាស្ហ៍ អាល់-គុបរ៉ា, ហ្វាទ្ទីម៉ាស្ហ៍ អាល់-វុស្តត៍ (فاطمة الوسطى), ហ្វាទ្ទីម៉ាស្ហ៍ អាល់-ស្ទុក្ររ៉ (فاطمة الصغرى) និង ហ្វាទ្ទីម៉ាស្ហ៍ អាល់-អ៊ុក្ររ៉ ។[10]

ហ្វាទ្ទីម៉ាស្ហ៍ អាល់-គុបរ៉ា គឺ ហ្វាទ្ទីម៉ាស្ហ៍ ម៉ាក់ស្វូម៉ាស្ហ៍ سلام الله عليها ចញ្ចុះព្រះរាជសពនៅខេត្តគុមនោះឯង ។ កំណត់ហេតុឲ្យដឹងថាព្រះរាជសពព្រះនាង ហ្វាទ្ទីម៉ាស្ហ៍ អាល់-វុស្តត៍ ត្រូវបានបញ្ចុះនៅឯខេត្តអ៊ីស្វ-ហ្វាហ្ងាន់ ។ គេហៅព្រះចេតិយព្រះនាងថា ស៊ីត្ទី ហ្វាទ្ទីម៉ាស្ហ៍ (سيتي فاطمة) (ក្បែរ ឆាហ្ងារ ស៊ុក្ខ ស្ហ៊ីរ៉ស៊ុី ហា) ។

ហ្វាទ្ទីម៉ាស្ហ៍ អាល់-ស្ទុក្ររ៉ (فاطمة الصغرى) ហៅឈ្មោះក្រៅថា "ប៊ីប៊ី ហៃ្ងបាត់ (بی‌بی هيبت)" ។ ព្រះរាជសពព្រះនាងត្រូវបញ្ចុះនៅឯប្រទេស អាស៊ែរបៃយ៉ាន់ (Azerbaijan)[11] ។ ដោមនិងសួនឡោមព័ទ្ធចេតិយព្រះនាងត្រូវកម្ទេចចោលក្នុងរបបកុម្មុយនិស្តរុស្ស៊ី ។

---

[9] ស្ហៃខ៍ មូហ្វីដ្ឋ (الشيخ المفيد) អាល់-អៀរស្ហាដ្ឋ៍ (الإرشاد) ព្រះជីវប្រវត្តិរបស់អ៊ីមុាំ អាល់-កាស៊្ឋិម صلوات الله عليه والسلام ។

[10] ស៊ីបត៍ ប៊ីន យ៉ោ្ជស៊ុី (سبط بن الجوزي) តាស្ហ៍គីរ៉ត់ អាល់-ខ៏វ៉ាស្វ៍ (تذكرة الخواص) ទំព័រ ៣១៥ ។

[11] ប៊ីហ្ងារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ៣១៧ ។

ហ្វាទ៊ីម៉ាស្ទ៍ អាល់-អ៊ុក្ខរ៉ា ដែលគេហៅឈ្មោះដែរថា ហ្វាទ៊ីម៉ាស្ទ៍ គុំហ្វ៊ុរ៉ោះត្ទ៍ ព្រះរាជសពព្រះនាងត្រូវបញ្ចុះនៅឯខេត្ត រ៉ស្ទ៍ត៍ ប្រទេសអ៊ីរ៉ង់ ។[12]

លោកអ្នកស្រាវជ្រាវសហសម័យ អាល់ឡាម៉ាស្ទ៍ ស្ហៃខ្ទ៍ មូហ្ហាំម៉ាដ្ទ៍ តាគ្គី អាល់-ទុសតារី (عَلَّامة شيخ محمد تقي التستري) បានសរសេរថា៖ "ក្នុងបណ្ដាព្រះរាជបុត្រាបុត្រីទាំងអស់របស់អ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام ពុំមានអ្នកណាមួយស្មើព្រះនាងហ្វាទ៊ីម៉ាស្ទ៍ ម៉ាក់ស៊្វូម៉ាស្ទ៍ سلام الله عليها ទេ ក្រៅពីអ៊ីម៉ាំ អាលី អាល់-រីដ៏ صلوات الله عليه والسلام ។"[13]

ឆ្នាំ ១៧៣ សករាជហ៊ុីជ្រ៉ោះត្ទ៍ ហារូន អាល់-រ៉ស្ទ៊ីដ្ទ៍ ឡើងសោយរាជ្យខ៉ លីហ្វាស្ទ៍ ។ ប្រាំមួយឆ្នាំក្រោយមក ថ្ងៃទី ២០ ខែ ស្ហៅវ៉ាល់ ឆ្នាំ ១៧៩ សករាជហ៊ុីជ្រ៉ោះត្ទ៍ ស្ដេចខ៉លីហ្វនេះបានចេញបញ្ជាឲ្យចាប់ខ្លួនអ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام នៅម៉ាឌីណាស្ទ៍ ។ គេបានចាប់ខ្លួនអ៊ីម៉ាំ صلوات الله عليه والسلام ពេលព្រះអង្គ صلوات الله عليه والسلام កំពុងស្វ៊ឡាត្ទ៍នៅក្នុងម៉ាស់យ៉ិដ្ទ៍ព្រះសាស្ដា صلى الله عليه وآله وسلم ។ បន្ទាប់មកគេបានបញ្ជូនព្រះអង្គ صلوات الله عليه والسلام ទៅដាក់ពន្ធនាគារងងឹតនៅឯខេត្តបាក់ដ្ហាដ់ប្រទេសអ៊ីរ៉ាក់ ។ ព្រះអង្គ صلوات الله عليه والسلام បាននៅទីនេះអស់មួយជីវិត ។

ស្ដេច ហារូន បានដាក់ថ្នាំបំពុលអ៊ីម៉ាំ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام សោយព្រះទិវង្គតនៅក្នុងពន្ធនាគារក្រុងបាក់ដ្ហាដ់ថ្ងៃទី ២៤ ឬ ២៥ ខែ រ៉យ៉ាប់ ឆ្នាំ ១៨៣ សករាជហ៊ុីជ្រ៉ោះត្ទ៍ ។ ព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ត្រូវបានបញ្ចុះនៅ "អាល់-ម៉ាក់ប៉ៀរ អាល់-គូរ៉យស្ទ៍" សព្វថ្ងៃហៅថា កាស៊ីម៉ៃន៍ ។ ព្រះរាជសពអ៊ីម៉ាំទី ៩ អ៊ីម៉ាំ មូហ្ហាំម៉ាដ្ទ៍ អាល់-តាគ្គី صلوات الله عليه والسلام ត្រូវបញ្ចុះនៅទីនេះដែរ ។[14]

---

[12] ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ៣១៧ ។

[13] ស្ហៃខ្ទ៍ មូហ្ហាំម៉ាដ្ទ៍ តាគ្គី ទុសតារី (محمد تقي التستري), តាវ៉ារីក្ខ អាល់-ណាប៊ី វ៉ាល់-អាលី ទំព័រ ៦៥ ។

[14] អូស្វ៊ូល អាល់-កាហ្វី (أُصُول الْكَافِي) ក្បាលទី ១ ទំព័រ ៤៧៦ ។ អាល់-អៀរស្ហាដ្ទ៍ (الإرشاد)

យើងអាចសម្រេចបានថាអ៊ីម៉ាំ صلوات الله عليه والسلام បានជាប់ពន្ធនាគារអស់បួនឆ្នាំ យោលតាមព័ត៌មានថ្ងៃខែខាងលើនេះ ។ ក៏ប៉ុន្តែលោកអ្នកប្រវត្តិសាសន៍ខ្លះមានប្រសាសន៍ថាព្រះអង្គ صلوات الله عليه والسلام ជាប់ពន្ធនាគារប្រាំពីរឆ្នាំ ចំណែកឯលោក អ៊ីបនូ យ៉ៅស៊ី បានថាព្រះអង្គ صلوات الله عليه والسلام ត្រូវឃុំឃាំងអស់រយៈពេលដប់មួយឆ្នាំ ។[15]

## ១.៥ ព្រះមាតា رضي الله عنها ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ។

ព្រះមាតា رضي الله عنها របស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ជាព្រះមាតា رضي الله عنها របស់អ៊ីម៉ាំទី ៨ ដែរ អ៊ីម៉ាំ អាលី អាល់-រីដ្ហ៍ صلوات الله عليه والسلام ។ ព្រះនាង رضي الله عنها មានតែព្រះរាជបុត្រពីរអង្គនេះទេ ។ ព្រះនាង رضي الله عنها មានព្រះនាមច្រើន ព្រះនាមល្បីជាងគេគឺ ណាច់ម៉ាស់ ខ៊ុទុន (نجمة خاتون) ។[16]

ព្រះនាង رضي الله عنها ជាអតីតស្ត្រីបម្រើអាហ្វ្រិកខាងជើងត្រូវព្រះនាង ហាមីដ្ហាស់ رضي الله عنها ព្រះមាតារបស់អ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام ទិញ ។ បន្ទាប់ពីបានចូលមកក្នុងជម្រកព្រះរាជកុលដ្ឋាន អាស់លុល-បៃត៍ عليهم السلام ព្រះនាង رضي الله عنها ឈានទៅដល់កម្រិតខ្ពស់ផ្នែកប្រាជ្ញានិងសាសនាអាស្រ័យការអប់រំរបស់ព្រះនាងហាមីដ្ហាស់ رضي الله عنها ។

---

ក្បាលទី ២ ទំព័រ ២១៥ ។ អាលី ប៊ិន ហ៊ូសៃន៍ ម៉ាស់អ៊ូឌី (عَلِيّ ٱبْن ٱلْحُسَيْن ٱبْن عَلِيّ ٱلْمَسْعُودِيّ), អ៊ីស្បាត់ អាល់-វ៉ាស៊ីយ៉ាស់ (اثبات الوصية) ទំព័រ ១៦១-១៦៩ ។

[15] គាស់គីរ៉ត់ អាល់-ខ៊ូវ៉ាស់ ទំព័រ ៣១៤ ។

[16] ស្ហៃខ៍ ស៊ូឌូក្វ (الشيخ الصدوق), អ៊ុយុន អាល់-អាក់បារ អាល់-រីដ្ហ៍ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ១ ទំព័រ ១៤ ។ ស្ហៃខ៍ តុប់រ៉សី (الطبرسي), អាក់ឡាំ អាល់-វ៉ារ៉ (اعلام الورى) ទំព័រ ៣០២ ។ ស្ហៃខ៍ ហ៊ូរ អាល់-អាមីលី (الحر العاملي), អ៊ីស្បាត់ អាល់-ហ៊ូដ្ហាស់ (إثباتُ الهُداة) ក្បាលទី ៣ ទំព័រ ២៣៣ ។

ព្រះនាង ហាមីដ្ហាស់ رضي الله عنها បានឲ្យដឹងថាយប់មួយព្រះនាង رضي الله عنها បានសុបិនឃើញព្រះសាស្តា صلى الله عليه وآله وسلم ប្រាប់ព្រះនាង رضي الله عنها ថា៖ "អល់ឡោះហ៊្វ عز وجل បានដាក់ព្រះរាជបញ្ជាឲ្យព្រះនាង رضي الله عنها អភិសេកព្រះនាង ណាជ់ម៉ាស់ رضي الله عنها ជាមហេសីរបស់ មូសា អ៊ីបនូ យ៉ាក់ហ្វារ صلوات الله عليه والسلام ព្រះរាជបុត្ររបស់នាង رضي الله عنها ដើម្បីនឹងឲ្យបុគ្គលប្រសើរជាច់គេក្នុងលោក (អ៊ីមុាំ អាល់-រីដ្ហ៉ صلوات الله عليه والسلام) ប្រសូតមកពីពោះព្រះនាង رضي الله عنها ។[17]

ព្រះនាង ហាមីដ្ហាស់ رضي الله عنها ក៏បានធ្វើតាមបណ្តាំក្នុងសុបិន ។ ព្រះនាង ណាជ់ម៉ាស់ رضي الله عنها ក៏បានទៅជាព្រះមហេសីរបស់អ៊ីមុាំ អាល់-កាស្ហ៊ុម صلوات الله عليه والسلام ក្រោយមកក៏បានទៅជាព្រះមាតារបស់អ៊ីមុាំ អាល់-រីដ្ហ៉ صلوات الله عليه والسلام និងព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ។ ព្រះនាង ណាជ់ម៉ាស់ سلام الله عليها មានព្រះនាមក្រៅច្រើនទៀត ដូចជា៖

**-ទុកតាំ** (تكتم) នាមប្រជាប្រិយដែលពួកអារ៉ាប់ហៅ ។ ជានាមរបស់ព្រះមាតាអ៊ីមុាំ អាល់-រីដ្ហ៉ صلوات الله عليه والسلام និងព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها កាលគេបានទិញព្រះនាង ។ ឈ្មោះ ទុកតាំ ផ្តោតអត្ថន័យទៅលើអណ្តូងទឹក ស៊ាំស៊ាំ ដែល អ៊ាប់ឌុល-មុត្តត៏លិប رضي الله عنه បានឃើញក្នុងសុបិន ។ នៅក្នុងសុបិននេះ គេបានប្រាប់លោក رضي الله عنه ឲ្យជីកកន្លែងនីមួយរកអណ្តូងទឹកដែលបានលុបបាត់យូរមកហើយ ។ ដូច្នេះ ទុកតាំ ជានាមសក្តិសមណាស់សម្រាប់ព្រះនាង ណាជ់ម៉ាស់ رضي الله عنها ពីព្រោះគុណសម្បត្តិវិសេសវិសាលរបស់ព្រះនាង سلام الله عليها ក៏ត្រូវលាក់បាំងដែរ កាលពីព្រះនាងនៅជាស្ត្រីបម្រើ ។[18]

**-អ៊ុម អាល់-បានីន** (أم البنين) នេះជានាមពិសេសមួយដែរដែលគេដាក់ឲ្យព្រះនាង

---

[17] អ៊ុយុន អាល់-អាក់បារ អាល់-រីដ្ហ៉ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ១ ទំព័រ ១៧ ។

[18] អ៊ុយុន អាល់-អាក់បារ អាល់-រីដ្ហ៉ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ១ ទំព័រ ១៤ ។ អាក់ឡាំ អាល់-វ៉ារ៉ (اعلام الورى) ទំព័រ ៣០២ ។ អ៊ីស្បាត់ អាល់-ហ៊ូដ្ហាស់ (إثباتُ الهُداة) ក្បាលទី ៣ ទំព័រ ២៣៣ ។

رضي الله عنها មានន័យថា "មាតារបស់បុត្រា" ទោះបីព្រះនាង ណាច់ម៉ាស់ رضي الله عنها មានបុត្រតែពីរអង្គក៏ដោយ [អ៊ីមុាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام និងព្រះនាង ហ្វាទ្វីម៉ាស់ ម៉ាក់ស៊្វម៉ាស់ سلام الله عليها] ។ ដោយសារបុណ្យបារមីរបស់ព្រះរាជបុត្រទាំងពីររបស់នាង سلام الله عليها បានជាព្រះនាង رضي الله عنها មានព្រះកិត្តិយសទទួលបុណ្យស័ក្តិថា "អ៊ុម អាល់-បានីន" ។[19]

-ត៏ហ៊ីរ៉ោះត៏ គេបានឲ្យដឹងថាបន្ទាប់ពីបានប្រសូតអ៊ីមុាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام ថ្ងៃទី ១១ ខែស៊ុល ក្វក់ដាស់ ឆ្នាំ ១៤៨ សករាជហ៊ុិចរ៉ោះត៏ នៅម៉ាឌីណាស់ ព្រះនាង رضي الله عنها មានព្រះកិត្តិយសទទួលបាននូវបុណ្យស័ក្តិនេះ មានន័យថាបរិសុទ្ធ ។[20]

ទោះបីព្រះនាង ហ្វាទ្វីម៉ាស់ ម៉ាក់ស៊្វម៉ាស់ رضي الله عنها បានចាប់បដិសន្ធិ ២៥ ឆ្នាំក្រោយអ៊ីមុាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام ក៏ដោយ ដែលព្រះអង្គទាំងពីរ عليهم السلام មានព្រះមាតាបិតាមួយ សឲ្យឃើញនូវសេចក្តីជិតស្និទ្ធរវាងព្រះអង្គទាំងពីរ عليهم السلام ។

## ១.៦ នាមនិងបុណ្យស័ក្តិរបស់ព្រះនាងហ្វាទ្វីម៉ាស់ ម៉ាក់ស៊្វម៉ាស់ سلام الله عليها ។

ហាឌីស្ហច្រើនបានបញ្ជាក់ថា ការជ្រើសរើសឈ្មោះដែលស័ក្តិសមនឹងកូនជាកាតព្វកិច្ចរបស់ឪពុក ។[21] បើជាកូនប្រុស គប្បីជ្រើសរើសយកព្រះនាមរបស់ព្រះ

[19] អ៊ូស៊្វល អាល់-កាហ្វី (أُصُول الْكَافِي) ក្បាលទី ១ ទំព័រ ៤៨៦ ។ អ៊ុយុន អាល់-អាក់បារ អាល់-រីដ្ហ៏ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ១ ទំព័រ ១៤ ។ អាក់ឡាំ អាល់-វ៉ារ៉ (اعلام الورى) ទំព័រ ៣០២ ។ អាល់-អៀរស្ហាដ់ (الإرشاد) ក្បាលទី ២ ទំព័រ ២៤៧ ។

[20] ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៩ ទំព័រ ៤ ។ អ៊ុយុន អាល់-អាក់បារ អាល់-រីដ្ហ៏ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ១ ទំព័រ ១៤ ។ អ៊ីស្ប៊ាត់ អាល់-ហ៊ូដាស់ (إثباتُ الهُداة) ក្បាលទី ៣ ទំព័រ ២៣៣ ។ មូហាំម៉ាដ់ រីដ្ហ៏ ហាគីមី (محمد رضا حكيمى), អាក់យ៉ាន់ អាល់-នីសាអ៊ុ ទំព័រ ៧៦ ។

សាស្តា ﷺ ឬព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام (មូហុាំម៉ាដ់ ឬ អុាលី)[22] ។ បើជាកូនស្រី ពុំមានឈ្មោះណាស័ក្តិសមជាងឈ្មោះហ្វាទីម៉ាស់ទេ[23] ។

ព្រះសន្តអ៊ីមុាំ عليهم السلام ព្រោះតែស្រឡាញ់និងគោរពព្រះនាងហ្វាទីម៉ាស់ ស្ហាស់រ៉អ៊ Ø سلام الله عليها (فَاطِمَة الزَّهْرَاء) ជាទីបំផុត ព្រះអង្គ عليهم السلام គោរពឈ្មោះ "ហ្វាទីម៉ាស់" ណាស់ ។ កាលសាវកម្នាក់បានប្រាប់ អ៊ីមុាំ អាល់-ស្វ៉ឌិក្វ صلوات الله عليه والسلام ថាលោកបានដាក់ឈ្មោះកូនស្រីលោកថា ហ្វាទីម៉ាស់ ព្រះអង្គ صلوات الله عليه والسلام បានបន្លឺសម្លេងខ្លាំងឡើងថា៖ "ពេលនេះលោកបានដាក់ឈ្មោះ ហ្វាទីម៉ាស់ ឲ្យកូនហើយ អំណឹះតទៅលោកត្រូវប្រយ័តមិនត្រូវជេរប្រទេចនាងដាច់ខាត មិនត្រូវវាយនាងដាច់ខាត ។"[24]

ដោយសារសេចក្តីគោរពនេះឯង បានជាព្រះសន្តអ៊ីមុាំ عليهم السلام បានដាក់ព្រះនាមថ្លៃថ្លាទាំងនេះឲ្យព្រះរាជបុត្រាបុត្រី ។ ការពិតកូនក្មេងច្រើនមានសំណាងដែលឪពុកម្តាយដាក់ឈ្មោះទាំងនេះឲ្យ ។ ជាពិសេសអ៊ីមុាំ អាល់-កាស្ហ៊ិម صلوات الله عليه والسلام ដែល

---

[21] ស្ហៃខ៏ មូហុាំម៉ាដ់ ប៊ិន យ៉ាក់គូប អាល់-គូឡៃនី (محمد بن يعقوب بن إسحاق الكليني) ហ្វ៊ុរុអ៊ អាល់-កាហ្វី (فروع الكافي) ក្បាលទី ៦ ទំព័រ ១៨ ។ ស្ហៃខ៏ ស្វ៉ឌុក្វ (الشيخ الصدوق) ម៉ាន់ ឡាយ៉ាស្ហ់ឌុរុះហ៊ុ អាល់-ហ្វាគ្វិះហ៊ុ (مَنْ لَا يَحْضُرُه ٱلْفَقِيه) ក្បាលទី ៤ ទំព័រ ២៦៩ ។ ស្ហៃខ៏ ទូស៊ី (الشيخ الطوسي) តាស្ហ់ស៊ីប អាល់-អាស្ហ់កាម (تَهْذِيب ٱلْأَحْكَام) ក្បាលទី ៧ ទំព័រ ៤៣៧ ។

[22] ស្ហៃខ៏ ទូស៊ី (الشيخ الطوسي), អាល់-អាម៉ាលី ក្បាលទី ២ ទំព័រ ៦៩ ។ ស្ហៃខ៏ ស្វ៉ឌុក្វ (الشيخ الصدوق) ម៉ាអុានី អាល់-អាក់បារ (مَعانِي الأخبار) ទំព័រ ១៤៦ ។ អ៊ូស្វ៊ូល អាល់-កាហ្វី (أُصُول اَلْكَافِي) ក្បាលទី ៦ ទំព័រ ១៩ ។ អ៊ុយូន អាល់-អាក់បារ អាល់-រីដ្ហ៊ (عُيُون أَخْبَار ٱلرِّضَا) ក្បាលទី ២ ទំព័រ ២៩ ។ ស្វ៉ហ៊ីហ្វាស់ អាល់-រីដ្ហ៊ (صحيفة الرضا) ចាត់ទុកជាវណ្ណកម្មរបស់អ៊ីមុាំ អាល់-រីដ្ហ៊ صلوات الله عليه والسلام ទំព័រ ៨៨ ។

[23] ហ្វ៊ុរុអ៊ អាល់-កាហ្វី (فروع الكافي) ក្បាលទី ៦ ទំព័រ ១៩ ។ តាស្ហ់ស៊ីប អាល់-អាស្ហ់កាម (تَهْذِيب ٱلْأَحْكَام) ក្បាលទី ៧ ទំព័រ ៤៣៨ ។

[24] ហ្វ៊ុរុអ៊ អាល់-កាហ្វី (فروع الكافي) ក្បាលទី ៦ ទំព័រ ៤៨ ។ តាស្ហ់ស៊ីប អាល់-អាស្ហ់កាម (تَهْذِيب ٱلْأَحْكَام) ក្បាលទី ៨ ទំព័រ ១១២ ។

បានដាក់ព្រះនាមហ្វាទីម៉ាស្ស់ឲ្យព្រះរាជបុត្រីប្អូនអង្គរបស់ព្រះអង្គ صلوات الله عليه والسلام ដូចដែលបានថាខាងលើមកហើយ ។ ដូច្នេះយើងដឹងថា ហ្វាទីម៉ាស្ស់ ម៉ាក់ស្ហ៊ូម៉ាស្ស់ سلام الله عليها គឺ ហ្វាទីម៉ាស្ស់ អាល់-គុបរ៉អ៊ុ ។

ព្រះរៀមព្រះនាង سلام الله عليها អ៊ីម៉ាំ អាល់-រីដ្ហ៊ំ صلوات الله عليه والسلام ជាអ្នកដាក់ព្រះនាមចំតើត (បុណ្យស័ក្តិឬឋានន្តរស័ក្តិ) "ម៉ាក់ស្ហ៊ូម៉ាស្ស់" ឲ្យព្រះនាង سلام الله عليها ។ គេពុំបានហៅព្រះនាង سلام الله عليها តាមព្រះនាមនេះទេកាលព្រះនាង سلام الله عليها នៅរស់ ។ ព្រះនាមតម្កើងនេះត្រូវបានដាក់ឲ្យព្រះនាង سلام الله عليها បន្ទាប់ពីព្រះនាង سلام الله عليها ចូលទិវង្គត ។ បានសេចក្តីថាចំណុចនេះធ្វើឲ្យមោឃៈមតិខុស ដែលថាព្រះនាង سلام الله عليها បានចូលទិវង្គតក្រោយព្រះរៀម صلوات الله عليه والسلام ព្រះនាង سلام الله عليها អ៊ីម៉ាំ អាល់-រីដ្ហ៊ំ صلوات الله عليه والسلام ។ លោក មៀរស្សា មូហ្ហាំម៉ាដ្ឌ់ តាគ្គី (الميرزا محمد تقي - កើត ១២១៦ ហ្ស.ស./១៨០២ គ.ស. ស្លាប់ ១២៩៧ ហ្ស.ស./១៨៨០ គ.ស.) បានឲ្យដឹងថាព្រះនាមតម្កើង "ម៉ាក់ស្ហ៊ូម៉ាស្ស់" ត្រូវព្រះរៀម صلوات الله عليه والسلام ព្រះនាង سلام الله عليها អ៊ីម៉ាំ អាល់-រីដ្ហ៊ំ صلوات الله عليه والسلام ដាក់ឲ្យព្រះនាង سلام الله عليها ។ យោលតាមហាឌីស្ស៍នេះ អ៊ីម៉ាំ អាល់-រីដ្ហ៊ំ صلوات الله عليه والسلام មានវចនៈថា៖

مَنْ زَارَ المَعْصُوْمَةَ بقم كَمَنْ زَارَنِيْ (رياحين الشريعة، ج١، ص٥٣٥ internet)

អ៊ីម៉ាំទី ៨ អាលី អាល់-រីដ្ហ៊ំ صلوات الله عليه والسلام មានវចនៈថា៖ "អ្នកណាទៅគោរពម៉ាក់ស្ហ៊ូម៉ាស្ស់ سلام الله عليها នៅឯគុំម ដូចអ្នកនោះទៅគោរពខ្ញុំ صلوات الله عليه والسلام ដែរ ។" (رياحين الشريعة 1: 535)[25]

ព្រះនាមចំតើត "ម៉ាក់ស្ហ៊ូម៉ាស្ស់" ដាក់ឲ្យព្រះនាង ហ្វាទីម៉ាស្ស់ سلام الله عليها បញ្ជាក់ថាព្រះនាង سلام الله عليها មានលក្ខណៈអរិរុទ្ធ (គឺគ្មានបាប) ទេ ? ក្នុងន័យផ្សេង តើព្រះនាង سلام الله عليها អរិរុទ្ធក្នុងន័យតែមួយនឹងម៉ាក់ស្ហ៊ូមីនទាំង ១៤ អង្គ عليهم السلام ទេ (គឺព្រះសាស្តា صلى الله عليه وآله وسلم, ហ្វាទីម៉ាស្ស់ ស្សាស្ស់រ៉អ៊ុ سلام الله عليها និងព្រះសន្តអ៊ីម៉ាំទាំង ១២ អង្គ سلام الله عليها) ? ព្រះអង្គទាំង ១៤ អង្គ سلام الله عليها ជាបុគ្គលគ្មានបាប ត្រូវអល់ឡោះហ៍ عز وجل ការពារ នៅក្នុងអាយ៉ាស្ស់បន្សុទ្ធ

[25] ណាស៊ីក្ហ អាល់-តាវ៉ារីក្ហ (ناسخ التواريخ) ក្បាលទី ៣ ទំព័រ ៦៨ ។ រ៉យ៉ាហ៊ីន អាល់-ស្សារីអាស្ស់ (رَياحين الشَريعَة) ក្បាលទី ៥ ទំព័រ ៣៥ ។

(آيَةُ اَلتَّطْهِيرِ) ថា៖

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

*[៣៣:៣៣] អល់ឡោះហ្វ៍គ្រាន់តែចង់ឲ្យពួកអ្នកចាកផុតពីមន្ទិល ជម្រះបន្សុទ្ធពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ រាជកុលដ្ឋាន[របស់សាស្ដា]អើយ ។*[26]

លោកអ្នកប្រាជ្ញច្រើននាក់ជឿថាអភិជនច្រើននាក់ ដែលជាព្រះរាជវង្សរបស់ព្រះសាស្ដាﷺ ដូចជាព្រះនាង ស្ហ៊ែណាប់سلام الله عليها, ហ្ជាដ្ហ៍រ៉ោះត្ហ៍ អ្ចប់បាស់رضي الله عنه និងព្រះនាង ហ្វាទិ៍ម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍سلام الله عليها ជាដើម ទទួលបាននូវលក្ខណៈបរិសុទ្ធខ្ពស់ ព្រោះតែជិតស្និទ្ធនឹងម៉ាក់ស៊្ហូមីនعليهم السلام ។

អវិរុទ្ធភាព (عِصْمَة) មានន័យពីរគឺ៖ អវិរុទ្ធភាពពីការប្រព្រឹត្តខុស (គឺពុំមានកំហុស ឬពុំធ្វើខុស) និងអវិរុទ្ធភាពពីបាប (គឺគ្មានបាប)។ ពេលគេនិយាយអំពីម៉ាក់ស៊្ហូមីនعليهم السلام បានសេចក្ដីថាមានន័យទាំងពីរនេះ។ តែពេលគេនិយាយអំពីបុគ្គលពិសេសនិងអភិជនដូចជាព្រះនាង ស្ហ៊ែណាប់سلام الله عليها, ហ្ជាដ្ហ៍រ៉ោះត្ហ៍ អ្ចប់បាស់ رضي الله عنه ឬព្រះនាង ហ្វាទិ៍ម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍سلام الله عليها ជាដើម បានសេចក្ដីថាមានន័យថាអវិរុទ្ធភាពពីបាប ។

យើងសូមស្លេះត្រឹមនេះ ។ តែព្រះសន្តអ៊ីម៉ាំعليهم السلامធ្លាប់តែលើកតម្កើងបុគ្គលដោយមានហេតុផល ។ ដែលអ៊ីម៉ាំ អាល់-រីដ្ហ៍صلوات الله عليه والسلام លើកតម្កើងព្រះរាជអនុជារបស់ព្រះអង្គصلوات الله عليه والسلامដោយបុណ្យស័ក្តិ "ម៉ាក់ស៊្ហូម៉ាស្ហ៍" នេះសឲ្យឃើញថាព្រះនាងسلام الله عليهاស័ក្តិសមនឹងបុណ្យស័ក្តិនេះ ។

ការ៉ម៉ាស្ហ៍ អាស្ហ៍ឡាល់-បៃត៍ (كرامة أهل البيت) នេះគឺព្រះរាជឋានន្តរស័ក្តិ "នារីថ្លៃថ្លានៃព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្ដាﷺ" ដែលអ៊ីម៉ាំ អាល់-បាក្វៀរصلوات الله عليه والسلام ឬ

---

[26] ព្រះគម្ពីរគួរអាន [៣៣:៣៣] ។

អ៊ីម៉ាំ អាល់-ស្វ័ឌិក្ក صلوات الله عليه والسلام ដាក់ឲ្យព្រះនាង سلام الله عليها ដែល អាយ៉ាទុលឡោះហ៍ សៃយីដ្ឋ ម៉ាស៊ូមូដ្ឋ ម៉ារអាស៊ី ណាយ៉ាហ្វី អ្នកនិពន្ធសាត្រា "ម៉ាស៊ូយ៉ីរ៉ត អាល់-អារ៉ុឡាវីយីន" បានសុបិនឃើញ ។

អភិជនរូបនេះបានចាប់អារម្មណ៍នឹងការស្វែងរកកន្លែងពិត ដែលគេបានបញ្ចុះព្រះរាជសពរបស់ព្រះនាង ហ្វាទីម៉ាស៊ូ ស្ហាស៊ូរ៉ាអ៊ុ سلام الله عليها ។ ដើម្បីបំពេញគោលដៅនេះ លោកបានបួងសួងអល់ឡោះហ៍ عز وجل ៤០ ថ្ងៃទាល់តែបានទទួលចម្លើយ ។

យប់ទី ៤០ ក្រោយពីបានស្វ័ឡាត់រួច លោកបានទទួលទានដំណេក ហើយបានសុបិនឃើញខ្លួនលោកនៅឯព្រះចេតិយរបស់អ៊ីម៉ាំ អាល់-បាក្កៀរ صلوات الله عليه والسلام ឬ អ៊ីម៉ាំ អាល់-ស្វ័ឌិក្ក صلوات الله عليه والسلام (អ៊ីម៉ាំទាំងពីរអង្គ عليهم السلام ត្រូវបញ្ចុះព្រះរាជសពនៅ អាល់-បាគ្គី នគរ ម៉ាឌីណាស៊ូ) ។ អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់លោកថា៖

عَلَيْكَ بِكَرِيمَةِ اَهْلِ الْبَيْتِ

ខ្ញុំ صلوات الله عليه والسلام សូមណែនាំលោក លោកគប្បីទៅឯ ការីម៉ាស៊ូ អាស៊ូល់លុល-បៃត៍ عليهم السلام ។

លោកគិតថាដែលអ៊ីម៉ាំ صلوات الله عليه والسلام ថា ការីម៉ាស៊ូ អាស៊ូល់លុល-បៃត៍ عليهم السلام នោះ ព្រះអង្គ صلوات الله عليه والسلام ចង់និយាយអំពីព្រះនាង ហ្វាទីម៉ាស៊ូ ស្ហាស៊ូរ៉ាអ៊ុ سلام الله عليها ។ លោកក៏បានតបថា៖ "ក្រាបទូល ។ ទូលបង្គំបានបួងសួងសូមដូច្នេះ ដើម្បីដឹងកន្លែងពិតដែលគេបានបញ្ចុះព្រះរាជសពមហាស្ត្រីអង្គនេះ سلام الله عليها ទូលបង្គំនឹងអាចស៊ុីរ៉ាស៊ូព្រះនាង سلام الله عليها ។" អ៊ីម៉ាំ صلوات الله عليه والسلام បានតបថា៖ "ខ្ញុំ صلوات الله عليه والسلام ចង់និយាយថាព្រះចេតិយរបស់ព្រះនាង ហ្វាទីម៉ាស៊ូ ម៉ាក់ស៊ូម៉ាស៊ូ سلام الله عليها នៅឯគុម ។" ហើយអ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈបន្ថែមថា៖ "ដែលព្រះចេតិយរបស់ព្រះនាង ហ្វាទីម៉ាស៊ូ ស្ហាស៊ូរ៉ាអ៊ុ سلام الله عليها កំបាំងពីភ្នែកមនុស្សនោះព្រោះអល់ឡោះហ៍ عز وجل ចង់ដូច្នេះ ។" ដូច្នេះអ៊ីម៉ាំ صلوات الله عليه والسلام បានដាក់ព្រះចេតិយព្រះនាង ហ្វាទីម៉ាស៊ូ ម៉ាក់ស៊ូម៉ាស៊ូ سلام الله عليها ជំនួសព្រះចេតិយព្រះនាង ហ្វាទីម៉ាស៊ូ ស្ហាស៊ូរ៉ាអ៊ុ سلام الله عليها ឯព្រះកិត្តិយសនិងសេចក្តីរុងរឿងដែលបានមកលើព្រះចេតិយព្រះនាង ហ្វាទីម៉ាស៊ូ ស្ហាស៊ូរ៉ាអ៊ុ سلام الله عليها ក៏ត្រូវបានទៅលើព្រះចេតិយព្រះនាង ហ្វាទីម៉ាស៊ូ

ម៉ាក់ស៊ូម៉ាស់ سلام الله عليها ដែរ ។

ពេលភ្ញាក់ពីដំណេក អាយ៉ាទុលឡោះហ៍ សៃយ៉ីដ្ឋ ម៉ាស់អ៊ូដ្ឋ ម៉ារអ្ហាស៊ី ណាយ៉ាហ្វី ប៉ងធ្វើដំណើរទៅកាន់ខេត្តគុមជាមួយក្រុមគ្រួសារលោកដើម្បីសម្តែងសេចក្តីគោរព (ស៊ីរ៉ាស់) ចំពោះព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ។ លោកប៉ងបំពេញបំណងនេះភ្លាមៗ ។[27] លោកបានទទួលអនិច្ចកម្មនៅខេត្តណាយ៉ាហ្វ ក្នុងឆ្នាំ ១៣៣៨ សករាជហ៊ីជ្រ៉ោះត៍ (ឆ្នាំសាកល ១៩២០) ។

លោក អាយ៉ាទុលឡោះហ៍ សៃយ៉ីដ្ឋ ស្ហាហ្វាប់ អាល់-ឌីន ម៉ារអ្ហាស៊ី ណាយ៉ាហ្វី កូនប្រុសដ៏ល្បីរបស់ត្រកូល ម៉ារអ្ហាស៊ី បានភៀសខ្លួនទៅកាន់ប្រទេសអ៊ីរ៉ង់ឆ្នាំ ១៣៤២ សករាជហ៊ីជ្រ៉ោះត៍ (ឆ្នាំសាកល ១៩២៤) ។ លោកបាននិយាយច្រើនលើកថាមូលហេតុដែលលោកភៀសខ្លួនមកប្រទេសអ៊ីរ៉ង់ គឺសុបិនរបស់បិតាលោក ។

បន្ទាប់ពីបានស្នាក់នៅខេត្ត តេហេរ៉ង់ មួយរយៈពេលខ្លី លោកបានចូលបម្រើសិក្ខាសាលាខេត្តគុម អាល់-ហៅស្ហាស់ អាល់-អ៊ីលមីយ៉ាស់ (الحوزة العلمية) ឆ្នាំ ១៣៤៣ សករាជហ៊ីជ្រ៉ោះត៍ (ឆ្នាំសាកល ១៩២៥) ។ លោកបានរស់នៅក្បែរការីម៉ាស់ អាស្ហលុល-បៃត៍ عليهم السلام ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها លុះទទួលអនិច្ចកម្មក្នុងឆ្នាំ ១៤១១ សករាជហ៊ីជ្រ៉ោះត៍ (ឆ្នាំសាកល ១៩៩១) ។ ជាង ៦០ ឆ្នាំ លោក ស្ហាហ្វាប់ អាល់-ឌីន ម៉ារអ្ហាស៊ី ជាបុគ្គលដំបូងបង្អស់ដែលទៅសម្តែងសេចក្តីគោរព (ស៊ីរ៉ាស់) មហាស្ត្រីអង្គនេះ عليهم السلام ។ លោកតែងតែរង់ចាំខាងក្រៅព្រះចេតិយមុនគេបើកទ្វារឲ្យចូល ។ ទោះបីពេលលោកមានជម្ងឺធ្ងន់មុនទទួលអនិច្ចកម្មក៏ដោយ លោកបានឲ្យគេសែងលោកទៅទីនេះដើម្បីគោរពព្រះនាង سلام الله عليها ។

[27] ស៊ីនដ្ហាកានី ការីម៉ាស់ អាស្ហលុល-បៃត៍ عليهم السلام (زندگانی کریمه اهل بیت) ទំព័រ ៥៥ ។

គេបានហៅព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្វូម៉ាស្ញ់ سلام الله عليها ដោយឈ្មោះច្រើនទៀតគឺ៖
១.ត្ហ៊ីរ៉ោះត្ញ៉ (اَلطَّاهِرَة)
២.ហ៊ាមីដ្ញាស្ញ់ (اَلْحَمِيدَة)
៣.បាររ៉ោះត្ញ៉ (اَلْبَرَّة)
៤.រ៉ស្ញ៊ីដ្ញាស្ញ់ (اَلرَّشِيدَة)
៥.តាគ្វីយ៉ាស្ញ់ (اَلتَّقِيَّة)
៦.ណាគ្វីយ៉ាស្ញ់ (اَلنَّقِيَّة)
៧.រ៉ឌ្វីយ៉ាស្ញ់ (اَلرَّضِيَّةُ)
៨.ម៉ារឌ្វីយ៉ាស្ញ់ (اَلْمَرْضِيَّةُ)
៩.សៃយីដ្ញាស្ញ់ (سَيِّدَةَ)
១០.អ៊ុក្ត៍ អាល់-រីឌ្វ៍ (أخت الرضا)

នាមទាំងអស់នេះមាននៅក្នុងឌុអាអ៍ ស៊ីយ៉ារ៉ោះត្ញ៉ រាយការណ៍ដោយស្ញៃខ៍ មូហ៊ាំម៉ាដ្ញ់ អាលី អាល់-គូមមី នៅក្នុងសាត្រារបស់លោក អាន់វ៉ារ អាល់-មូស្ញាក់ស្ញាអ៊ីន ។ វន្ទនាការចំពោះព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្វូម៉ាស្ញ់ سلام الله عليها នេះផ្សេងពីសាត្រាមួយទៀតដែលល្បីល្បាញជាង កត់ត្រាទុកដោយអាឡាម៉ាស្ញ់ ម៉ាជ្លីស៊ី (العلامة المجلسي) មកពីអ៊ីម៉ាំ អាល់-រីឌ្វ៍ صلوات الله عليه والسلام ។

# ១.៧ បារមីព្រះនាងហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្វូម៉ាស្ញ់ سلام الله عليها ។

នៅក្នុងវន្ទនាការព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្វូម៉ាស្ញ់ سلام الله عليها រាយការណ៍មកពីអ៊ីម៉ាំ អាល់-រីឌ្វ៍ صلوات الله عليه والسلام គេឃើញមានចារថា៖

وَ أَنْ لاَ يَسْلُبَنَا مَعْرِفَتَكُمْ إِنَّهُ وَلِيٌّ قَدِيرٌ

"[អស់ទូលបង្គំសូមអស់ឡោះហ៍عزّ وجلّ] កុំឲ្យអស់ទូលបង្គំពុំបានស្គាល់[បារមី]ព្រះនាងسلام الله عليها ។ ការពិតព្រះអង្គعزّ وجلّជាអ្នកការពារ ព្រះអង្គعزّ وجلّមានសព្វានុភាពលើសព្វសារពើ ។"

នៅក្នុងវគ្គនេះ យើងនឹងស្វែងយល់អំពីបារមីខ្ពង់ខ្ពស់របស់ព្រះនាងមហាស្ត្រីអង្គនេះسلام الله عليها ។ សេចក្ដីរាយការណ៍មួយចំនួនស្ដីអំពីរឿងនេះមានដូចតទៅ ។

១. សេចក្ដីរាយការណ៍មកពីអ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام បានឲ្យដឹងថា៖

مَنْ زَارَ الْمَعْصُوْمَةَ بقم كَمَنْ زَارَنِيْ (رياحين الشريعة، ج١، ص٥٣٥ internet)

អ៊ីម៉ាំទី ៨ អាលី អាល់-រីដ្ឋ៏صلوات الله عليه والسلام មានវចនៈថា៖ "អ្នកណាទៅគោរពម៉ាក់ស៊្ហូម៉ាស៊្ហូسلام الله عليهاនៅឯគុំម ដូចអ្នកនោះទៅគោរពខ្ញុំصلوات الله عليه والسلامដែរ ។" (رياحين الشريعة 1: 535)[28]

ហាឌីស្សនេះសឲ្យឃើញថា រង្វាន់និងគុណបុណ្យដែលបានមកពីការទៅសម្ដែងសេចក្ដីគោរពចំពោះព្រះនាង ហ្វាទីម៉ាស៊្ហូ ម៉ាក់ស៊្ហូម៉ាស៊្ហូسلام الله عليها ឬ អ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام រង្វាន់និងគុណបុណ្យនោះដូចគ្នាសម្រាប់អ្នកដែលទៅសម្ដែងសេចក្ដីគោរព ។

២. សេចក្ដីរាយការណ៍មកពីអ៊ីម៉ាំ អាល់-ស្វ៉ឌិក្ហصلوات الله عليه والسلام បានឲ្យដឹងថា៖

وَ سَتُدْفَنُ فِيهَا اِمْرَأَةٌ مِنْ أَوْلاَدِي تُسَمَّى فَاطِمَةَ، فَمَنْ زَارَهَا وَجَبَتْ لَهُ اَلْجَنَّةُ. (بحار الأنوار ج٥٧ ص٢١٦ internet)

"មហាស្ត្រីមួយអង្គក្នុងបណ្ដាកូនចៅខ្ញុំصلوات الله عليه والسلامឈ្មោះ ហ្វាទីម៉ាស៊្ហូ នឹងត្រូវបញ្ចុះសាកសពនៅឯគុំម ។ អ្នកណាទៅគោរព[ព្រះចេតិយ]ព្រះនាងسلام الله عليها អ្នកនោះត្រូវ

[28] ណាស៊ីក្ហ អាល់-តាវ៉ារីក្ហ (ناسخ التواريخ) ក្បាលទី ៣ ទំព័រ ៦៨ ។ រ៉យ៉ាហ៊ីន អាល់-ស្ហារីអាស់ (رَياحين الشَريعَة) ក្បាលទី ៥ ទំព័រ ៣៥ ។

តែបានចូលឋានសួគ៌ ។ (بحار الأنوار 57: 216)[29]

សេចក្តីរាយការណ៍នេះ ក៏ឆ្លុះបញ្ចាំងនូវបុណ្យបារមីរបស់មហាស្ត្រីអង្គនេះ سلام الله عليها ដែរ ។

៣. សេចក្តីរាយការណ៍ពិតមួយទៀត មកពីអ៊ីមុាំ អាល់-ស្វ៉ាឌិក្វ صلوات الله عليه والسلام បានឲ្យដឹងថា៖

تُقْبَضُ فِيهَا اِمْرَأَةٌ مِنْ وُلْدِي، اِسْمُهَا فَاطِمَةُ بِنْتُ مُوسَى، وَ تُدْخَلُ بِشَفَاعَتِهَا شِيعَتِي اَلْجَنَّةَ بِأَجْمَعِهِمْ. (بحار الأنوار ج٥٧ ص٢٢٨ internet)

"មហាស្ត្រីមួយអង្គក្នុងបណ្តាកូនចៅខ្ញុំ صلوات الله عليه والسلام ឈ្មោះ ហ្វាទ្វីម៉ាស្វ រាជបុត្រីរបស់មូសា صلوات الله عليه والسلام នឹងអស់ជីវិតនៅឯគួម ។ ថ្ងៃជំនុំជម្រះ មហាស្ត្រីនេះនឹងធ្វើអន្តរាគមន៍ឲ្យស្ស៊ីអ៊ាស្វទាំងអស់របស់ខ្ញុំ صلوات الله عليه والسلام បានចូលឋានសួគ៌ ។" (بحار الأنوار 8: 228)[30]

សេចក្តីរាយការណ៍នេះបង្ហាញឲ្យឃើញកិត្តិយស និងឋានៈឯករបស់ព្រះនាង ហ្វាទ្វីម៉ាស្វ ម៉ាក់ស៊្វូម៉ាស្វ سلام الله عليها ព្រោះព្រះនាង سلام الله عليها ជាមធ្យោបាយធ្វើអន្តរាគមន៍របស់ស្ស៊ីអ៊ាស្វ អាស្វលុល-បៃត៍ عليهم السلام ថ្ងៃជំនុំជម្រះ ។ ទោះបីហាឌីស្សច្រើនទៀតចែងថាមនុស្សនឹងបានចូលឋានសួគ៌ដោយសារអន្តរាគមន៍របស់វិញ្ញូ និងទុក្ករបុគ្គលក៏ដោយ តែនារីអរិរុទ្ធគ្មានបាបមួយអង្គក៏នៅក្នុងបណ្តាអ្នកធ្វើអន្តរាគមន៍ឲ្យគេទាំងពីរប្រភេទនេះដែរ គឺព្រះនាង ហ្វាទ្វីម៉ាស្វ ម៉ាក់ស៊្វូម៉ាស្វ سلام الله عليها ។

[29] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ៣១៧, ក្បាលទី ៦០ ទំព័រ ២១៦, ក្បាលទី ១០២ ទំព័រ២៦៦ ។

[30] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២២៨ ។ ម៉ាយ៉្ហាលីស អាល់-មុមីន (مجالس المؤمنين) ក្បាលទី ១ ទំព័រ ៨៣ ។

៤. ឌូអាអ៍ ស៊ីយ៉ារ៉ោះត៍ ព្រះនាង ហ្វាទីម៉ាស្ទ ម៉ាក់ស៊្វូម៉ាស្ទ سلام الله عليها នៅក្នុងដៃយើងពេលនេះមកពីអ៊ីម៉ាំ អាល់-រីដ្ហ៏ صلوات الله عليه والسلام ។ អ្វីដែលគួរចាប់អារម្មណ៍គឺអ៊ីម៉ាំច្រើនអង្គ عليهم السلام បានបង្គាប់ឲ្យកត់ត្រាទុកពាក្យពេចន៍ និងរបៀបធ្វើវន្ទនាការព្រះនាង ហ្វាទីម៉ាស្ទ ស្ហាស្ទរ៉អ៍ سلام الله عليها និងព្រះនាង ហ្វាទីម៉ាស្ទ ម៉ាក់ស៊្វូម៉ាស្ទ سلام الله عليها ។

ម្យ៉ាងទៀត ព្រោះតែយើងដឹងថាអ៊ីម៉ាំ صلوات الله عليه والسلام ជាអ្នកប្រាប់ ឌូអាអ៍ ស៊ីយ៉ារ៉ោះត៍ នេះតាមរយៈសេចក្ដីរាយការណ៍គួរឲ្យទុកចិត្តបាន បានសេចក្ដីថាគុណសម្បត្តិព្រះនាង ហ្វាទីម៉ាស្ទ ម៉ាក់ស៊្វូម៉ាស្ទ سلام الله عليها មិនក្លែងក្លាយទេ ។

យើងសូមលើកយក ឌូអាអ៍ ស៊ីយ៉ារ៉ោះត៍ ព្រះនាង ហ្វាទីម៉ាស្ទ ម៉ាក់ស៊្វូម៉ាស្ទ سلام الله عليها ខ្លីៗមកវិភាគជាគំរូ ។ នៅក្នុង ឌូអាអ៍ ស៊ីយ៉ារ៉ោះត៍ នេះគេហៅឈ្មោះព្រះនាង سلام الله عليها ថា៖

-ព្រះរាជបុត្រីរបស់រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم ។

-ព្រះរាជបុត្រីរបស់ហ្វាទីម៉ាស្ទ سلام الله عليها និងខ៏ឌីយ៉ាស្ទ سلام الله عليها ។

-ព្រះរាជបុត្រីរបស់ព្រះរាជអគ្គមហាប្រមុខ (អាលី صلوات الله عليه والسلام) របស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា ។

-ព្រះរាជបុត្រីរបស់ អាល់-ហាសាន់ صلوات الله عليه والسلام និង អាល់-ហ៊ូសែន៍ صلوات الله عليه والسلام ។

-ព្រះរាជបុត្រីរបស់ព្រះអភិបាលរបស់អល់ឡោះហ៍ عز وجل (អាល់-កាស្ហ៊ីម صلوات الله عليه والسلام) ។

-ព្រះរាជអនុជារបស់ព្រះឧបរាជរបស់អល់ឡោះហ៍ عز وجل (អាល់-រីដ្ហ៏ صلوات الله عليه والسلام) ។

-ព្រះបិតុលានីរបស់ព្រះឧបរាជរបស់អល់ឡោះហ៍ عز وجل (អាល់-យ៉ាវ៉ាដ្ទ صلوات الله عليه والسلام) ។

ស៊ីយ៉ារ៉ោះត៍សង្ខេបខាងលើនេះមានដូចតទៅគឺ៖

| | |
|---|---|
| សូមព្រះសិរីសួស្ដីកើតមានដល់ព្រះនាង ព្រះរាជបុត្រីរបស់រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم អើយ ! | السَّلَامُ عَلَيْكِ يَا بِنْتَ رَسُولِ اللَّهِ |

السَّلَامُ عَلَيْكِ يَا بِنْتَ فَاطِمَةَ وَ خَدِيجَةَ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះរាជបុត្រីរបស់ហ្វាទិម៉ាស់ سلام الله عليها និង ខ៉ូឌីយ៉ាស់ سلام الله عليها អើយ !

السَّلَامُ عَلَيْكِ يَا بِنْتَ أَمِيرِ الْمُؤْمِنِينَ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះរាជបុត្រីរបស់ព្រះរាជអគ្គមហាប្រមុខ (អ៊ាលី صلوات الله عليه والسلام) របស់បណ្តាអ្នកមានសទ្ធាជ្រះថ្លាអើយ !

السَّلَامُ عَلَيْكِ يَا بِنْتَ الْحَسَنِ وَ الْحُسَيْنِ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះរាជបុត្រីរបស់ អាល់-ហ៊ាសាន់ صلوات الله عليه والسلام និង អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ។

السَّلَامُ عَلَيْكِ يَا بِنْتَ وَلِيِّ اللَّهِ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះរាជបុត្រីរបស់ព្រះឧបរាជរបស់ អល់ឡោះហ៍ عز وجل (អាល់-កាស៊ីម صلوات الله عليه والسلام) ។

السَّلَامُ عَلَيْكِ يَا أُخْتَ وَلِيِّ اللَّهِ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះរាជអនុជារបស់ព្រះឧបរាជរបស់ អល់ឡោះហ៍ عز وجل (អាល់-រីដ្ហ៍ صلوات الله عليه والسلام) ។

السَّلَامُ عَلَيْكِ يَا عَمَّةَ وَلِيِّ اللَّهِ

សូមព្រះសិរីសួស្តីកើតមានដល់ព្រះនាង ព្រះបិតុលានីរបស់ព្រះឧបរាជរបស់ អល់ឡោះហ៍ عز وجل (អាល់-យ៉ាវ៉ាដ្ជ) ។

ទំនាក់ទំនងខាងលើនេះរបស់ ហ្វាទិម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها សឲ្យឃើញជាភ័ស្តុតាងថាមហាស្ត្រីថ្លៃថ្លាអង្គនេះមកពីព្រះរាជវង្សថ្លៃថ្នូរ ។ អភិជនភាពព្រះនាងមកពីព្រះសាច់សាលោហិតព្រះសាស្តា صلى الله عليه وآله وسلم ព្រះនាង ខ៉ូឌីយ៉ាស់ سلام الله عليها ព្រះនាង ហ្វាទិម៉ាស់ ស៊ាស្ស៊រ៉អ៊ុ سلام الله عليها និងព្រះសន្តអ៊ីម៉ាំបរិសុទ្ធ عليهم السلام ។

នៅក្នុងស៊ីយ៉ារ៉ោះត្ត៍នេះ អ៊ីម៉ាំ អាល់-រីដ្ហ៍ صلوات الله عليه والسلام ឲ្យយើងបែរទៅរកព្រះនាង سلام الله عليها ក្នុង

ការជួយធ្វើអន្តរាគមន៍ ។ ព្រះអង្គ صلوات الله عليه والسلام ផ្ដាំល់បានអង្វរព្រះនាង سلام الله عليها សូមឲ្យជួយអង្វរអល់ឡោះហ៍ عز وجل ឲ្យព្រះអង្គ صلوات الله عليه والسلام ព្រោះព្រះនាង سلام الله عليها ជាបុគ្គលជំនិតដែលមានឋានៈពិសេសសម្រាប់អល់ឡោះហ៍ عز وجل ថា៖

يَا فَاطِمَةُ اشْفَعِي لِي فِي الْجَنَّةِ فَإِنَّ لَكِ عِنْدَ اللَّهِ شَأْناً مِنَ الشَّأْنِ

"ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها អើយ ! សូមព្រះនាង سلام الله عليها ជួយធ្វើអន្តរាគមន៍ឲ្យទូលបង្គំ صلوات الله عليه والسلام បានចូលឋានសួគ៌ផង ព្រោះព្រះនាង سلام الله عليها មានបុណ្យបារមីខ្ពង់ខ្ពស់សម្រាប់អល់ឡោះហ៍ عز وجل ។"[31]

ការជួយធ្វើអន្តរាគមន៍របស់អភិនារីអង្គនេះឲ្យយើងបានចូលឋានសួគ៌ ខាងលើនេះមានចែងនៅក្នុងពាក្យពេចន៍វចនៈពិតរបស់អ៊ីម៉ាំ អាល់-ស្វ៉ឌិក្វ صلوات الله عليه والسلام និងនៅក្នុងវន្ទនាការបង្រៀនដោយអ៊ីម៉ាំ អាល់-រីដ្ហ៍ صلوات الله عليه والسلام ។[32]

[31] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ១០២ ទំព័រ ២៦៧ ។

[32] លោកអ្នកប្រាជ្ញខ្លះបានអធិប្បាយរឿងនេះដែរ ។ អាយ៉ាទុលឡោះហ៍ មូហ្ាំម៉ាដ់ បាគ្គីណាស្ទីរី (محمد باقر الناصري - អនិច្ចកម្មឆ្នាំ ១៤០៧ សករាជហ៊ីជ្រ៉េះត៍) បានរាយការណ៍ថា៖ "ឆ្នាំ ១២៩៥ សករាជហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ១៨៧៨) មានការអត់ឃ្លាននិងរាំងភ្លៀង ធ្វើឲ្យសត្វចិញ្ចឹមស្លាប់ ។ គេបានជ្រើសរើសអ្នកមានសទ្ធាស៊ប់ចិត្ត ៤០ នាក់ ឲ្យទៅធ្វើនមស្ការនៅឯហ្ការ៉មព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها ដើម្បីសូមជំនួយឲ្យរួចផុតពីមហន្តរាយនេះ ។ បណ្ដាអ្នកមានសទ្ធាស៊ប់ចិត្តទាំង ៤០ នាក់នោះក៏បានធ្វើនមស្ការនៅក្នុងព្រះបូជនីយចេតិយ ៣ ថ្ងៃ ៣ យប់ ។ យប់ទី ៣ ម្នាក់ក្នុងបណ្ដាបុគ្គលទាំង ៤០ នាក់នោះបានយល់សប្ដិឃើញអាយ៉ាទុលឡោះហ៍ មៀរស៊ា គុម្មី ដែលបានអនិច្ចកម្មទៅហើយ ។ អាយ៉ាទុលឡោះហ៍ មៀរស៊ា បានសួរបុគ្គលនេះថា៖ "តើពួកគេចង់បានអ្វី ?" គាត់បានតបថាពួកធ្វើនមស្ការសូមឲ្យមានភ្លៀងធ្លាក់ដើម្បីនឹងចាកផុតពីទុក្ខលំបាកដែលពួកគេកំពុងជួបប្រទះ ។ អាយ៉ាទុលឡោះហ៍ មៀរស៊ា មានប្រសាសន៍ថា៖ "អស់លោកប្រជុំគ្នានៅទីនេះអំពីរឿងប៉ុននេះឬ ? នេះជារឿងតូចតាចទេ ។ ខ្ញុំអាចដោះស្រាយបញ្ហានេះបាន ។ បើអស់លោកត្រូវការដោះស្រាយបែបនេះ សូមមករកយើង តែបើអស់លោកត្រូវការជំនួយអន្តរាគមន៍ក្នុងថ្ងៃជំនុំជម្រះ សូមអង្វរសូមព្រះនាង

គុណសម្បត្តិថ្លៃថ្លាមួយដែលគេដាក់ឲ្យព្រះនាង ហ្វាទីម៉ាស់ ស្ហាស់រ៉អ៊ែ سلام الله عليها នោះគឺព្រះសាស្តា صلى الله عليه وآله وسلم ព្រះបិតា صلى الله عليه وآله وسلم ព្រះនាង سلام الله عليها ធ្លាប់មានព្រះវចនៈថា៖

فِدَاهَا اَبُوهَا

"សូមឲ្យព្រះបិតា صلى الله عليه وآله وسلم ព្រះនាង سلام الله عليها បានធ្វើពលីកម្មដើម្បីព្រះនាង سلام الله عليها ។"[33]

អ៊ីមុាំ អាល់-កាស៊ីម صلوات الله عليه والسلام ក៏បានប្រើមួយឃ្លានេះដែរសម្រាប់ព្រះរាជបុត្រីព្រះអង្គ صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ។[34]

ពាក្យពេចន៍នេះពោរពេញដោយកិត្តិយស ពីព្រោះ៖

-គេប្រៀបឋានៈព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها នឹងឋានៈព្រះនាង ហ្វាទីម៉ាស់ ស្ហាស់រ៉អ៊ែ سلام الله عليها ពីព្រោះវាជាពាក្យពេចន៍តែមួយដែលព្រះសាស្តា صلى الله عليه وآله وسلم បានប្រើ ។

-ពាក្យពេចន៍នេះចេញមកពីមាត់អ៊ីមុាំ صلوات الله عليه والسلام តែម្តង សឲ្យឃើញថាឋានៈរបស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها កាន់តែមានលក្ខណៈលេចត្រដែតខ្ពស់ឡើង ។

ព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها មានលក្ខណៈស្មើនឹងព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ស្ហាស់រ៉អ៊ែ سلام الله عليها ។[35]

---

ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ។" (មូហាំម៉ាដ់ មូហាំម៉ាឌី អ៊ីស្ទីហារឌី (محمد محمدی اشتهاردی), ហាដ់រ៉ត់ ម៉ាក់ស៊ូម៉ាស់ ហ្វាទីម៉ាស់ ឌូវូម (حضرت معصومه فاطمه دوم) ទំព័រ ១៧៨ និង ១៧៩) ។

[33] ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៣ ទំព័រ ៨៦-៨៨ ។

[34] ស៊ីនដ្វាកានី ការីម៉ាស់ អាស់លុល-បៃត៍ عليهم السلام (زندگانی کریمه اهل بیت) ទំព័រ ៦៣ និង ៦៤ ។ មើល វគ្គ ១.១០ ។

[35] ដូចដែលបានអធិប្បាយរួចមកហើយនៅក្នុងវគ្គ ១.៦ ខាងលើ រឿងនេះត្រូវបាន

បុរសពីរនាក់បានមកបញ្ចុះព្រះរាជសពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ (سلام الله عليها) ។ ពុំមានអ្នកណាបានឃើញមុខច្បាស់របស់បុរសទាំងនេះទេ ។ យោលតាមហ្វាឌីស្ហ បុរសទាំងពីរនាក់នេះគឺអ៊ីម៉ាំ អាល់-រីដ្ហ (صلوات الله عليه والسلام) និងអ៊ីម៉ាំ អាល់-តាគ្គី (صلوات الله عليه والسلام) ។[36]

មានតែបុគ្គលអរិរុទ្ធទេដែលអាចកប់សពបុគ្គលអរិរុទ្ធបាន ។ ព្រឹត្តិការណ៍នេះមិនមែនជាភ័ស្តុតាងប្រកែកមិនបានថាព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ (سلام الله عليها) ជាអរិរុទ្ធបុគ្គលនោះទេ ព្រោះអ៊ីម៉ាំ (صلوات الله عليه والسلام) បានចូលរួមក្នុងពិធីបញ្ចុះសពរបស់សាវកព្រះអង្គ (صلوات الله عليه والسلام) ច្រើនរូប ។ ក៏ប៉ុន្តែ ដែលអ៊ីម៉ាំ (صلوات الله عليه والسلام) មកពីឆ្ងាយដើម្បីទទួលខុសត្រូវពិធីបុណ្យសពនោះ សឲ្យឃើញថាឋានៈព្រះនាង (سلام الله عليها) មានលក្ខណៈខ្ពង់ខ្ពស់ ។

ពាក្យពេចន៍ច្រើនរបស់អ៊ីម៉ាំ (عليهم السلام) ស្តីអំពីលក្ខណៈស័ក្តិសិទ្ធិរបស់ខេត្តគ្គុម ដោយសារតែព្រះរាជសពអភិនារីអង្គនេះត្រូវបញ្ចុះទីនេះ ។ ពុំមានទេនូវកន្លែងណាមួយដែលមានតម្កល់សពស្ត្រីដែលបានទទួលងារម៉ាក់ស៊ូម៉ាស់ ក្រៅពីកន្លែងនេះដែលគេនឹករលឹកឥតដាច់ ។

ហេតុការណ៍អស្ចារ្យច្រើនធ្លាប់បាននិយាយដោយមនុស្សផ្សេងៗ ច្រើនជំនាន់មកហើយ ។ អព្ភូតហេតុទាំងនោះមិនដែលកើតឡើងទេនៅទីណាដែលពុំមានព្រះចេតិយព្រះសាស្តា (عليه السلام) ឬអ៊ីម៉ាំ (صلوات الله عليه والسلام) លើកលែងតែចេតិយរបស់មហាបុរស

---

រាយការណ៍ប្រាប់អាយ៉ាទុល្លឡោះហ្វ៍ សៃយីដ្ហ ម៉ាស៊ូមូដ្ហ ម៉ារអ្ហាស៊ី ណាយ៉ាហ្វី ដែលបានទទួលអនិច្ចកម្មហើយ នៅក្នុងសុបិនដោយអ៊ីម៉ាំ អាល់-បាគៀរ (صلوات الله عليه والسلام) ឬអ៊ីម៉ាំ អាល់-ស្វាឌិក (صلوات الله عليه والسلام) បន្ទាប់អាយ៉ាទុល្លឡោះហ្វ៍ទទួចសូមក្នុងការស្វែងរកព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ស្ហាស្វ៉រអ៊ុ (سلام الله عليها) ។

[36] ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ២៩០ ។ មើល វគ្គ ២.៤ ។

អ៊ុប់បាស់عليه السلام នៅឯ ការបាឡាអ៊ុំ និងមហាស្រ្តី ស៊ុំណាប់سلام الله عليها នៅឯខេត្ត ដ្វាម៉ាស់ ។

ពាក្យពេចន៍ (ហ្ទាឌីស្ទ) ពិតថ្លែងដោយអភិនារីអង្គនេះបង្ហាញឲ្យឃើញនូវចំណេះវិជ្ជាខ្ពស់របស់ព្រះនាងវិស័យវិទ្យាសាស្រ្តអ៊ីស្លាមច្រើនមុខ  វិស័យព្រះធម៌របស់ព្រះនាងនិងគុណសម្បត្តិរបស់ព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាﷺ បូករួមនឹងគុណសម្បត្តិច្រើនទៀតរបស់ព្រះនាង ។

## ១.៨ មូលហេតុព្រះនាង ហ្វាទ្វីម៉ាស្ញ់ ម៉ាក់ស្ញូម៉ាស្ញ់سلام الله عليها មិនមានស្វាមី

ស្មើរតែប្រាកដថាព្រះនាង ហ្វាទ្វីម៉ាស្ញ់ ម៉ាក់ស្ញូម៉ាស្ញ់سلام الله عليها ពុំមានស្វាមីទេ ។ ហេតុអ្វី ?

យើងដឹងច្បាស់ថាអាពាហ៍ពិពាហ៍ជាប្រការដែលគួរឲ្យអនុវត្តិណាស់  និងជាប្រការមួយដែលអ៊ីស្លាមផ្តាំផ្ញើឲ្យអនុវត្តិ ។  គេបានលើកឡើងនូវពាក្យពេចន៍ខ្លះរបស់ព្រះសាស្តាﷺដូចតទៅ ។

مَا بُنِيَ فِي اَلْإِسْلاَمِ بِنَاءٌ أَحَبُّ إِلَى اَللَّهِ عَزَّ وَ جَلَّ وَ أَعَزُّ مِنَ اَلتَّزْوِيجِ. (بحار الأنوار  ج١٠٠ ص٢٢٢)
"ពុំមានការរៀបចំណាដែលប្រកបដោយកិត្តិយស  និងជាទីស្រឡាញ់ជាងការរៀបចំអាពាហ៍ពិពាហ៍ទេ សម្រាប់អល់ឡោះហ្ញ៍عز وجل ។"[37]

اَلنِّكَاحُ سُنَّتِي، فَمَنْ رَغِبَ عَنْ سُنَّتِي فَلَيْسَ مِنِّي. (جامع الأخبار  ج١ ص١٠١)

---

[37] ស្ហៃខ៍ ហ៊្វូរ អាល់-អ៊ុមីលី (الحر العاملي) វ៉ាសាអ៊ីល អាល់-ស្ញីអ៊ុស្ញ់ (وسائل الشيعة) ក្បាលទី ១៤ ទំព័រ ៣ ។

"អាពាហ៍ពិពាហ៍ជាស៊ុណ្ណាស្ន៍ (ទំនៀម) របស់ខ្ញុំﷺ ។ អ្នកណាមិនអើពើស៊ុណ្ណាស្ន៍ខ្ញុំﷺទេ អ្នកនោះមិនមែនកនខ្ញុំﷺទេ ។"[38]

គេបានឲ្យដឹងថាសម័យអ៊ីមុាំទី ៥ អ៊ីមុាំ អាល់-បាក្វៀរصلوات الله عليه والسلام នារីម្នាក់មិនព្រមរៀបការទេដើម្បីរក្សាកិត្តិយស កាន់វិន័យអប់រំខ្លួននិងដើម្បីបាននៅក្បែរអល់ឡោះហ្ស៍عز وجل ។ អ៊ីមុាំصلوات الله عليه والسلامបានប្រាប់គាត់ថា៖ "បើការលះបង់អាពាហ៍ពិពាហ៍បាននូវកិត្តិយសច្រើន ព្រះនាង ហ្វាទីម៉ាស្ហ៍ ស្ហាស្ន៍រ៉អ៊ុسلام الله عليها ប្រាកដជាពុំបានអភិសេកទេ ព្រោះពុំមានស្ត្រីណាបរិសុទ្ធនិងសម្បូរកិត្តិយសជាងព្រះនាងسلام الله عليهاទេ ។"[39]

អាស្រ័យហេតុនេះ យើងយល់ថាប្រាកដជាមានមូលហេតុដែលព្រះនាង ហ្វាទីម៉ាស្ហ៍ ម៉ាក់ស៊្វូម៉ាស្ហ៍سلام الله عليها មិនមានស្វាមី ។ អាចមានការសន្និដ្ឋានពីរប្រការគឺ៖

មូលហេតុដំបូង ។ អាចសន្និដ្ឋានបានថាអាចមកពីព្រះរាជបុត្រីរបស់ អ៊ីមុាំ អាល់-កាស្ហ៊ីមصلوات الله عليه والسلام ជាស្ត្រីថ្លៃថ្លា ជាពិសេសព្រះនាង ហ្វាទីម៉ាស្ហ៍ ម៉ាក់ស៊្វូម៉ាស្ហ៍سلام الله عليها តែម្តង ។ រកស្វាមីណាដែលស័ក្តិសមនឹងព្រះនាងسلام الله عليهاជាការពិបាក ។ អ៊ីមុាំ អាល់-កាស្ហ៊ីមصلوات الله عليه والسلام ព្រោះតែជាប់ឃុំឃាំងដោយស្តេចខ៍លិហ្វ ហ្ហារូន បានណែនាំពួកគេឲ្យប្រឹក្សានិងសួរយោបល់អ៊ីមុាំ អាល់-រីដ្ហ៍صلوات الله عليه والسلام រឿងអាពាហ៍ពិពាហ៍ ។[40]

បើយើងពិនិត្យមើលពាក្យពេចន៍របស់អ៊ីមុាំ អាល់-ស្វ៍ឌិក្វصلوات الله عليه والسلام ស្តីអំពីការអភិសេកព្រះនាង ហ្វាទីម៉ាស្ហ៍ ស្ហាស្ន៍រ៉អ៊ុسلام الله عليها ជាមួយ អ្នលីصلوات الله عليه والسلام យើងនឹងកាន់តែយល់មូលហេតុដែលព្រះនាង ហ្វាទីម៉ាស្ហ៍ ម៉ាក់ស៊្វូម៉ាស្ហ៍سلام الله عليها នៅលីវ ។

---

[38] វ៉ាសាអ៊ីល អាល់-ស្ហ៊ីអ្នស្ហ៍ (وَسَائِل ٱلشِّيعَة) ក្បាលទី ១៤ ទំព័រ ៧ និង ៨ ។

[39] វ៉ាសាអ៊ីល អាល់-ស្ហ៊ីអ្នស្ហ៍ (وَسَائِل ٱلشِّيعَة) ក្បាលទី ១៤ ទំព័រ ១១៧ និង ១១៨ ។

[40] អ៊ូស៊្វូល អាល់-កាហ្វី (أُصُول ٱلْكَافِي) ក្បាលទី ១ ទំព័រ ៣១៧ ។ មើល វគ្គ ១.១០ ។

لَوْ لاَ أَنَّ اَللَّهَ تَبَارَكَ وَ تَعَالَى خَلَقَ أَمِيرَ اَلْمُؤْمِنِينَ عَلَيْهِ اَلسَّلاَمُ لِفَاطِمَةَ مَا كَانَ لَهَا كُفْوٌ عَلَى ظَهْرِ اَلْأَرْضِ مِنْ آدَمَ وَ مَنْ دُونَهُ. (الكافي ج١ ص٤٦١ ح١٠)

"បើអល់ឡោះហ៍ تبارك وتعالى ពុំបានបង្កើត អាមីរុល-មុមីនីន صلوات الله عليه والسلام ជាគូស្វាមីភរិយានឹង ហ្វាទីម៉ាស់ سلام الله عليها ទេ ប្រាកដជានឹងពុំមានស្វាមីណាដែលស័ក្តិសមនឹងព្រះនាង سلام الله عليها ទេ ពីសម័យអាដាំ عليه السلام រហូតដល់អវសានកាលរបស់ឋានលោក ។"[41]

មូលហេតុទីពីរគឺមកពីការភ័យនិងការខ្លាចអ្នកគ្រប់គ្រងទឹកដីស្តេច ខ៉ុលិហ្វ ហ្វារូន ។ ពុំមានអ្នកណាហ៊ានចងសម្ព័ន្ធមេត្រីជាមួយសមាជិក អាស្ហ៍លុល-បៃត៍ عليهم السلام ទេ ។ រៀបការជាមួយព្រះរាជបុត្រីរបស់អ៊ីមុាំ អាល់-កាស៊្ហិម صلوات الله عليه والسلام ប្រកប ដោយគ្រោះថ្នាក់ ។ នេះគឺការលំបាកមួយគួរឲ្យអាណោចអាធ័មដែលព្រះរាជវង្ស អ៊ីមុាំ صلوات الله عليه والسلام បានជួបប្រទះ ដោយសារការសង្កត់សង្កិនពីសំណាក់អ្នកដឹកនាំក្នុង សម័យនោះ ។[42]

យើងពុំអាចសម្រេចបានយ៉ាងជាក់ច្បាស់ទេថាហេតុអ្វីព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها បានលះបង់ចោលអាពាហ៍ពិពាហ៍ ។ តែយើងជឿជាក់ថាព្រះ

---

[41] អ៊ូស៊្ហូល អាល់-កាហ្វី (أُصُول اَلْكَافِي) ក្បាលទី ១ ទំព័រ ២៦១ ។

[42] មូលហេតុមួយទៀតដែលព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها មិនរៀបការនៅក្នុង ចំណោមពាក្យពេចន៍ខ្យោយ មិនអាចជឿបានទាំងស្រុង គឺគេបានរាយការណ៍ថាស្តេច ខ៉ុលិហ្វ ម៉ាក់មូន (ស្តេចទី ៧ ត្រកូល អ៊ុប់បាស់) ចង់រៀបការជាមួយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ក្នុងគោលដៅនយោបាយ ។ ដើម្បីចៀសវាងមហន្តរាយនេះ ព្រះនាង سلام الله عليها បានលះបង់ចោលអាពាហ៍ពិពាហ៍ទាំងអស់ ។ ប្រហែលជាមកពីមូលហេតុនេះដែរ ដែលអល់ឡោះហ៍ عز وجل មិនបានអនុញ្ញាតឲ្យព្រះនាងហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها បានទៅ ដល់ដែនដីឃ៊ូរ៉សាន ដែនដីដែលព្រះរៀម صلوات الله عليه والسلام ព្រះនាង سلام الله عليها នៅ ព្រោះស្តេច ម៉ាក់មូន អាចបង្ខំព្រះនាង سلام الله عليها ឲ្យរៀបការជាមួយខ្លួន ។ (មើល កាន់ឃ៊ីណាស់ អាស្ហារ គុំម (گنجینه آثار قم) ក្បាលទី ១ ទំព័រ ៣៨៤ ។)

នាង سلام الله عليها ពុំបានលះបង់អាពាហ៍ពិពាហ៍ដោយជម្រើសខ្លួនឯងទេ ។

## ១.៩ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها អ្នកតំណាលហាឌីស្ហព្រះសាស្តា صلى الله عليه وآله وسلم

គុណសម្បត្តិមួយរបស់ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វូម៉ាស់ سلام الله عليها គឺវិជ្ជាសាស្រ្តអ៊ីស្លាមច្រើនវិស័យ ចំណោះព្រះនាង سلام الله عليها បានមកពីព្រះសន្តតិវង្សព្រះសាស្តា صلى الله عليه وآله وسلم ។ ព្រះនាង سلام الله عليها ជាអ្នកតំណាលហាឌីស្ហជាទីទុកចិត្ត ។ អកុសល មកពីមានការសង្កត់សង្កិនពីសំណាក់ដឹកនាំ សេចក្តីរាយការណ៍មកពី អាស្ហ់លុល-បៃត៍ عليهم السلام ត្រូវកៀបសង្កត ហេតុដូច្នេះប្រភពព័ត៌មានច្រើនត្រូវបាត់បង់ ។

យើងសូមលើកឡើងនូវហាឌីស្ហមួយចំនួន តំណាលដោយនារីថ្លៃថ្លាអង្គនេះ ជាមួយខ្សែអ្នកតំណាលបន្ត (السند) ដូចតទៅ ។

حدثتنا فَاطِمَةُ وَ زَيْنَبُ وَ أُمُّ كُلْثُومٍ بَنَاتُ مُوسَى بْنِ جَعْفَرٍ (عَلَيْهِمَا السَّلاَمُ)، قُلْنَ حَدَّثَتْنَا فَاطِمَةُ ...بِنْتُ جَعْفَرِ بْنِ مُحَمَّدٍ الصادق، حَدَّثَتْنِي فَاطِمَةُ بِنْتُ مُحَمَّدِ بْنِ عَلِيٍّ، حَدَّثَتْنِي فَاطِمَةُ بِنْتُ عَلِيِّ بْنِ اَلْحُسَيْنِ، حَدَّثَتْنِي فَاطِمَةُ وَ سُكَيْنَةُ اِبْنَتَا اَلْحُسَيْنِ بْنِ عَلِيٍّ، عَنْ أُمِّ كُلْثُومٍ بِنْتِ فاطمة بنت النبي، عن فاطمة بنت رسول الله (ص) قالت: أنسيتم قول رسول الله (ص) يوم غدير خم: مَنْ كُنْتُ مَوْلاَهُ فَعَلِيٌّ مَوْلاَهُ و قوله (ص): اَنْتَ مِنِّي بِمَنْزِلَةِ هارُونَ مِنْ مُوسى.[43]

"ព្រះរាជបុត្រី سلام الله عليها របស់អ៊ីម៉ាំ អាល់-កាស៊្ហិម صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها [ម៉ាក់ស៊្វូម៉ាស់] ព្រះនាង ស្សៃណាប់ سلام الله عليها និងព្រះនាង អ៊ុម គុលស៊្ហូម سلام الله عليها បានប្រាប់ខ្ញុំ ។ ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-ស្វ៉ាឌិក្ក صلوات الله عليه والسلام បាន

[43] អាគ្ហ្យាម៉ាស់ ស្សៃខ្ខ័ អាប់ដ្វាល់-ហ៊្សសៃន៍ អាមីនី (عبد الحسين الأميني), អាល់-ក៏ដ្ឌៀរ ក្បាលទី ១ ទំព័រ ១៩៧ ។ លោកអ្នកប្រាជ្ញស៊ុន្នីក៏និយាយដល់ហាឌីស្ហនេះដែរ ។

ប្រាប់យើង ។ ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-បាគៀរ صلوات الله عليه والسلام បាននិយាយប្រាប់ ។ ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-សាច់យ៉ាដ្ជុំ صلوات الله عليه والسلام បាននិយាយប្រាប់ ។ ព្រះនាង ហ្វាទីម៉ាស់ سلام الله عليها និងព្រះនាង សាគីណាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បាននិយាយប្រាប់ ។ ព្រះរាជបុត្រីរបស់ព្រះនាង អ៊ូម គុលស៊្មូម سلام الله عليها បាននិយាយប្រាប់យើងតាមព្រះមាតា سلام الله عليها ព្រះនាង سلام الله عليها ថាព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ស្ហាស់រ៉អ៊៍ سلام الله عليها ព្រះរាជបុត្រីរបស់ព្រះសាស្តា صلى الله عليه وآله وسلم មានវចនៈថា៖ "អស់លោកភ្លេចព្រះវចនៈរបស់ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ្ទ៍ عز وجل ហើយឬនាថ្ងៃ ក៏ដ្ឌៀរ ឃុម កាលព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "អ្នកណាព្រមទទួលយកខ្ញុំ صلى الله عليه وآله وسلم ជាអភិបាល អាលី صلوات الله عليه والسلام ក៏ជាអភិបាលរបស់អ្នកនោះដែរ" និងព្រះរាជវចនៈរបស់ព្រះអង្គ صلى الله عليه وآله وسلم ថា៖ "ទំនាក់ទំនងអ្នក صلوات الله عليه والسلام ជាមួយខ្ញុំ صلى الله عليه وآله وسلم ដូចទំនាក់ទំនងហារូន عليه السلام ជាមួយមូសា عليه السلام ។"

យោលតាមខ្សែអ្នករាយការណ៍ខាងលើនេះដែរ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្មូម៉ាស់ سلام الله عليها បាននិយាយប្រាប់តមកពីព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ស្ហាស់រ៉អ៊៍ سلام الله عليها ថាខ្ញុំ سلام الله عليها បានឮព្រះបិតា صلى الله عليه وآله وسلم ខ្ញុំ سلام الله عليها ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "កាលខ្ញុំ صلى الله عليه وآله وسلم ឡើង មិអ៊្រ៉ាច (المعراج) ខ្ញុំ صلى الله عليه وآله وسلم បានចូលទៅក្នុងឋានសួគ៌ ។ ខ្ញុំ صلى الله عليه وآله وسلم បានឃើញនៅក្នុងឋានសួគ៌នោះនូវវាំងមួយដាំសុទ្ធតែគជ់ស ។ ទ្វារវាធ្វើអំពីគជ់និងត្បូង ។ នៅលើទ្វារនោះមានវាំងនន ។ ខ្ញុំ صلى الله عليه وآله وسلم បានងើយមុខមើល ឃើញចារពីលើទ្វារនោះថា៖ "لا اِلهَ اِلا اللهُ، مُحَمَّدٌ رَسُولُ اللهِ، عَلِيٌّ وَلِيُّ الْقَوْمِ (ពុំមានព្រះទេក្រៅពីអល់ឡោះហ្ទ៍ عز وجل ។ អាលី صلوات الله عليه والسلام ជាអគ្គប្រមុខរបស់សហគមន៍ខ្ញុំ صلى الله عليه وآله وسلم ។)" ខ្ញុំ صلى الله عليه وآله وسلم បានមើលទៅវាំងនន ឃើញចារថា៖ "بَخٍّ بَخٍّ مَنْ مِثْلُ شِيعَةِ عَلِيٍّ؟" (អ្នកណាដូចស្ហ៊ីអុាស់ អាលី صلوات الله عليه والسلام ?)" ខ្ញុំ صلى الله عليه وآله وسلم បានចូលទៅក្នុងវាំង នៅក្នុងនោះខ្ញុំ صلى الله عليه وآله وسلم បានឃើញប្រាសាទមួយធ្វើអំពីថ្មកែវ "អាគ៊ីក្ហ العقيق" ក្រហម ។ ប្រាសាទនោះមានទ្វារប្រាក់ដាំបុស្សរាគ៌ម (ត្បូង) បៃតង នៅលើទ្វារនោះមានវាំងនន ។ ខ្ញុំ صلى الله عليه وآله وسلم បានងើយមុខឡើង ឃើញចារនៅលើទ្វារនោះថា៖ "مُحَمَّدٌ رَسُولُ اللهِ عَلِيٌّ وَصِيُّ الْمُصْطَفى (មូហាំម៉ាដ្ជុំ صلى الله عليه وآله وسلم ជាព្រះ

សាសនៈទូតរបស់អល់ឡោះហ៍ﷻ អាលីصلوات الله عليه والسلامជាព្រះឧត្តរាធិការី (អ្នកស្នង) របស់មុស្ហាំម៉ាត់ﷺ ។)"[44]

ព្រះនាង ហ្វាទិម៉ាស់سلام الله عليها ម៉ាក់ស៊្ហូម៉ាស់ បាននិយាយប្រាប់តាមសម្ដីព្រះនាងស៊្វហ្វីយ៉ាស់رضي الله عنها (صفية بنت عبد المطلب) ម្ដាយមីង ឬ ម្ដាយធំខាងឪពុករបស់រ៉ស៊ូលុលឡោះហ៍ﷺ) ព្រះរាជបុត្រីរបស់ អាប់ឌុល-មុត្តាលិបرضي الله عنه ថា៖

عن صفية بنت عبد المطّلب قالت: لما سقط الحسين (ع) من بطن امّه وكنت وليتها قال رسول الله (ص) يا عمة هلمّي اليّ ابني فقلت يا رسول الله انا لم ننظفّه بعد. فقال (ص) يا عمة انت تنظّفينه انّ الله تبارك وتعالى قد نظّفه وطهّره

"កាល អ៊ីម៉ាំ ហ៊្វូសែន៍صلوات الله عليه والسلام ប្រសូតមក ខ្ញុំرضي الله عنها បាននៅមើលព្រះមាតាسلام الله عليهاព្រះអង្គصلوات الله عليه والسلام ។ ព្រះសាស្ដាﷺបានប្រាប់ខ្ញុំرضي الله عنهاថា៖ "ព្រះបិតុលានីرضي الله عنهاអើយ ! សូមយកព្រះរាជទារកصلوات الله عليه والسلامមកឲ្យទូលបង្គំﷺ ។" ខ្ញុំرضي الله عنهاបានទូលថា៖ "ខ្ញុំម្ចាស់رضي الله عنهاមិនបានងូតទឹកឲ្យគេصلوات الله عليه والسلامទេ ។" ព្រះអង្គﷺមានព្រះវចនៈថា៖ "ព្រះបិតុលានីرضي الله عنهاចង់សម្អាតគេصلوات الله عليه والسلام ដ្បិតអល់ឡោះហ៍ﷻបានជម្រះបន្សុទ្ធគេصلوات الله عليه والسلامស្រេចហើយ ?""[45]

គេបានរាយការណ៍ថា៖

عن فاطمة بنت موسى بن جعفر، عن فاطمة بنت الصادق جعفر بن محمد، عن فاطمة بنت الباقر محمد بن علي، عن فاطمة بنت السجاد علي بن الحسين زين العابدين، عن فاطمة بنت ابي عبدالله الحسين، عن زينب بنت أمير المؤمنين، عن فاطمة بنت رسول الله (ص)، قالت قال رسول الله (ص): ألا مَنْ ماتَ عَلى حُبِّ آلِ مُحَمَّدٍ ماتَ شَهِيداً

"ព្រះនាង ហ្វាទិម៉ាស់ [ម៉ាក់ស៊្ហូម៉ាស់]سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-កាស៊ិមصلوات الله عليه والسلام បាននិយាយប្រាប់តមកពីព្រះនាង ហ្វាទិម៉ាស់سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-ស៊្វឌិក្ហصلوات الله عليه والسلام ដែលបាននិយាយប្រាប់តមកពីព្រះនាង ហ្វាទិម៉ាស់سلام الله عليها ព្រះ

---

[44] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦៨ ទំព័រ ៧៦-៧៧ ។

[45] អាល់-អាម៉ាលី (الأمالي) ទំព័រ៨២ ។

រាជបុត្រីរបស់អ៊ីម៉ាំ អាល់-បាគៀរ صلوات الله عليه والسلام ដែលបាននិយាយប្រាប់តមកពីព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-សាច់យ៉ាដ្ឋ صلوات الله عليه والسلام ដែលបានតំណាលតមកពីព្រះនាង ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام តមកពីព្រះនាង ស៊ៃណាប់ سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាលី صلوات الله عليه والسلام ដែលបាននិយាយប្រាប់តមកពីព្រះនាង ហ្វាទីម៉ាស់ ស្សាស់រ៉អ៊ុ سلام الله عليها ព្រះរាជបុត្រីរបស់ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ៍ عز وجل ដែលមានវចនៈថា៖ "ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់ព្រះរាជកុលដ្ឋាន عليهم السلام របស់មូហាំម៉ាដ្ឋ صلى الله عليه وآله وسلم អ្នកនោះស្លាប់ក្នុងលក្ខណៈទុក្ករបុគ្គល (ស្ហាហ៊ីដ្ឋ) ។"[46]

ពាក្យពេចន៍ហាឌីស្សខាងលើនេះ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ជាអ្នកថ្លែងបន្តមកតាមរយៈអ្នករាយការណ៍បន្តដែលគួរទុកចិត្តបាន ។ យើងឃើញហើយថាមិនមានតែមនុស្សប្រុសនៃព្រះរាជកុលដ្ឋាន عليهم السلام របស់ព្រះសាស្តា صلى الله عليه وآله وسلم ទេ ដែលជាអ្នកផ្សាយបន្តពាក្យពេចន៍ហាឌីស្សរបស់ព្រះសាស្តា صلى الله عليه وآله وسلم នោះ បណ្តាស្ត្រីនៃព្រះរាជកុលដ្ឋាន عليهم السلام ព្រះអង្គ صلى الله عليه وآله وسلم ក៏មាននាទីជាអ្នកផ្សាយហាឌីស្សបន្តដែរ ។

## ១.១០ អានុភាពអ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام និងអ៊ីម៉ាំ អាល់-រីដ្ឋ៏ صلوات الله عليه والسلام លើព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها

ពាក្យពេចន៍ហាឌីស្សគួរឲ្យទុកចិត្តបាន បានឲ្យដឹងថាក្នុងអំឡុងឆ្នាំ ១៧៩ នៃសករាជហ៊ិចរ៉ោះត៍ (ឆ្នាំសាកល ៧៩៥) អ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام ត្រូវស្តេចខ៉លិហ្វ ហារូន (ស្តេច ខ៉លិហ្វទី ៥ ត្រកូល អាប់បាស់) ចេញបញ្ជាឲ្យចាប់ខ្លួន

[46] មូហាំម៉ាដ្ឋ ប៊ិន អាស់ម៉ាដ្ឋ ឈីស្សទី ដ្ឋាគីសតានី (محمد بن احمد چشتی داغستانی), អាល់-លុអ៊ុលូអាស់ អាល់-ស្សាមីណាស់ ហ្វី អាល់-អាស្សារ អាល់-មូអានណាក់ណាស់ អាល់-ម៉ារវីយ៉ាស់ (اللؤلؤة الثمينة في الآثار المعنعنة المرويه) ទំព័រ ២១៧ ។ កាន់យ៉ីណាស់ដ្ឋានេស្សម៉ាន់ដ្ឋាន់ (گنجینه دانشمندان) ក្បាលទី ១ ទំព័រ១៦ និង ១៧ ។

និរទេសចេញពីនគរម៉ាឌីណាស្ទូទៅកាន់ខេត្ត បាក់ដាដ្ធ កាត់តាមខេត្តបាស្វ៉ូរ៉េាះត៍ ។ ព្រះអង្គصلوات الله عليه والسلامត្រូវឃុំឃាំងនៅឯខេត្តបាក់ដាដ្ធ ហើយបាននៅក្នុងពន្ធនាគារនោះអស់មួយជីវិត លុះសោយព្រះទិវង្គតក្នុងឆ្នាំ ១៨៣ នៃសករាជហ៊ិជ្រ៉េាះត៍ (ឆ្នាំសាកល ៧៩៩) ។ ការបែកពីព្រះបិតាصلوات الله عليه والسلامធ្វើឲ្យព្រះនាងហ្វាទីម៉ាស្ទ ម៉ាក់ស៊្វូម៉ាស្ទសلام الله عليها រងការលំបាកខ្លាំង ។ ព្រះនាងسلام الله عليهاចង់ឃើញមុខព្រះបិតាصلوات الله عليه والسلامណាស់តែពុំអាចទៅរួច ពីព្រោះព្រះរាជវង្សរបស់អ៊ីម៉ាំصلوات الله عليه والسلامបានដំណឹងថាព្រះអង្គصلوات الله عليه والسلامបានសោយព្រះទិវង្គតក្រោយពីបានជាប់ឃុំឃាំង ៤ ឆ្នាំនៅក្នុងពន្ធនាគារបាក់ដាដ្ធ ។

ចាប់តាំងពីព្រះបិតាصلوات الله عليه والسلامព្រះនាងسلام الله عليهاជាប់ឃុំឃាំងមក ព្រះនាងسلام الله عليهاនៅក្រោមអាណាព្យាបាលព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها អ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام ។ ព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليهاបានថែរក្សាព្រះនាងسلام الله عليهاរហូតដល់ឆ្នាំ ២០០ សករាជហ៊ិជ្រ៉េាះត៍ (ឆ្នាំសាកល ៨១៦) កាល ម៉ាក់មូន បានកោះហៅព្រះអង្គصلوات الله عليه والسلامឲ្យទៅកាន់តំបន់ឃ្វ៉ូរ៉សាន ។

ព្រះបិតាصلوات الله عليه والسلامព្រះនាងسلام الله عليها អ៊ីម៉ាំ អាល់-កាស៊្ទីមصلوات الله عليه والسلام ជាអ្នកដាក់ព្រះនាងسلام الله عليهاនៅក្រោមអាណាព្យាបាលភាពព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها អ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام ។ បន្ទាប់ពីបានតែងតាំងអ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام ជាអាណាព្យាបាលរបស់បណ្ដាមហេសីនិងបណ្ដាបុត្រីព្រះអង្គصلوات الله عليه والسلام អ៊ីម៉ាំ អាល់-កាស៊្ទីមصلوات الله عليه والسلام បានសរសេរព្រះរាជបណ្ដាំទុកឲ្យថា៖

وَاِنْ اَرادَ رَجُلٌ مِنْهُمْ اَنْ يُزَوِّجَ اُخْتَهُ، فَلَيْسَ لَهُ اَنْ يُزَوِّجَها اِلاَّ بِاِذْنِهِ وَاَمْرِهِ. (الكافي ج١ ص٣١٦ ح١٥ (internet

"អ្នកណាមួយចង់ឲ្យបងប្អូនស្រីខ្លួនមានគូស្វាមី ចូរអ្នកនោះសូមអនុញ្ញាតពីគេصلوات الله عليه والسلام (គឺអ៊ីម៉ាំ អាល់-រីដ្ឋ៏صلوات الله عليه والسلام) ។"[47]

[47] អ៊្វូស៊្វូល អាល់-កាហ្វី (أصول الكافي) ក្បាលទី ១ ទំព័រ ៣១៧ ។

អ៊ីមុាំ អាល់-រីដ្ឋ៏ صلوات الله عليه والسلام មិនត្រឹមតែត្រូវតែងតាំងជាអាណាព្យាបាលរបស់ព្រះនាង ហ្វាទីម៉ាស្ទ់ ម៉ាក់ស៊្លូម៉ាស្ទ់ سلام الله عليها តែម្នាក់ទេ ព្រះអង្គ صلوات الله عليه والسلام ជាអាណាព្យាបាលរបស់បណ្ដាព្រះមហេសីនិងព្រះបុត្រីទាំងអស់របស់អ៊ីមុាំ អាល់-កាស្ទ៊ីម صلوات الله عليه والسلام ដែរ ។

ព្រះនាង سلام الله عليها បានរស់នៅជាមួយព្រះបិតា صلوات الله عليه والسلام ដល់មានព្រះជន្ម ៦ ព្រះវស្សា ។ ព្រះនាង سلام الله عليها ខិតខំសិក្សាពីព្រះបិតា صلوات الله عليه والسلام ក្នុងអំឡុងពេលនេះ ។ ទោះបីព្រះនាង سلام الله عليها មានវ័យក្មេងក៏ដោយ តែព្រះនាង سلام الله عليها មានចំណេះនិងការយល់ដឹងខ្ពស់ណាស់ ។

អាយ៉ាទុលឡោះហ្ទ័ សៃយីដ្ទ ណាស្ទ់រុលឡោះហ្ទ័ មុសតាន់ប៊ីត្ទ[48] បានសរសេរថាលោកបានរកឃើញសាត្រាសរសេរដោយដៃ នៅក្នុងបណ្ណាល័យស្ទ៊ុស្ទតារីនៃប្ញូជនីយខេត្តណាយ៉ាហ្ទ់ នូវពាក្យពេចន៍ហ្ទាឌ៊ីស្ទមួយថា៖ "ថ្ងៃសុក្រមួយ ស្ទ៊ីអាស្ទ់ច្រើននាក់បាននាំគ្នាទៅជួបអ៊ីមុាំ អាល់-កាស្ទ៊ីម صلوات الله عليه والسلام ដើម្បីសូមឲ្យព្រះអង្គ صلوات الله عليه والسلام ឆ្លើយតបសំណួរខ្លះ ។ លុះទៅដល់ដំណាក់អ៊ីមុាំ صلوات الله عليه والسلام គេបានប្រាប់អស់ទាំងគាត់ថាព្រះអង្គ صلوات الله عليه والسلام មិននៅទេ ។ ពួកគាត់បានសម្រេចចិត្តសរសេរសំណួរលើក្រដាសហើយផ្ញើសំណួរទាំងអស់នេះនៅឯអ្នកគ្រួសារព្រះអង្គ صلوات الله عليه والسلام ដើម្បីនឹងឲ្យព្រះអង្គ صلوات الله عليه والسلام ឆ្លើយតបពេលព្រះអង្គ صلوات الله عليه والسلام ត្រឡប់មកវិញ ។ បន្ទាប់ពីបានស្នាក់នៅម៉ាឌ៊ីណាស្ទ់ពីរបីថ្ងៃ ពួកគាត់គិតត្រឡប់ទៅលំនៅដ្ឋានវិញ ។ មុនចាកចេញ ពួកគាត់បានកាត់តាមដំណាក់អ៊ីមុាំ صلوات الله عليه والسلام ដើម្បីសូមលាព្រះអង្គ صلوات الله عليه والسلام ។ ទីនោះ គេបានប្រគល់ក្រដាសសំណួរឲ្យមកពួកគាត់វិញ ដោយមានសរសេរនូវចម្លើយរបស់សំណួរទាំងអស់ ។ ចម្លើយសំណួរពួកគាត់នោះ ព្រះនាង ហ្វាទីម៉ាស្ទ់ មាក់ស៊្លូម៉ាស្ទ់ سلام الله عليها ជាអ្នកផ្ដល់ឲ្យ កាលនោះព្រះនាង سلام الله عليها មានព្រះជន្ម ៦ វស្សា ។ អស់លោកបានចាកចេញពីម៉ាឌ៊ីណាស្ទ់ដោយពេញចិត្តនឹងចម្លើយ ។ តាមផ្លូវទៅ

[48] កូនប្រសាររបស់អាយ៉ាទុលឡោះហ្ទ័ សៃយីដ្ទ អាប៊ូ អាល់-កូ៏ស៊ីម អាល់-ឃ្ញុអ៊ី (سيد ابو القاسم خوئي) ។

លំនៅដ្ឋានវិញ អស់លោកបានជួបអ៊ីម៉ាំ អាល់-កាស៊ុីម صلوات الله عليه والسلام ដែលត្រឡប់ទៅម៉ាឌីណាស់វិញ ។ ពួកគាត់បានតំណាលប្រាប់ព្រះអង្គ صلوات الله عليه والسلام ព្រឹត្តិការណ៍ដែលបានកើតឡើង ។ អ៊ីម៉ាំ صلوات الله عليه والسلام បានសូមមើលក្រដាសដែលមានសំណួរឆ្លើយដោយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ។ បន្ទាប់ពីបានពិនិត្យមើលចម្លើយ ដោយឃើញថាសំណួរទាំងអស់បានឆ្លើយតបត្រឹមត្រូវនិងក្បោះក្បាយ ដោយព្រះរាជបុត្រីពៅរបស់ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ "فِدَاهَا اَبُوهَا (សូមឲ្យព្រះបិតា صلوات الله عليه والسلام ព្រះនាង سلام الله عليها បានធ្វើពលីកម្មដើម្បីព្រះនាង سلام الله عليها) ។" អ៊ីម៉ាំ صلوات الله عليه والسلام បានថាមួយឃ្លានេះបីដង ។[49]

ព្រះសាស្ដា صلى الله عليه وآله وسلم ក៏បានប្រើពាក្យពេចន៍នេះដែរឲ្យព្រះនាង ហ្វាទីម៉ាស់ ស្ហាស់រ៉ អ៊ុ سلام الله عليها ។[50]

ពាក្យពេចន៍ហ្វាឌីស្ហូតទៅនេះជាភ័ស្តុតាងបញ្ជាក់ថាព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها មានទេពកោសល្យថ្វីដ្បិតព្រះនាង سلام الله عليها ជាកុមារភាព ។ រឿងនេះមិនចម្លែកទេពីព្រោះនៅក្នុងឌូអ្ហាអ៊ុ ស៊ីយ៉ារ៉ស់ ព្រះនាង سلام الله عليها [ចម្លងមកពី អ៊ីម៉ាំ អាល់-រីដ្ហ៊ុ صلوات الله عليه والسلام] នោះមានសេចក្ដីដូចតទៅគឺ៖

اَلسَّلامُ عَلَيْكِ يا فاطِمَةُ بِنْتَ موسَى بْنِ جَعْفَرٍ وَ حُجَّتِهِ وَ اَمينِهِ.

"សូមសិរីសួស្ដីកើតមានដល់ព្រះនាង سلام الله عليها ឱ ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់មូសា ប៊ិន យ៉ាក់ហ្វារ صلوات الله عليه والسلام ព្រះរាជភ័ស្តុតាង ព្រះរាជបុគ្គលជាទីទុកចិត្ត ។"[51]

បន្ទាប់ពីបាននៅក្រោមអាណាព្យាបាលភាពព្រះបិតា صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها នៅក្រោមការថែរក្សារបស់ព្រះរៀម صلوات الله عليه والسلام អស់ម្ដែមួយឆ្នាំ ។ ព្រះ

---

[49] កាស្ហ៍ហ្វ អាល់-ឡាអ៊ាលី (كشف اللئالي) ក្បាលទី ៧ ទំព័រ ១៤ ។

[50] ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៣ ទំព័រ ៨៦ និង ៨៨ ។

[51] ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៣ ទំព័រ ៨៨ ។

នាងسلام الله عليهاទទួលបាននូវផលប្រយោជន៍ច្រើនបំផុតពីព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها ។

ពិតណាស់ ព្រះនាងسلام الله عليهاប្រកបដោយកម្រិតធម៌ខ្ពស់ណាស់ អាស្រ័យហេតុនេះ ព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليهاបានលើកឋានន្តរស័ក្តិឲ្យព្រះនាងسلام الله عليهاថា ម៉ាក់ស៊្ហូម៉ាស៊ូ (អរិរុទ្ធបុគ្គល) ។ នេះគឺថោមនាការកំពូលមួយមកពីអ៊ីម៉ាំصلوات الله عليه والسلام ។



**ព្រះបូជនីយចេតិយព្រះនាង ហ្វាទីម៉ាស៊ូ ម៉ាក់ស៊្ហូម៉ាស៊ូسلام الله عليها**

# ២. ដំណើរទៅគុម

## ២.១ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها បែកពី អ៊ីម៉ាំ អាល់-រីដ្ឋ صلوات الله عليه والسلام

ទោះបីព្រះនាង سلام الله عليها លំបាកអត់ពីព្រះបិតា صلوات الله عليه والسلام ក៏ដោយ តែព្រះនាង سلام الله عليها នៅមានព្រះរៀម صلوات الله عليه والسلام ជាជម្រកអាស្រ័យ ជួយសម្រាលទុក្ខ ។ តែក្នុងឆ្នាំ ២០០ សករាជហ៊ីច្ចរ៉ោះត៏ (ឆ្នាំសាកល ៨១៦) [ស្ដេចខ៏លិហ្វទី ៧ ត្រកូល អ៊ាប់បាស់] ម៉ាក់មូនបានបង្ខំឲ្យអ៊ីម៉ាំ អាល់-រីដ្ឋ صلوات الله عليه والسلام ទៅកាន់តំបន់ឃូរ៉សាន ។ ចំណាកមាតុភូមិរបស់ព្រះរៀម صلوات الله عليه والسلام ព្រះនាង سلام الله عليها ធ្វើឲ្យព្រះនាង سلام الله عليها កាន់តែបារម្ភខ្លាំងឡើង ។ និរាសព្រាត់ប្រាសនេះបានកន្លងទៅអស់មួយឆ្នាំ តែអកុសលព្រះនាង سلام الله عليها ចាកចោលលោកនេះមុនបានឃើញមុខព្រះរៀម صلوات الله عليه والسلام ។

កាល អាមីន [ស្ដេចខ៏លិហ្វទី ៦ ត្រកូល អ៊ាប់បាស់] ត្រូវទ័ពរបស់ ម៉ាក់មូន ប្អូនខ្លួន សម្លាប់ ម៉ាក់មូនក៏បានទៅជាស្ដេចខ៏លិហ្វ ។ ការសោយរាជ្យរបស់ ម៉ាក់មូន មិនបិតថេរទេពីដំបូង ។ ម៉ាក់មូនត្រូវការជំនួយដើម្បីបង្រួបបង្រួមអាណាចក្រដែលត្រូវបែងចែកនោះ ។ ដើម្បីទទួលបាននូវការគាំទ្រពីពួកស៊ីអ៊ាស់ ម៉ាក់មូន ទទូចសូមឲ្យអ៊ីម៉ាំ អាល់-រីដ្ឋ صلوات الله عليه والسلام យាងមកឯតំបន់ឃូរ៉សាន ។

លុះទៅដល់ ម៉ាក់មូនបានទទួលព្រះអង្គ صلوات الله عليه والسلام ដោយកិត្តិយស ដោយយកលេសថាខ្លួនគោរពព្រះអង្គ صلوات الله عليه والسلام ជាព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ថែមទាំងប្រកាសខ្លួនជាអ្នកតាមព្រះអង្គ صلوات الله عليه والسلام ។ ស្ដេចខ៏លិហ្វរូបនេះគួរតែលះបង់អំណាចឲ្យទៅអ៊ីម៉ាំ صلوات الله عليه والسلام ដើម្បីបញ្ជាក់ឲ្យឃើញនូវសេចក្ដីស្មោះត្រង់ ។ ផ្ទុយទៅវិញ ម៉ាក់មូនបែរជាប្រកាសលើកអ៊ីម៉ាំ صلوات الله عليه والسلام ជាអ្នកស្នងខ្លួន ដោយលាក់ទុកក្នុងចិត្តថាថ្ងៃនោះមិនអាចមកដល់បានឡើយ ។

អ៊ីម៉ាំ صلوات الله عليه والسلام ព្រមទទួលការអញ្ជើញនេះទាំងបង្ខំ ។ ព្រះអង្គ صلوات الله عليه والسلام បានធ្វើដំណើរទៅកាន់តំបន់ឃូរ៉សាន ។ វត្តមានព្រះអង្គ صلوات الله عليه والسلام នៅឯរាជវាំងរបស់ម៉ាក់មូនបម្រើផលប្រយោជន៍ស៊ីអ៊ុស្ហ៊ូនិងសាសនាអ៊ីស្លាម ។ អ៊ីម៉ាំ صلوات الله عليه والسلام បានទៅដល់តំបន់ឃូរ៉សានឆ្នាំ ២០០ សករាជហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ៨១៦) ។ ម៉ាក់មូនបានដាក់ថ្នាំបំពុលសម្លាប់អ៊ីម៉ាំ صلوات الله عليه والسلام ក្នុងឆ្នាំ ២០៣ សករាជហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ៨១៩) ។

ម៉ាក់មូនបានរៀបចំឯកសារវីឡាយ៉ាត់ (ស្នងរាជ្យ) ឲ្យអ៊ីម៉ាំ អាល់-រីដ៏ صلوات الله عليه والسلام ប្រាំច្បាប់ ។ មួយច្បាប់ផ្ញើទៅម៉ាក់កាស់ មួយច្បាប់ផ្ញើទៅម៉ាឌីណាស់ មួយច្បាប់ផ្ញើទៅដែនដីស្ហាំ (ស៊ីរី) មួយច្បាប់ទៅបាក់ដាដ់ មួយច្បាប់ទុកនៅឯឃូរ៉សាន ។[1]

ម៉ាក់មូនបានដាក់បញ្ជាថាឲ្យមានឈ្មោះអ៊ីម៉ាំ អាល់-រីដ៏ صلوات الله عليه والسلام នៅក្នុងឃុត្ធបាស់ស្វឡាត់ថ្ងៃសុក្រ គ្រប់ដែនដីអ៊ីស្លាម និងឲ្យបោះពុម្ពកាក់ប្រាក់ដាក់ឈ្មោះអ៊ីម៉ាំ صلوات الله عليه والسلام ។

ស៊ីអ៊ុស្ហ៊ូមួយចំនួនធំបានភៀសខ្លួនទៅកាន់តំបន់ឃូរ៉សាន ដើម្បីបាននៅក្បែរអ៊ីម៉ាំ صلوات الله عليه والسلام ។ អ្នកខ្លះចាញ់កលល្បិចគេ ដោយសារជឿម៉ាក់មូនដែលសម្តែងសេចក្តីគោរពចំពោះអ៊ីម៉ាំ صلوات الله عليه والسلام តែអាការក្រៅ ដែលគ្រាន់តែជាមធ្យោបាយបោកបញ្ឆោតក្នុងល្បិចនយោបាយ ។

## ២.២ ដំណើរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហ៊ូម៉ាស់ سلام الله عليها ពីម៉ាឌីណាស់

បែកពីព្រះរៀម صلوات الله عليه والسلام ជាទីស្រឡាញ់ជាងមួយឆ្នាំយ៉ាងលំបាក ព្រះនាងហ្វាទីម៉ាស់ម៉ាក់ស្ហ៊ូម៉ាស់ سلام الله عليها សម្រេចចិត្តចេញដំណើរទៅរកព្រះអង្គ صلوات الله عليه والسلام ។ ព្រះនាង سلام الله عليها បានចាប់ផ្តើមធ្វើដំណើរពីម៉ាឌីណាស់ទៅតំបន់ឃូរ៉សានឆ្នាំ ២០១ សករាជ

[1] មូហ៊ាំម៉ាដ់ ប៊ិន ហ៊ាសាន់ អាមីលី, តារីក្ហ រ៉ីយ៉ាន់ រាយការណ៍ដោយ ណាស៊ី អាល់-ឌីន អាល់-ទូស៊ី ទំព័រ ២១៣ ។

ហ្វុីច្ជរ៉ោះត្ន័ជាមួយមនុស្សមួយក្រុមដែលជាសមាជិកគ្រួសារព្រះនាង سلام الله عليها និងជាមិត្តរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។

ប្រវត្តិវិទូខ្លះបានថាដែលព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស្វ៊ូម៉ាស្វ៉ូ سلام الله عليها ធ្វើដំណើរដ៏ឆ្ងាយ និងប្រកបដោយអន្តរាយនេះ ព្រោះតែចង់នៅក្បែរព្រះរៀម صلوات الله عليه والسلام ព្រះនាង سلام الله عليها ។ តែនេះដូចជាមិនមែនមូលហេតុតែម្យ៉ាងទេ ។
មូលហេតុដែលសក្តិសមជាងគេនៃការធ្វើដំណើរនេះ គឺពីព្រោះព្រះនាង سلام الله عليها មានតួនាទីមួយដែរក្នុងការបំពេញបេសកកម្មជាមួយអ៊ីម៉ាំ صلوات الله عليه والسلام ។ ចំណេះវិជ្ជាមហាសាលជាមួយជំនឿមុតមាំរបស់ព្រះនាង سلام الله عليها អាចនឹងជួយអ៊ីម៉ា صلوات الله عليه والسلام បាន ក្នុងការផ្សព្វផ្សាយព្រះសាសនាអ៊ីស្លាម ជាពិសេសក្នុងចំណោមបណ្តាស្ត្រី ។
ត្រង់ចំណុចនេះ តួនាទីព្រះនាង سلام الله عليها ប្រៀបបាននឹងតួនាទីព្រះនាង ហ្វាទីម៉ាស្វ៉ូ ស្ហ្វ៉ារ៉ូស្វ៉ូ سلام الله عليها ដែលនៅខាងព្រះសាស្តា صلى الله عليه وآله وسلم ឬព្រះនាង ស្វៃណាប់ سلام الله عليها ដែលនៅខាងអ៊ីម៉ាំ អាលី صلوات الله عليه والسلام អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام និងអ៊ីម៉ាំ ហ៊្វសែន៍ صلوات الله عليه والسلام នៅឯការបាទ្បារ៉ុននិងក្រោយពីនោះ នៅខាងអ៊ីម៉ាំ អាលី ស៊ែន៍ អាល់-អាប៊ីឌីន صلوات الله عليه والسلام ។

មានកំណត់ហេតុផ្សេងៗ ដែលស្តីអំពីមូលហេតុនៃការធ្វើណើររបស់គ្រួសារអ៊ីម៉ាំ صلوات الله عليه والسلام ពីម៉ាឌីណាស្វ៉ូទៅស្រុកសាវ៉េះហ្វ៍ និងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងពេលធ្វើដំណើរនេះ ។
កំណត់ហេតុមួយបានឲ្យដឹងថា អ៊ីម៉ាំ صلوات الله عليه والسلام បានសរសេរសំបុត្រទៅព្រះរាជអនុជាព្រះអង្គ صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស្វ៉ូ ម៉ាក់ស្វ៊ូម៉ាស្វ៉ូ سلام الله عليها តាមរយៈបម្រើម្នាក់របស់ព្រះអង្គ صلوات الله عليه والسلام ដោយប្រាប់បម្រើនោះថារួសរាន់ទៅកាន់ម៉ាឌីណាស្វ៉ូមិនឲ្យឈប់តាមផ្លូវនៅកន្លែងណាមួយទេ ។ ក្រោយពីបានទទួលសំបុត្រពីព្រះរៀម صلوات الله عليه والسلام ព្រះនាង ហ្វាទីម៉ាស្វ៉ូ ម៉ាក់ស្វ៊ូម៉ាស្វ៉ូ سلام الله عليها បានរៀបចំខ្លួនធ្វើដំណើរទៅកាន់តំបន់ឃ៉ូរ៉សានជាបន្ទាន់ដោយកាត់តាមស្រុកសាវ៉េះហ្វ៍ ។[2]

---

[2] សៃយីដ្ឋ ដ្ឋាឃីល ប៊ិន ហ៊្វសែន៍ (داخل حسن تحميل), ម៉ាន់ ឡា យ៉ាស្វ៉ូឌ្ឌរុះហ្វ៍ អាល់-ខ្វ៉ទីប

ហាឌីស្សមួយបានឲ្យដឹងថា អ៊ីម៉ាំ صلوات الله عليه والسلام បានសរសេរសំបុត្រទៅក្រុមគ្រួសារទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام ផ្ដាំឲ្យមកឯតំបន់ឃូរ៉សាន ។ គេបានតំណាលថាបន្ទាប់ពីសំបុត្របានទៅដល់ មនុស្សមួយក្រុមដោយមានបុត្រានិងសមាជិកគ្រួសារឯទៀតរបស់អ៊ីម៉ាំ صلوات الله عليه والسلام និងស៊ីអ៊ាស់ឯទៀត មានចំនួន ១២០០០ នាក់ បានចាកចេញទៅកាន់តំបន់ឃូរ៉សាន ។[3]

ហាឌីស្សមួយទៀតបានឲ្យដឹងថា ពេលសំបុត្របានទៅដល់បណ្ដាសមាជិកគ្រួសារព្រះអង្គ صلوات الله عليه والسلام ទុក្ខព្រួយដោយសារបែកពីអ៊ីម៉ាំ صلوات الله عليه والسلام បានធ្វើឲ្យពួកគេសម្រេចចិត្តទៅតាមព្រះអង្គ صلوات الله عليه والسلام ។ គេបានរៀបចំយានរទេះសម្រាប់ធ្វើដំណើរក្រោមការដឹកនាំផ្លូវរបស់ អ៊ីបរ៉ហ៊ីម បុត្ររបស់អ៊ីម៉ាំ អាល់-កាស៊ីម صلوات الله عليه والسلام ហើយក៏បានចេញដំណើរទៅកាន់តំបន់ឃូរ៉សាន ។[4]

គេបានតំណាលថា យានរទេះធ្វើដំណើរពីរក្រុមបានឆ្ពោះទៅកាន់តំបន់ឃូរ៉សាន ។ ក្រុមមួយមានព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها មានគ្នា ២៣ នាក់ ក្រោមការដឹកនាំផ្លូវរបស់ ហារូន អ៊ីបនូ មូសា អ៊ីបនូ យ៉ាក់ហ្វារ ។[5] ក្រុមមួយទៀតធ្វើដំណើរឆ្ពោះទៅឃូរ៉សានមានគ្នា ១២០០០ ក្រោមការដឹកនាំផ្លូវរបស់ អាស់ម៉ាដ់ អ៊ីបនូ មូសា អាល់-កាស៊ីម ។[6]

---

(من لا يحضره الخطيب) ក្បាលទី ៤ ទំព័រ ២៦១ ។

[3] សៃយីដ មូហាំម៉ាដ់ អាលី រ៉ៅដ៍ទី (سيد محمد على روضاتى), យ៉ាមិអ៍ អាន់សាប់ (جامع أنساب) ទំព័ ១៧ ។

[4] ប៊ីហារ អាល់-អាន់សាប់ (بحر الأنساب) ទំព័រ ៩១-៩៤ ។

[5] អាលី អាក់បារ តាស្ហៃយ៉ាដ់ (علي اكبر تشيد), គ៊ីយ៉ាម សាដាត់ អាឡាវី (قيام سادات علوي) ទំព័រ ១៦០ ។

[6] អាលី អាក់បារ តាស្ហៃយ៉ាដ់ (علي اكبر تشيد), គ៊ីយ៉ាម សាដាត់ អាឡាវី (قيام سادات علوي) ទំព័រ ១៦៩ ។

យានរទេះធ្វើដំណើរបានទៅដល់ស្រុកមួយហៅថាសាវ៉េះហ្វ៍ តាមផ្លូវទៅកាន់តំបន់ឃ្ជូរ៉សាន តែត្រូវពួកសត្រូវព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាﷺវាយប្រហារ ។ ច្រើននាក់បានស្លាប់ដោយទុក្ករកម្ម រាប់ទាំង ហ្វារូន ផង ។ ច្រើននាក់ទៀតរងរបួសឬត្រូវចាប់ខ្លួនជាឈ្លើយ ខ្លះទៀតរត់រួច ។ នារីសត្រូវម្នាក់បានដាក់ថ្នាំបំពុលក្នុងចំណីព្រះនាង ហ្វាទី្ទម៉ាស្ហ ម៉ាក់្កស្ហូម៉ាស្ហسلام الله عليها ធ្វើឲ្យព្រះនាងسلام الله عليهاមានជម្ងឺ ។

គេបាននាំព្រះនាងسلام الله عليهاទៅខេត្តគុ្ឋមតាមសំណូមព្រះនាងسلام الله عليها ។ បន្ទាប់ពីបានស្នាក់នៅខេត្តគុ្ឋមពីរបីថ្ងៃ ព្រះនាងسلام الله عليهاសោយព្រះទិវង្គតដោយសារជម្ងឺ សពព្រះនាងسلام الله عليهاត្រូវបញ្ចុះនៅទីនោះ ។[7]

កំណត់ហេតុមួយទៀតបានឲ្យដឹងថា ហ្វារូន និងបណ្ដាសមាជិកគ្រួសារព្រះនាង ហ្វាទី្ទម៉ាស្ហ ម៉ាក់្កស្ហូម៉ាស្ហسلام الله عليها មានចំនួនទាំងអស់ ២៣ នាក់ ត្រូវសម្លាប់ក្នុងការលួចវាយឆ្មក់ ដោយពួកអ្នកស្រុកសាវ៉េះហ្វ៍ដែលស្អប់ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាﷺណាស់សម័យនោះ ។

នៅក្នុងសាត្រា គ្ឃីយ៉ាម អាល់-សាដ្ឋាត់ អាល់-អ៊្ឡាវី (قيام [ال] سادات [ال] علوي [ين]) គេ បានថាការពិតកងទ័ពរបស់ ម៉ាក់្កមូន ជាបុគ្គលដែដល់ក្នុងការវាយឆ្មក់នោះ ។ គេបានឲ្យដឹងថាពួកទាហានកាក់រទេះយានធ្វើដំណើរមិនទៅមុខទៀតទេ ។ នៅក្នុងការចរចា ពួកទាហានបាននិយាយបង្ខូចថា៖ "អ៊ីមុាំអ្នកឯងស្លាប់ហើយ ។" សម្ដីបង្កាច់នេះបានធ្វើឲ្យអ្នកជំរំស្លុតចិត្ត ។ អ្នកខ្លះសម្រេចចិត្តត្រឡប់ទៅម៉ាឌីណាស្ហវិញ អ្នកឯទៀតចង់ធ្វើដំណើរស្រូតទៅមុខ ។ រឿងនេះអាចជា

7 អ៊្អលី អាក់្កបារ តាស្ហៃយ៉ាដ្ឌ (علي اكبر تشيد), គ្ឃីយ៉ាម សាដ្ឋាត់ អ៊្ឡាវី (قيام سادات علوي) ទំព័រ ១៦០ និង ១៦៨ ។ យ៉ាក់្ជហ្វារ មូរតាដ្ឋ៍ អាល់-អ៊្អាមីលី (جَعْفَر مُرْتَضى العامِلي), អាល់-ហ្ហាយ៉ាស្ហ អាល់-ស៊ីយ៉ាស៊ីយ៉ាស្ហ លី អ៊ីមុាំ អាល់-រីដ្ឋ៍ (الحياة السياسية للإمام الرضا) ទំព័រ ៤២៨ ។

មូលហេតុធ្វើឲ្យមានយល់ខុសថាព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្មូម៉ាស់ سلام الله عليها សោយទិវង្គត ដោយសារព្រះរៀម صلوات الله عليه والسلام ជាទីស្រឡាញ់របស់ព្រះនាង سلام الله عليها សោយព្រះទិវង្គត ។

ទោះជាយ៉ាងណាក៏ដោយ ការច្របូកច្របល់បានកើតឡើង ពួកទាហានបានឆ្លៀតយកឱកាសនេះវាយលុកជំរំអ្នកដំណើរ ។ ក្នុងការវាយប្រហារនេះ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្មូម៉ាស់ سلام الله عليها បានឃើញផ្ទាល់ភ្នែកសមាជិកគ្រួសារព្រះនាង سلام الله عليها ២៣ នាក់ត្រូវគេសម្លាប់យ៉ាងសាហាវយង់ឃ្នង ។

ហេតុដូច្នេះ គេប្រៀបធៀបព្រះនាង سلام الله عليها នឹងព្រះនាង ស៊ៃណាប់ سلام الله عليها ដែលជាសាក្សីផ្ទាល់ភ្នែកការកាប់សម្លាប់សមាជិកគ្រួសារព្រះនាង سلام الله عليها ដែរ ។

ដោយសារសោកនាដកម្មដ៏សែនឈឺចាប់នេះ ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្មូម៉ាស់ سلام الله عليها ធ្លាក់ខ្លួនឈឺ ត្រូវគេនាំទៅខេត្តគុ្ម ។ បន្ទាប់ពីបានស្នាក់នៅទីនោះអស់ ១៦-១៧ ថ្ងៃ ព្រះនាង سلام الله عليها សោយទិវង្គត សពព្រះនាង سلام الله عليها ត្រូវបញ្ចុះនៅទីនោះ ។[8]

គេបានឲ្យដឹងដែរថាក្រុមទីពីរដែលមានស្ហ៊ីអុាស់ ១២០០០ នាក់ក៏ត្រូវគេវាយប្រហារដែរ តាមបញ្ជា ម៉ាក់មូន ដោយប្រើដៃអាជ្ញាធរនយោបាយនៃអាណាខេត្ត ហ្វារស៍ (فارس) នៅឯស្រុកមួយដែលហៅថា ស្ហ៊ីរ៉ាស់ (شيراز) ។ អ្នកក្រុមនេះទាំងអស់ត្រូវសម្លាប់ឬបានរត់គេចខ្លួន ។[9]

សេចក្តីរាយការណ៍ខាងលើនេះអាចបំភ្លឺមូលហេតុ ដែលគេឃើញមានផ្នូរកូនចៅច្រើននិងសមាជិកគ្រួសាររបស់អ៊ីម៉ាំ صلوات الله عليه والسلام នៅក្នុងប្រទេសអ៊ីរ៉ង់ ។ ឧទាហរណ៍ នៅស្រុកសាវ៉េះហ្វ៍ មានផ្នូរសៃយីដ្ឋ អ៊ីសហ្វាក់, សៃយីដ្ឋ រីដ្ហ៏, អាុលី អាស់ក៉ារ (عَلِيّ ٱلْأَصْغَر) (ទាំងអស់ជាកូនចៅរបស់អ៊ីម៉ាំ صلوات الله عليه والسلام) ។ ទាំងអស់សុទ្ធតែជាបូជនីយដ្ឋានសម្រាប់ធ្វើគារវៈកិច្ច (ស៊ីយ៉ារ៉ាស់) រំលឹកឧបការគុណដែលអស់

[8] ស្ហៃខ៍ ម៉ាស់ឌី ម៉ាន់ស៊ូរី (شيخ مهدي منصوري) ហ្វាយ៉ាត់ អាល់-ស៊ីត (حياة الست) ទំព័រ ១៦០ ។
[9] គ្វីយ៉ាម សាដ្ហាត់ អាុឡាវី (قيام سادات علوي) ទំព័រ ១៦៩ ។

លោកបានបូជាជីវិតដើម្បីព្រះសាសនាអល់ឡោះហ្ទ៍ عز وجل រាប់ទាំងបណ្ដាផ្នូរនៅក្បែរស្រុកសាវ៉េះហ្វ៍នេះដែរ ដែលចាត់ទុកជាផ្នូររបស់បណ្ដាកូនចៅអ៊ីម៉ាំ صلوات الله عليه والسلام ដែរ ។[10]

## ២.៣ ដំណើរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ពីស្រុកសាវ៉េះហ្វ៍ទៅខេត្តគុម

កាលព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها ឈឺនៅស្រុកសាវ៉េះហ្វ៍ ព្រះនាង سلام الله عليها បានសួរកនព្រះនាង سلام الله عليها អំពីចម្ងាយពីទីនោះទៅខេត្តគុម ។ គេបានប្រាប់ព្រះនាង سلام الله عليها ថាឆ្ងាយ ១០ ហ្វារសាក់ (ប្រមាណ ៦០ គីឡូម៉ែត្រ) ។[11]
ព្រះនាង سلام الله عليها សូមឲ្យគេសែងព្រះនាង سلام الله عليها ទៅគុម ប្រជានិករខេត្តនេះជាស៊ីអាស់ ។[12] អ្នកស្រុកសាវ៉េះហ្វ៍ម្ខាងទៀតស្អប់គ្រួសារព្រះសាស្ដា صلى الله عليه وآله وسلم ។[13]

អាឡាម៉ាស់ អាល់-ម៉ាច់លីស៊ី មានប្រសាសន៍ថា៖ "កំណត់ហេតុច្បាស់បំផុតគឺពេលគ្រួសាររបស់ សាអាដ់ អាស់អារី ត្រកូលស៊ីអាស់ធំមួយនៅខេត្តគុម បានដំណឹងថាព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ عليهم السلام នៅស្រុកសាវ៉េះហ្វ៍ មានជម្ងឺទាំងអស់គ្នាបាននាំគ្នាទៅសាវ៉េះហ្វ៍ដើម្បីសូមអញ្ជើញព្រះនាង سلام الله عليها ទៅគុម ។ នៅក្នុងត្រកូលនេះ មានបុរសម្នាក់ជាសាវករបស់អ៊ីម៉ាំ អាល់-រីដ៏ صلوات الله عليه والسلام ឈ្មោះ មូសា អ៊ីបនូ ខាស់រ៉ច់ អ៊ីបនូ សាអាដ់ អាស់អារី ។ ពេលលោកបានទៅជួបព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ عليهم السلام លោកបានដឹកព្រះនាង سلام الله عليها លើអូដ្ឋព្រះនាង سلام الله عليها ទៅគុម ឲ្យព្រះនាង سلام الله عليها ស្នាក់ឯលំនៅដ្ឋានលោក ។ ព្រះនាង سلام الله عليها បាននៅទីនេះ

[10] គីយ៉ាម សាដាត់ អាឡាវី (قيام سادات علوي) ទំព័រ ១៦៦ ។
[11] ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២១៩ ។
[12] ស៊ីនដេគី (زِنْدَگی حضرت موسا بن جعفر) ក្បាលទី ២ ទំព័រ ៣៨៤ ។
[13] កាន់ជីណាស់ អាសារ គុម (گنجينه آثار قم) ក្បាលទី ១ ទំព័រ ៣៨២ ។

ច្រើនថ្ងៃចុងក្រោយនៃជីវិតព្រះនាងﷺ (១៦ ឬ ១៧ ថ្ងៃ) ។[14]

គេថាព្រះនាង ហ្វាទ៊ីម៉ាស់ ម៉ាក់ស៊្សូម៉ាស់ﷺ សោយទិវង្គតថ្ងៃទី ១០ ឬទី ១២ ខែ រ៉ប៊ីអុាល់-ស្សានី ថាព្រះនាងﷺមានព្រះជន្ម ១៦ ឬ ១៧ ថ្ងៃចុងក្រោយនៃជីវិតព្រះនាងﷺនៅឯខេត្តគូម ។ អាស្រ័យហេតុនេះយើងអាចស្មានបានថាព្រះនាងﷺ បានមកដល់ខេត្តគូមប្រហែលថ្ងៃទី ២៤ ខែ រ៉ប៊ីអុាល់-អៅវ៉ាល់ ។

លំនៅដ្ឋានរបស់ មូសា អ៊ីបនូ ខុស្សរ៉ចុំ អ៊ីបនូ សាអុាដុំ អាស្សអុារី ដែលព្រះនាង ហ្វាទ៊ីម៉ាស់ ម៉ាក់ស៊្សូម៉ាស់ﷺ បានស្នាក់នៅច្រើនថ្ងៃនោះ សព្វថ្ងៃនេះបានទៅជាមន្ទីរសិក្សាហៅថា "ម៉ាដ្ទរ៉សាស់ ស៊ីតទីយ៉ាស់ (المدرسة الستّيّة)" [ស៊ីតទី មានន័យម្ចាស់ស្រ្តី ពោលគឺ មន្ទីរសិក្សាម្ចាស់ស្រ្តី]។ រហូតមកដល់សព្វថ្ងៃ នៅទល់មុខទ្វារសាលានេះក្នុងបរិវេណលំនៅដ្ឋាន នៅមានអាសនៈសម្រាប់ធ្វើសក្ការៈ (មិះហ៊្រ៉ប អ៊ីបាដ្ទាស់) របស់ព្រះនាងﷺ ។ ព្រះនាងﷺបានធ្វើសក្ការៈអល់ឡោះហ្វ៊ុំនៅទីនេះច្រើនថ្ងៃចុងក្រោយនៃជីវិតព្រះនាងﷺ ។ គេហៅកន្លែងនេះដែរថា "បៃត៍ អាល់-នូរ (بيت النور មន្ទីររស្មី)" ។ បណ្តាបូជនីយេសក៍ឬអ្នកធម្មយាត្រាស្គាល់កន្លែងនេះច្បាស់ មកកាន់ទីនេះដើម្បីធ្វើគារវៈកិច្ច ។

## ២.៤ ព្រឹត្តិការណ៍នៅពេលបញ្ចុះព្រះរាជសព ព្រះនាង ហ្វាទ៊ីម៉ាស់ ម៉ាក់ស៊្សូម៉ាស់ﷺ

កន្លែងបញ្ចុះព្រះរាជសពព្រះនាង ហ្វាទ៊ីម៉ាស់ ម៉ាក់ស៊្សូម៉ាស់ﷺ ឈ្មោះ "បាបាឡាន់ (بابلان)" សម័យនោះ ។ វាជាកន្លែងរហោឋាន គ្មានសំណង់ ជា

[14] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២១៩ ។

កម្មសិទ្ធិរបស់ មូសា អ៊ីបនូ ខុស្ស៊ូរ៉ច់ ។ លោកបានបរិច្ចាគដីនេះក្នុងគោលដៅបញ្ចុះព្រះរាជសពមហានារីថ្លៃថ្លាអង្គនេះسلام الله عليها ។

បន្ទាប់ពីបានជ្រើសរើសកន្លែងបញ្ចុះព្រះរាជសពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها ហើយ សមាជិកគ្រួសាររបស់ សាអ្ទុដ៍ បានរៀបចំកន្លែងសម្រាកអវសានរបស់ព្រះនាងسلام الله عليها ដោយជីកផ្នូរធ្វើចេតិយដាក់ព្រះរាជបូជនីយសពព្រះនាង سلام الله عليها ។

ផ្ងូតទឹកព្រះរាជសពហើយ រុំសំពត់[កាហ្វាន់]ស្រេចហើយ គ្រួសារ សាអ្ទុដ៍ បានពិភាក្សាគ្នាជ្រើសរើសអ្នកដែលមានកិត្តិយស លើកព្រះរាជបូជនីយសពទៅតម្កល់ក្នុងព្រះចេតិយ ។ បន្ទាប់ពីបានប្រឹក្សាគ្នាមួយរយៈពេលធំទាំងអស់គ្នាបានមូលមតិគ្នាជ្រើសរើសបុរសម្នាក់ឈ្មោះ ក៏ដៀរ (قادر) ។ ក៏ដៀរ ជាបុរសចំណាស់ម្នាក់ដែលមានជំនឿ ខ្លាចអល់ឡោះហ៍عز وجل ដែលស្រឡាញ់ព្រះរាជកុលដ្ឋានعليهم السلام ព្រះសាស្តាصلى الله عليه وآله وسلم ។

ព្រមនឹងពេលនោះ ពួកគេបានឃើញមនុស្សបិទមុខពីរនាក់ជិះសេះ មកពីវាលរហោឋាន ។ មនុស្សបិទមុខទាំងពីរនាក់នេះបានចូលមកដល់យ៉ាងលឿន ចុះពីលើសេះនៅខាងកន្លែងបញ្ចុះព្រះរាជសព ។ ពួកគេបានចូលមក ហើយបានធ្វើពិធីនមស្ការសព (ស្វ៊ឡាត់ ម៉ាយិត) ឲ្យព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់سلام الله عليها ។ ម្នាក់បានចូលទៅក្នុងព្រះចេតិយ ម្នាក់ទៀតលើកព្រះរាជបូជនីយសពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់سلام الله عليها ឲ្យទៅគាត់ ។ ការបញ្ចុះព្រះរាជបូជនីយសពបានប្រព្រឹត្តទៅដូច្នេះ ។

កិច្ចបញ្ចុះព្រះរាជបូជនីយសពបានចប់សព្វគ្រប់ហើយ មិនបាននិយាយជាមួយអ្នកណាម្នាក់សោះ មនុស្សបិទមុខទាំងពីរនាក់បានឡើងជិះសេះ ចាកចេញទៅវិញ ។[15]

---

[15] ប៊ីហ្ារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៤៨ ទំព័រ ២៩០ ។ តារីក្ហ កាឌីម គ្ហុម (تاريخ قم) ទំព័រ ២១៣ ។

ពុំមានអ្នកណាដឹងទេថាបុរសបិទមុខទាំងពីរនាក់នោះជាអ្នកណា ។ តែបណ្ដាអ្នកដែលស្គាល់លក្ខណសម្បត្តិនិងចរិយារបស់អ៊ីម៉ាំ صلوات الله عليه والسلام ដឹងច្បាស់ថាឥស្សរជនទាំងពីរអង្គនោះគឺអ៊ីម៉ាំ អាល់-រីដ្ហ៍ صلوات الله عليه والسلام និងព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំ អាល់-តាគ្គី صلوات الله عليه والسلام ។

ព្រះអង្គទាំងពីរ عليهم السلام បានមកពីតំបន់ឃ្ញរ៉សាននិងម៉ាឌ្ទីណាស្ហ៍ ដោយសារអានុភាពអាចឆ្លងកាត់ចម្ងាយច្រើនយោជន៍បានតែមួយភ្លែត (طيّ الأرض ពង្រួញដី ឬ មូរដី) ដើមមកចូលរួមក្នុងពិធីបុណ្យព្រះរាជបូជនីយសពព្រះនាង ហ្វាទ្វិម៉ាស្ហ៍ ម៉ាក្ហុំស្ហ៊ូម៉ាស្ហ៍ سلام الله عليها ។

វត្តមានព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام នៅក្នុងពិធីបុណ្យសព្វស្ហ៊ីអ៊ាស្ហ៍ស្មោះត្រង់មិនមែនព្រឹត្តិការណ៍មិនធម្មតាទេ ពីព្រោះមានឧទាហរណ៍ច្រើនមកហើយនៅក្នុងប្រវត្តិសាស្ត្រ ។
គេបានឲ្យដឹងនៅក្នុងកំណត់ហេតុមួយថាអ៊ីម៉ាំ អាល់-កាស្ហ៊ីម صلوات الله عليه والسلام បានយាងមកពី ម៉ាឌ្ទីណាស្ហ៍ មកកាន់ស្រុក ណៃស្ហាប៊ូរ (نيشابور) ដើម្បីចូលរួមក្នុងពិធីបុណ្យសពជីដូនចំណាស់ម្នាក់ដែលមានឈ្មោះថា "ស្ហាទ្វីតោះត្ហ៍ (شَطِيطَةَ)" ដែលជាស្ហ៊ីអ៊ាស្ហ៍ស្មោះ ស៊ប់ចិត្ត ។ កាលនោះ អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់ អាប៊ូ យ៉ាក្ហុំហ្វារ ណៃស្ហាប៊ូរី ដែលមានវត្តមាននៅទីនោះដែរ ដែលឆ្ងល់អំពីវត្តមានអ៊ីម៉ាំ صلوات الله عليه والسلام ឆ្ងាយពីម៉ាឌ្ទីណាស្ហ៍ ថា៖

اِنَّي وَ مَنْ جَرى مَجْرايَ مِنْ أَهْلِ الْبَيْتِ، لا بُدَّ لَنا مِنْ حُضورِ جَنائِزِكُمْ في أيِّ بَلَدٍ كُنْتُمْ، فَاتَّقُوا اللهَ في اَنْفُسِكُمْ وَ أَحْسِنوا الأَعْمالَ، لِتُعينونا عَلى خَلاصِكُمْ وَ فَكِّ رِقابِكُمْ مِنَ النّارِ. (الثاقب فى المناقب ج١ ص٤٣٩)

"ខ្ញុំ صلوات الله عليه والسلام និងអ៊ីម៉ាំ صلوات الله عليه والسلام អាស្ហ៍លុល-បៃត៍ عليهم السلام បន្ទាប់ពីខ្ញុំ صلوات الله عليه والسلام នឹងមានវត្តិមានក្នុងការហែហាមអមសពអស់លោក ទោះបីអស់លោកអស់ជីវិតនៅដែនដីណាក៏ដោយ ។ ដូច្នេះ ចូរខ្លាចអល់ឡោះហ្ហ៍ عزّ وجلّ ចូរជឿស៊ប់ចិត្ត ចូរអត់ធ្មត់ក្នុងការធ្វើល្អ

ដើម្បីយើង عليهم السلام នឹងមករំដោះអស់លោកពីភ្លើងនរក ។"[16]

យោលតាមពាក្យពេចន៍ហ្ហាឌីស្ហ៍ខាងលើនេះ មិនមែនមិនសមហេតុផលទេដែលសន្មតថាបុរសបិទមុខជិះសេះពីរនាក់ដែលលេចខ្លួនឡើងពីទីនីមួយដែលពុំមានអ្នកណាដឹង ដើម្បីចូលរួមក្នុងពិធីបុណ្យព្រះរាជបូជនីយសពព្រះនាង ហ្វាទិ៍ម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍ سلام الله عليها នោះការពិតគឺ អ៊ីម៉ាំ អាល់-រីដ្ហ៍ صلوات الله عليه والسلام និងអ៊ីម៉ាំ អាល់-តាគ្គី صلوات الله عليه والسلام ។



## ២.៥ សពឥស្សរជនឯទៀតបញ្ចុះនៅក្បែរព្រះនាង ហ្វាទិ៍ម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍ سلام الله عليها

ច្រើនឆ្នាំបន្ទាប់ពីបានបញ្ចុះព្រះរាជសពព្រះនាង ហ្វាទិ៍ម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍ سلام الله عليها ព្រះរាជសពព្រះនាង អ៊្ហុម មូហ៊្ហាំម៉ាដ្ហ៍ បុត្រីរបស់ មូសា មូបារក្ក៊្អ៍ (موسىٰ المُبَرْقَع) ព្រះរាជបុត្ររបស់អ៊ីម៉ាំ អាល់-តាគ្គី صلوات الله عليه والسلام ត្រូវបានបញ្ចុះក្បែរព្រះចេតិយព្រះនាង سلام الله عليها ។ ច្រើនឆ្នាំក្រោយមក ព្រះនាង ម៉ៃមូណាស្ហ៍ បងប្អូនស្រីរបស់ព្រះនាង អ៊្ហុម

[16] អ៊ីបនូ ហ្ហាំស្ហាស្ហ៍, អាល់-ស្ហាគ្គីប ហ្វី អាល់-ម៉ាណាគ្គីប (الثاقب فى المناقب) ទំព័រ ៤៤៥ ។

មូហ៊ាំម៉ាដ់ បានទទួលទិវង្គត ហើយត្រូវបានបញ្ចុះនៅក្បែរព្រះរាជចេតិយព្រះនាង ហ្វាទិ៍ម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺ ដែរ ។
ដោមចេតិយព្រះនាងទាំងពីរដាច់ពីដោមព្រះចេតិយព្រះនាង ហ្វាទិ៍ម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺ ។ បន្ទាប់មក សពព្រះនាង ប៊ូរ៉យ៉ហ៊ីយ៉ាស់ (بريهية) បុត្រីរបស់មូសា ព្រះរាជបុត្ររបស់អ៊ីម៉ាំ អាល់-គាគ្គីﷺ ត្រូវបានបញ្ចុះនៅទីនេះដែរ ។[17]

ស្ហៃខ៍ អាប់បាស់ គុម្មី (شيخ عباس قمي) អ្នករាយការណ៍ជាទីគោរព បានឲ្យដឹងថា សពម្ចាស់ស្ត្រីច្រើនអង្គទៀតត្រូវបានបញ្ចុះនៅទីនេះ ដូចជា ព្រះនាង សៃណាប់ បុត្រីអ៊ីម៉ាំ អាល់-គាគ្គីﷺ, អ៊ូម អ៊ីសហ្កាក់ បម្រើរបស់ មូហ៊ាំម៉ាដ់ អ៊ីបនូ មូសា មូបារក្វ៊អ៍ និង អ៊ូម ហ្កាប៊ីប បម្រើរបស់ មូហ៊ាំម៉ាដ់ អ៊ីបនូ អាស់ម៉ាដ់ អ៊ីបនូ មូសា មូបារក្វ៊អ៍ ។[18]
ហេតុការណ៍ដែលសពបណ្ដាស្ត្រីថ្លៃថ្លាឯទៀត ដែលជារាជវង្សរបស់អ៊ីម៉ាំﷺ ត្រូវបានបញ្ចុះនៅក្បែរព្រះនាង ហ្វាទិ៍ម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺនោះ ជាហេតុផលធ្វើឲ្យយើងយល់ថាហេតុអ្វីបានជាគេឃើញមានមួយឃ្លានេះ នៅក្នុងកម្រងពាក្យពេជន៍សម្ដែងសេចក្ដីគោរព (ស៊ីយ៉ារ៉ោះត៍ زيارة) ថា៖

السَّلامُ عَلَيْكُنَّ يا بَناتِ رَسولِ اللهِ، السَّلامُ عَلَيْكُنَّ وَرَحْمَةُ اللهِ وَبَرَكاتُهُ

"សូមសិរីសួស្ដីកើតមានដល់ព្រះនាងទាំងពួង ព្រះរាជបុត្រីរបស់ព្រះសាសនៈទូតអល់ឡោះហ្វ៍ﷻអើយ ! សូមព្រះសិរីសួស្ដី ព្រះមេត្តាធម៌និងព្រះពរអល់ឡោះហ្វ៍ﷻកើតមានដល់ព្រះនាងទាំងពួង ។"

ភ័ស្តុតាងមួយទៀតដែលបញ្ជាក់ថា សពបុគ្គលឯទៀតនៅក្នុងព្រះរាជវង្សព្រះសាស្តាﷺត្រូវបានបញ្ចុះទីនេះ គឺព្រឹត្តការណ៍មួយនេះរាយការណ៍ដោយអាយ៉ាទុលឡោះហ្វ៍ ហ្កាច អាក់ហ្វ៊ូសែន៍ មុច្ចតាហ៊ីដ្ធ ដែលបានទទួលអនិច្ចកម្ម

[17] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២២០ និង ២២៩ ។

[18] មុនតាហ្វា អាល់-អាម៉ាល់ (مُنتَهی الآمال) ក្បាលទី ២ ទំព័រ ១៦២ ។

ទៅហើយ បានឲ្យដឹងថា៖ "សម័យស្តេច ណាស្សៀរ អាល់-ឌីន ស្ហាស់ (ناصر الدين شاه) ស្លាប់ឆ្នាំ ១៣១៣ ស.ហ្. ត្រូវនឹងឆ្នាំសាកល ១៨៩៥) កាលគេបានឃើញកម្រាលព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហូម៉ាស់ﷺ ក្រាលដោយថ្មកែវ របើកនៅប៉ែកខាងបន្ទប់បញ្ចុះព្រះរាជសព (ضَرِيح) គេបានសម្រេចថាត្រូវជួសជុលបំណែកបំណាក់នេះនៅក្នុងព្រះចេតិយ ។
គេបានជ្រើសរើសស្ត្រីមានជំនឿស៊ប់ចិត្តពីរនាក់ឲ្យចូលទៅក្នុងព្រះចេតិយ ដើម្បីជួសជុលបំណែកបំណាក់នោះ ។ ពេលបានចូលទៅក្នុងព្រះចេតិយ ស្ត្រីទាំងពីរនាក់នោះបានឃើញថាបំណែកនោះ មិនមែននៅក្នុងព្រះចេតិយព្រះនាងហ្វាទីម៉ាស់ ម៉ាក់ស្ហូម៉ាស់ﷺ ទេ តែវាបែកចេញទៅឯចេតិយមហាស្ត្រីបីអង្គដែលនៅក្បែរនោះទេ ។ ស្ត្រីទាំងពីរនាក់នោះបានឲ្យដឹងថាសពស្ត្រីបីអង្គនោះមានសភាពដដែលហាក់ដូចជាទើបនឹងបានបញ្ចុះថ្ងៃនោះ ។"
ក្រោយពីបានស៊ើបអង្កេតរួច គេបានឲ្យដឹងថាសពទាំងនោះគឺសពព្រះនាងម៉ៃមូណាស់ បុត្រីរបស់ មូសា មូបារក្វ៍អ៊ ព្រះរាជបុត្ររបស់អ៊ីម៉ាំ អាល់-គាគ្វីصلوات الله عليه والسلام និងសពរបស់បម្រើពីរនាក់របស់ព្រះនាងឈ្មោះ អ៊ូម អ៊ីសហ្ហាក់ និង អ៊ូម ហ្ហាប៊ីបដែលត្រូវបានបញ្ចុះកាលពី ១១ សតវត្សរ៍កន្លងមក ។[19]

ព្រឹត្តិការណ៍ខាងលើនេះមិនគួរឲ្យភ្ញាក់ផ្អើលទេ បើគេពិនិត្យមើលពាក្យពេចន៍ហ្ហាឌីស្ហព្រះសាស្តាមូហ្ហាំម៉ាដ់ﷺ គឺ៖

اِنَّ اللهَ حَرَّمَ لُحُومَنا عَلَى الأَرْضِ فَلا يَطْعُمُ مِنْها شَيْئاً

"ការពិតអល់ឡោះហ្វ៍عزوجل បានហាមផែនដីប៉ះពាល់សាច់យើងعليهم السلام ។ ខ្លួនប្រាណយើងعليهم السلام នឹងពុំត្រូវដីស៊ីឡើយ ។"[20]

---

[19] មៀរស្ហា មូសា ហ្វារ៉ហ្ហានី (مرزا موسى فراهانى), អ៊ីក្វ៍ម៉ាស់ អាល់-ប៊ូរហ្ហាន ដ្វារ អ៊ូស្ហូល អាល់-ឌីន ទំព័រ ៤៧៩ ។

[20] ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ២២ ទំព័រ ៥៥០ ។ ម៉ាន់ ឡា យ៉ាស្ហ៊ូរុះហ្វ៍ អាល់-ហ្វាគ្វិះហ្វ៍ (مَنْ لَا يَحْضُرُهُ الْفَقِيه) ក្បាលទី ១ ទំព័រ ១២១ ។



ដោមលើព្រះបូជនីយដ្ឋានព្រះនាង ហ្វាទិម៉ាស់ ម៉ាក់ស៊ូម៉ាស់سلام الله عليها

# ៣. ព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហូម៉ាស់ سلام الله عليها

## ៣.១ ប្រវត្តិសង្ខេប

បន្ទាប់ពីបានបញ្ចប់កិច្ចបញ្ចុះព្រះរាជសពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហូម៉ាស់ سلام الله عليها មូសា អ៊ិបនូ ខ៊ុស្សរ៉ជ៌ បានដាក់ពិតានធ្វើអំពីឈើត្បាញពីលើព្រះរាជផ្នូរ ឥតផ្លាស់ប្ដូររហូតមកដល់ព្រះនាង ស្រៃណាប់ ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-តាគី صلوات الله عليه والسلام បានមកឯត្ដុម ហើយបានសាងដោមពីលើព្រះរាជផ្នូរនេះ ។[1] ដោមនោះធ្វើអំពីឥដ្ឋប៉ាតបាយអ ។ ព្រឹត្តិការណ៍នេះបានកើតឡើងក្នុងសតវត្សរ៍ទី ៣ នៃសាសនាអ៊ីស្លាម (ឆ្នាំ ៣០០ សករាជហ៊្ជិច្ជរ៉ោះត៍ ត្រូវនឹងឆ្នាំសាកល ៩១៣) ។

ច្រើនឆ្នាំកន្លងមក ដោមពីរទៀតត្រូវបានសាងសង់ឡើងក្បែរដោមដំបូង ។ ដោមនោះនៅពីលើព្រះរាជផ្នូរព្រះនាង ស្រៃណាប់ ព្រះរាជបុត្រីរបស់អ៊ីម៉ាំ អាល់-តាគី صلوات الله عليه والسلام ។

ដោមទាំងបីនេះនៅរហូតមកដល់ឆ្នាំ ៤៥៧ សករាជហ៊្ជិច្ជរ៉ោះត៍ (ឆ្នាំសាកល ១០៦៥) កាលមន្ត្រីរបស់ស្ដេច ទុក្ករូល មៀរ អាប៊ូ អាល់-ហ្វាដ្ឌល៍ អ៊ីរ៉ាគី បានសាងដោមខ្ពស់ត្រដែតជួសដោមទាំងបីតាមសំណូមរបស់វិញ្ញូ ស្សៃខ៌ ទូស៊ី (الشيخ الطوسي អនិច្ចកម្មឆ្នាំ ៤៦០ ស.ហ្វ. ត្រូវនឹងឆ្នាំសាកល ១០៦៨) ។

## ៣.២ រជ្ជកាល ស្វ៍ហ្វាវី

ចាប់តាំងពីពេលផ្លាស់ដោមបីជាដោមមួយ រហូតមកដល់រជ្ជកាលស្ដេចត្រកូល ស្វ៍ហ្វាវី[2] សភាពព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស្ហូម៉ាស់ سلام الله عليها មិនសូវប្រែ

---

[1] ប៊ីហ្ការ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ៦០ ទំព័រ ២១៩ ។

[2] ស្ដេចត្រកូល ស្វ៍ហ្វាវី បានសោយរាជ្យនៅប្រទេសអ៊ីរ៉ង់អស់រយៈពេល ២៣០ ឆ្នាំ ពីឆ្នាំ

ប្រួលប៉ុន្មានទេ ។ សម័យនោះពុំមានសាលនៅពីលើព្រះរាជផ្នូរ ពុំមានសាំយ៉ាប ឬទីផ្លាទេ ។

ឆ្នាំ ៩២៥ សករាជហ៊្ចីរ៉ោះត៍ (ឆ្នាំសាកល ១៥១៩) ស្តេច ស្ហាស៍ អ៊ីសម៉ាអ៊ីល ទីមួយ បានសាងសំយាបធ្វើពីមាសនៅខាងជើងព្រះចេតិយ បានចាក់គ្រឹះ (នៅខាងត្បូង) កន្លែងដែលគេហៅសព្វថ្ងៃនេះថាទីផ្លាចាស់ ។ បន្ទាប់ពីស្តេចនេះ ស្តេច ស្ហាស៍ តាស៍ម៉ាស់ព៍ ទី ១ (شاه تهماسپ) ស្លាបនាសាលបញ្ចុះព្រះរាជសព ដោយដាំការ៉ូរលោងជុំវិញព្រះរាជផ្នូរ ហើយបានសាងសំយាបនៅខាងត្បូងព្រះចេតិយ (ក្នុងទីផ្លាចាស់) ។

ឆ្នាំ ១០៧៧ សករាជហ៊្ចីរ៉ោះត៍ (ឆ្នាំសាកល ១៦៦៧) ស្តេច ស្ហាស៍ ស៊្វហ្វី (شاه صفي) បានសាងទីផ្លាសម្រាប់ស្ត្រីនៅខាងត្បូងនៃជើងព្រះរាជផ្នូរ ។ សព្វថ្ងៃនេះទីផ្លានេះព័ទ្ធជុំវិញម៉ាស់ឃ៊្ជិដ្ឋ ត៍បាត៍បាអ៊ី (الطباطبائي) ។ ទីផ្លានេះជាកន្លែងចញ្ចុះសព ស្ហាស៍ អាុប់បាស់, ស្ហាស៍ ស៊ូឡៃម៉ាន, ស្ហាស៍ ស៊ុលត្ន ហ៊្វសែន៍ ។ ក្នុងរជ្ជកាលសម្តេច ស្ហាស៍ អាុប់បាស់ សាលបញ្ចុះព្រះរាជសពត្រូវពាសដោយសន្លឹកដែកភ្លឺ ។ សម័យនេះនៅមានសន្លឹកដែកភ្លឺនេះមួយប៉ែក ជាមួយសន្លឹកប្រាក់ជាបន្ថែម ។

---

៩០៥ សករាជហ៊្ចីរ៉ោះត៍ (ឆ្នាំសាកល ១៥០០) ដល់ឆ្នាំ ១១៣៥ សករាជហ៊្ចីរ៉ោះត៍ (ឆ្នាំសាកល ១៧២៣) ។ អ្នកកាន់អំណាចមាន ស្ហាស៍ អ៊ីសម៉ាអ៊ីល ទី ១ (شاه اسماعیل یکم), ស្ហាស៍ តាស៍ម៉ាស់ព៍ ទី ១ (شاه تهماسپ یکم), ស្ហាស៍ អ៊ីសម៉ាអ៊ីល ទី ២ (شاه اسماعیل دوم), ស្ហាស៍ អាុប់បាស់ ទី ១ (شاه عباس بزرگ), ស្ហាស៍ ស៊្វហ្វី (شاه صفی), ស្ហាស៍ អាុប់បាស់ ទី ២ (شاه عباس دوم), ស្ហាស៍ ស៊ូឡៃម៉ាន (شاه سلیمان), ស្ហាស៍ ស៊ុលត្ន ហ៊្វសែន៍ (شاه سلطان حسین), ស្ហាស៍ តាស៍ម៉ាស់ព៍ ទី ២ (شاه تهماسپ دوم), ស្ហាស៍ អ៊ីសម៉ាអ៊ីល ទី ៣ (شاه اسماعیل سوم), ស្ហាស៍ អាុប់បាស់ ទី៣ (شاه عباس سوم) ។

## ៣.៣ រជ្ជកាល ក្វ៉ាយ៉ារ (قاجار)

បន្ទាប់ពីរជ្ជកាលស្វ៉ាហ្វាវី ពុំមានការកែប្រែ ពុំមានការជួសជុលព្រះរាជចេតិយព្រះនាង ហ្វាទីម៉ាស្ហ់ ម៉ាក់ស៊្វូម៉ាស្ហ់ﷺ ទេ រហូតដល់រជ្ជកាល ក្វ៉ាយ៉ារ នៅប្រទេសអ៊ីរ៉ង់ ។[3]

ឆ្នាំ ១២១៨ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ១៨០៣) ស្ដេច ហ្វាត់ហ៍ អាលី ស្ហាស្ហ់ ក្វ៉ាយ៉ារ បានសាង ដោមមាសខ្ពស់ដោយដុំឥដ្ឋពាសមាសចំនួន ១២០០០ ដុំ ។ ឆ្នាំ ១២៣៦ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ១៨២១) ម៉ាស់យ៉ិដ្ជមួយឈ្មោះថា ម៉ាសយ៉ិដ្ជ បាឡាសារ (مسجد بالاسر) [ម៉ាស់យ៉ិដ្ជនៅខាងព្រះសិរព្រះរាជសពព្រះនាង ហ្វាទីម៉ាស្ហ់ ម៉ាក់ស៊្វូម៉ាស្ហ់ﷺ] ត្រូវបានសាងឡើង ។

ឆ្នាំ ១២៧៦ (ឆ្នាំសាកល ១៨៦០) សម្ដេច ស្ហាស្ហ់ អ៊ីសម៉ាអ៊ីល ស្វ៉ាហ្វាវី បានតាក់តែងលំអសំយាបដោយមាស ។ ក្នុងឆ្នាំ ១២៧៥ (ឆ្នាំសាកល ១៨៥៩) សករាជហ៊ិជ្រ៉េះត៍ សម្ដេច ស្ហាស្ហ់ អាប់បាស់ បានស្លាបនាសាលព្រះរាជផ្នូពាសសន្លឹកដែកដោយសន្លឹកប្រាក់ ។

ក្បែរចុងសតវត្សរ៍ទី ១៣ សករាជហ៊ិជ្រ៉េះត៍ គេបានចាក់គ្រឹះសាងទីធ្លាថ្មីធំជាងមុន ។ ការសាងសង់នេះបានចប់ក្នុងរជ្ជកាលស្ដេច ណាស្ស៊ែរ អាល់-ឌីន ស្ហាស្ហ់

---

[3] រជ្ជកាលត្រកូល ក្វ៉ាយ៉ារ នៅប្រទេសអ៊ីរ៉ង់ ចាប់ពីឆ្នាំ ១២០០ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ១៧៨៦) ដល់ឆ្នាំ ១៣៣៩ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ១៩២១) ។ អ្នកកាន់អំណាចមាន អាក្ហ មូហ៊ាំម៉ាដ់ ខ្ហាន (آغا محمد خان), ហ្វាត់ហ៍ អាលី ស្ហាស្ហ់ (فتح علی‌شاه), មូហ៊ាំម៉ាដ់ ស្ហាស្ហ់ (محمد شاه), ណាស្ស៊ែរ អាល់-ឌីន ស្ហាស្ហ់ (ناصر الدين شاه), មូស្ហ្វហ្វ៉ារ អាល់-ឌីន ស្ហាស្ហ់ (مظفر الدين شاه), មូហ៊ាំម៉ាដ់ អាលី ស្ហាស្ហ់ (محمد على شاه), អាស្ហ៍ម៉ាដ់ ស្ហាស្ហ់ (احمد شاه) ។

ក្នុងឆ្នាំ ១៣០៣ សករាជហ្ស៊ីច្រ៉េះត៍ (ឆ្នាំសាកល ១៨៨៦) ។[4]

## ៣.៤ ក្រោយបដិវត្តន៍អ៊ីស្លាមមានជ័យជំនះ

នៅក្នុងប្រវត្តិព្រះចេតិយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺ ការស្ថាបនាគាត់តែងលំអច្រើនដោយប្រើវត្ថុធាតុផ្សេងៗនិងសិល្បអក្សរសាស្ត្រ ត្រូវបានបន្ថែមទៅលើព្រះចេតិយនោះ ។

បន្ទាប់ពីបដិវត្តន៍អ៊ីស្លាមនៃប្រទេសអ៊ីរ៉ង់បានទទួលជ័យជំនះ លោកអគ្គប្រមុខអាយ៉ាទុលឡោះហ្ស៍ អាល់-ឃុំមែនី (آية الله الخميني) បានអនុញ្ញាតឲ្យមានការផ្លាស់ប្តូរសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការសម្រួល និងការរៀបចំព្រះបូជនីយចេតិយ ។ ការបង្កើតឲ្យមានសេវាកម្មសម្រាប់បូជនីយេសក៍ ។ អាយ៉ាទុលឡោះហ្ស៍ ប៊ូរូយ៉ាវឌី (بروجردی) បានសាង ម៉ាស់យ៉ិដ អាក់ស៊ាំ ( مسجد اعظم) ភ្ជាប់នឹងព្រះចេតិយ ។ ព្រះចេតិយត្រូវបានពង្រីក រហូតមកដល់សម័យឥឡូវ គ្រោងការពង្រីកនៅតែអនុវត្តិបន្ត ។ មានការផ្លាស់ប្តូរច្រើនទៀតតែសូមស្លេះត្រឹមនេះ ។

## ៣.៥ ការសាងបន្ទប់បញ្ចុះព្រះរាជសព

ក្នុងឆ្នាំ ៦០៥ សករាជហ្ស៊ីច្រ៉េះត៍ (ឆ្នាំសាកល ១២០៩) អាមៀរ អាស្ស៊ម៉ាដ់ អ៊ីបនូ អ៊ីសម៉ាអ៊ីល បានប្រគល់មុខការតែងលំអព្រះរាជផ្នូរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ﷺ ឲ្យទៅជាងផលិតការ៉ូកែវនិងជាងចម្លាក់សម័យនោះ ឈ្មោះមូហ៊ាំម៉ាដ់ អ៊ីបនូ អាប៊ី ត៍ហ្ស៊ៀរ កាស្ស៊ីការ គូមី ។ កិច្ចការនេះទាមទាររយៈពេល ៨ ឆ្នាំទើបបានសម្រេចជាស្ថាពរ ។

[4] កាន់យ៉ីណាស់ អាស្ស៊ារ គូម (گنجینه آثار قم) ក្បាលទី ១ ទំព័រ ១០ ។

ក្នុងឆ្នាំ ៩៥០ សករាជហ៊ីុជ្រ៉េះត៍្ (ឆ្នាំសាកល ១៥៤៣) ស្តេច ស្ហ្វាស៍្ តាស៍្ម៉ាស់ព៍ បានសាងបន្ទប់បញ្ចុះព្រះរាជសពពីឥដ្ឋតែងលំអដោយការ៉ូប្រាំពីរពណ៌ជុំវិញព្រះរាជផ្នូរ ។ បន្ទប់មានប្រឡោះសម្រាប់បូជនីយសក៍មើលព្រះរាជផ្នូរ សម្រាប់ដាក់អំណោយនិងលិខិតសំណូម ។
ច្រើនឆ្នាំក្រោយមក ស្តេច ស្ហ្វាស៍្ អាុប់បាស់ បានដាក់បញ្ជាឲ្យដាក់រនាំងដែកនៅពីខាងមុខបន្ទប់បញ្ចុះព្រះរាជសព ។

ក្នុងឆ្នាំ ១២៣០ សករាជហ៊ីុជ្រ៉េះត៍្ (ឆ្នាំសាកល ១៨១៥) ស្តេច ហ្វាត់ហ៊្ច អាុលី ស្ហ្វាស៍្ ក៏្យ៉ាុរ ពាសរនាំងដែកនេះដោយប្រាក់ ។ រនាំងនេះនៅរហូតដល់ខូច ។ ក្នុងឆ្នាំ ១២៨០ សករាជហ៊ីុជ្រ៉េះត៍្ (ឆ្នាំសាកល ១៨៦៤) បន្ទប់ថ្មីត្រូវបានសាងឡើងដោយយកប្រាក់ពីបន្ទប់ចាស់មកប្រើ និងដោយបន្ថែមប្រាក់ពីរតនាគារ ។ បន្ទប់នេះជាជំនួសបន្ទប់ចាស់ទាំងអស់ ។



**បន្ទប់ចាស់ជុំវិញព្រះរាជផ្នូរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្ហូម៉ាស់ سلام الله عليها**

បន្ទប់ថ្មីនេះនៅយូរអង្វែងពីលើព្រះរាជផ្នូរព្រះនាង ហ្វាទិម៉ាស់ ម៉ាក់ស៊ូម៉ាស់ﷺ ត្រូវបានជួសជុលតាមការចាំបាច់ រហូតដល់ឆ្នាំ ១៣៦៨ សករាជហ៊ិជ្រ៉ោះត៍ (ឆ្នាំសាកល ១៩៤៩)។ បន្ទាប់មក លោកអ្នកថែរក្សាបានដាក់បញ្ជាឲ្យសាងបន្ទប់ថ្មីដោយមានសណ្ឋានខុសពីមុន ជួសបន្ទប់ចាស់។ ជាង ៤០ ឆ្នាំក្រោយមក ដោយសារកំណើនបូជនីយេសក៍មកកាន់ព្រះបូជនីយចេតិយ និងការខូចខាត

តាមធម្មជាតិ រនាំងបាំងបន្ទប់ព្រះរាជផ្នូររងការរបេះរបោច។

ម្យ៉ាងទៀត ឈើដែលគេបានដាក់នៅខាងក្នុងបន្ទប់ជាងមួយរយឆ្នាំរងការខូចខាតខ្លាំង។ សំខាន់លើសនេះ ការលាងបន្ទប់ដោយទឹកផ្កាជានិច្ចជាកាលធ្វើឲ្យបន្ទប់មានពណ៌ក្រហម មានស្នាមប្រេះនៅលើគ្រឹះ។ បន្ទប់រងការខូចខាតច្រើនចាំបាច់ត្រូវតែផ្លាស់ប្តូរ។

លោកអ្នកថែរក្សាព្រះពូជនីយចេតិយ អាយ៉ាទុលឡោះហ្វ៍ ម៉ាស់អ៊ូឌី បានសម្រេចចិត្តផ្លាស់បន្ទប់បញ្ចុះព្រះរាជសពក្នុងឆ្នាំ ១៤១៥ សករាជហ៊ិជ្រ៉ោះត៍ (ឆ្នាំសាកល ១៩៩៥)។ គេបានប្រគល់មុខការគូរប្លង់បន្ទប់ថ្មីឲ្យទៅលោកអ្នកឯកទេស អាកុា ហ៊្វូសៃន៍ ប៉ារវារេស្ហ អ៊ិស្វហ្វាហានី។ លោកបានទទួលអនិច្ចកម្មមុនចប់កិច្ចការ លោក អាកុា មូហ៊ាំម៉ាដ់ ហ៊្វូសៃន៍ អុាប់បាស់ពូរ អ៊ីស្វហ្វាហានីបានបញ្ចប់កិច្ចសាងបន្ទប់ថ្មីនេះ។



**បន្ទប់ (ضَريح) ថ្មីជុំវិញព្រះរាជផ្នូរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្សូម៉ាស់ سلام الله عليها**

មានការផ្លាស់ប្តូរខ្លះ ក្នុងការសាងសង់បន្ទប់បញ្ចុះព្រះរាជសពលំដាប់ចុងក្រោយនេះ គឺ៖

-កំណាព្យ និងឃ្លោងឃ្លាកាព្យដែលបានចារនៅប៉ែកខាងលើបន្ទប់ចាស់នោះត្រូវបានប្រមូលមកចារដោយអក្សរមាសនៅលើដំបូលបន្ទប់ថ្មី ។

-ប៉ែកនៅចន្លោះដំបូលបន្ទប់ និងប៉ែកដែលបូជនីយេសក៏អាចបានទៅមកបានកាលពីមុនដែលធ្វើពីប្រាក់ ត្រូវផ្លាស់ដោយមាស ។

-បន្ទប់ខាងលើនិងបំពង់ទីបដែលមាន ៥០០០ ដុំមូលត្រូវផ្លាស់ចេញ ហើយធ្វើឲ្យក្រាស់និងមាំជាងមុនៗ ។ តែចំពោះតែប៉ែកនេះ គេបានប្រើប្រាក់សុទ្ធ ២០០ គីឡូក្រាម ។

-គ្រឿងចាស់ដែលធ្វើអំពីឈើ មើលមិនឃើញនោះ ក៏ត្រូវផ្លាស់ចេញដែរដោយឈើល្អជាងមុន ។

បន្ទប់មានកម្ពស់ ៤ ម៉ែត្រ បណ្ដោយ ៥,២៥ ម៉ែត្រ ទទឹង ៤,៧៣ ម៉ែត្រ ។ មើលពីក្រៅ បន្ទប់ថ្មីដូចជាមិនសូវខុសពីបន្ទប់ចាស់ប៉ុន្មាន តែមាំជាង ជាប់និងបិតថេរជាង ។

ការស្ថាបនាទាំងអស់នេះថ្លៃប្រមាណ ៣ ០០០ ០០០ ០០០ រីយ៉ាល (ریال) អ៊ីរ៉ង់ស្មើនឹងប្រមាណ £២៥០ ០០០ ។

គ្រោងការស្ថាបនានេះទាមទារពេលវេលា ៥ ឆ្នាំទើបបានសម្រេចជាស្ថាពរ ។ ដោយសារជាងសំណង់បំពេញកិច្ចការរហ័សរហួនបីមុខការក្នុងមួយថ្ងៃ សំណង់បន្ទប់ថ្មីនៃព្រះរាជសពបានហើយស្រេចបាច់ក្នុងមួយខែ ដើម្បីនឹងមិនរំខានដល់បូជនីយេសក៏លើសពីចាំបាច់ ។

អាយ៉ាទុល្លោះហ៍ មូហ៊ាំម៉ាដ់ តាគ្គី បាស្វយ៉ាត់ បានបើកបន្ទប់ថ្មីនៃព្រះរាជសពឲ្យសាធារណជនឡើងវិញក្នុងថ្ងៃ កុំដៀរ ឆ្នាំ ១៤២២ (ឆ្នាំសាកល ២០០១) សកររាជហ៊ិច្ចរ៉េាះត៍ ។

## ៣.៦ ព្រះបូជនីយចេតិយក្នុងបច្ចុប្បន្ន

ផ្ទៃដីព្រះបូជនីយចេតិយមានទំហំ ១៣ ០០០ ម៉ែត្រក្រឡា ដោយរាប់បញ្ចូលបន្ទប់បញ្ចុះព្រះរាជសព (ضَريح) សំយាប សាល ទីធ្លាទាំងបី ម៉ាស់យ៉ិដ្ធដើមទាំងពីរ (ម៉ាស់យ៉ិដ្ធ បាឡាសារ និង ម៉ាស់យ៉ិដ្ធ គ៉ូបាត៍បាអ៊ី)

ថ្មីៗនេះ ម៉ាស់យ៉ិដ្ធថ្មីមួយ (ម៉ាស់យ៉ិដ្ធ អាក្ដុស្ហាំ (مسجد اعظم)) សាងសង់ដោយម៉ារយ៉ា (مَرجَع) អាយ៉ាទុល្លោះហ៍ ប៊ូរូយ៉ារឌី (البروجردي) ត្រូវភ្ជាប់នឹងបូជនីយដ្ឋាន ។ ទំហំផ្ទៃដីថ្មីរបស់ព្រះបូជនីយចេតិយនេះលើសពី ២៥ ០០០

ម៉ែត្រក្រឡា ។ ផ្ទះរបស់លោកស្ថិតនៅមាត់ផ្លូវចូលម៉ាស់ឃ៊ិដដែលលោកបាន សាងនោះ ។

នៅក្នុងម៉ាស់ឃ៊ិដនេះ លោកអ្នកប្រាជ្ញបច្ចុប្បន្នផ្តល់វគ្គសិក្សាដល់បណ្ឌានិស្សិត ដែលមានចំណេះកម្រិតខ្ពស់ស្រាប់ហើយ ។ ម៉ាស់ឃ៊ិដនេះជាកន្លែងធ្វើសក្ការជុំគ្នាដែរ ។ ត្រង់ចន្លោះម៉ាស់ឃ៊ិដ អាក់ស្ទាំ និងព្រះរាជផ្ទះព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ ﷺ មានម៉ាស់ឃ៊ិដមួយទៀតដែលហៅថា បាឡាសារ ។ នៅទីនេះ មានផ្ទះលោកអ្នកប្រាជ្ញល្បីៗសម័យមុនច្រើននាក់ គឺ៖

-អាយ៉ាទូលឡោះហ្វ៍ ស្ហេខ៍ អាប់ដ្វាល់-ការីម អាល់-ហ្វាអ៊ីរី (عبد الكريم الحائري)
-អាយ៉ាទូលឡោះហ្វ៍ ស្ហេខ៍ មូហាំម៉ាដ់ អាលី អារ៉ាគី (محمد علي أراكي)
-អាយ៉ាទូលឡោះហ្វ៍ សៃយីដ មូហាំម៉ាដ់ រីដ្ហ៍ អាល់-គុលប៉ៃកានី (محمد رضا الكلبيكاني)
-អាយ៉ាទូលឡោះហ្វ៍ សៃយីដ ស្វាដ់រ៍ អាល់-ឌីន អាល់-ស្វាដ់រ៍ (صدر الدين الصدر)
-អាយ៉ាទូលឡោះហ្វ៍ សៃយីដ មូហាំម៉ាដ់ តាគ្គី ខ៉ាវ៉ាន់សារី (سيد محمد تقى خوانسارى)
-អាយ៉ាទូលឡោះហ្វ៍ សៃយីដ មូហាំម៉ាដ់ ហាសាន់ អាល់-ស៊ីរ៉ាស៊ី (السيد محمد حسن الحسيني الشيرازي)
-អ៊ូឡាម៉ាស់ សៃយីដ មូហាំម៉ាដ់ ហ៊្វូសៃន៍ អាល់-ត៉ាបាត៉ាបាអ៊ី (العلامة السيد محمد حسين الطباطبائي)
-ស្ហាហ៊ីដ ស្ហេខ៍ មូរតាដ្ហ៍ អាល់-តោះហ្វ៍ហារី (الشهيد الشيخ مرتضى المطهري)



**ផ្នូររបស់អាយ៉ាទុលឡោះហ្ស៍នៅក្នុងម៉ាស់យ៉ិដ្ ឋាឡាសារ នៅក្នុងព្រះចេតិយព្រះនាង ហ្វាទីម៉ាស្ ម៉ាក់ស្ហ៍ម៉ាស៊ូ ﷺ**

## ៣.៧ ដោមមាស

ឆ្នាំ ១២១៨ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ១៨០៣) ស្តេច ហ្វាត់ហ៍ អាលី ស្ហាស់ ក៏យ៉ារ បានតែងតាំងគណៈកម្មការធ្វើដោមមាសដំបូងលើព្រះចេតិយព្រះនាង ហ្វាទីម៉ាស្ ម៉ាក់ស្ហ៍ម៉ាស៊ូ ﷺ ដោយប្រើឥដ្ឋជ្រលក់ទឹកមាសចំនួន ១២០០០ ដុំ ។ ដោមមិនត្រូវផ្លាស់ប្តូរអស់រយៈពេលជាង ២០០ ឆ្នាំ ។

ឆ្នាំ ១៤២១ សករាជហ៊ិជ្រ៉េះត៍ (ឆ្នាំសាកល ២០០០) គេបានធ្វើគម្រោងការផ្លាស់ប្តូរដោម ។ ហេតុការណ៍បានកើតឡើងដូចតទៅ ។ អាយ៉ាទុលឡោះហ្ស៍ ម៉ាស់អ៊ូឌី អ្នកថែរក្សាព្រះបូជនីយចេតិយ បានឲ្យដឹងថា៖ "ថ្ងៃមួយខ្ញុំបានទៅពិនិត្យមើលដោម ។ ខ្ញុំបានឃើញថាមាសរបកដោយកន្លែង ឥដ្ឋនៅប៉ែកខាងក្រោមចាស់ទ្រុឌទ្រោម ។ គេបានសួរយោបល់លោកអ្នកឯកទេស ។ បន្ទាប់ពី

បានពិភាក្សាគ្នា លោកអ្នកឯកទេសបានឲ្យយោបល់ថាជួសជុលដោមមាសមិនកើតទេក្នុងសភាពនេះ ។ ចាំបាច់ត្រូវពាសដោមដោយស្ពាន់សិនមុននឹងអាចដាក់មាសពីលើដោមបាន ។ គេបានគណនាឃើញថាអាចយកមាសមកពីដោមចាស់វិញបាន ២០ គីឡូក្រាម តែការជួសជុលទាមទារស្ពាន់ចំនួន ១០ តោន មាស ២៤ ការ៉ាត់ ចំនួន ២០០ គីឡូក្រាម ត្រូវចំណាយប្រាក់សាមសិបពាន់លានប្រាក់រីយ៉ាល់ (ស្មើនឹង £៣ ០០០ ០០០០) ។

នៅក្នុងកិច្ចប្រជុំសម្ងាត់ ជាមួយបណ្ដាអស់លោកដែលដឹងរឿងនេះ ថ្លៃចំណាយត្រូវបានលើកយកមកពិភាក្សា ។ ខ្ញុំបានថា៖ "ខ្ញុំមិនអាចទទួលខុសត្រូវរកថវិកាថ្លៃចំណាយនេះបានទេ ។ ម្យ៉ាងទៀត ខ្ញុំមិនអាចទទួលកិច្ចការនេះបានទេព្រោះខ្ញុំមានវ័យចំណាស់ហើយ ។"

ច្រើនថ្ងៃក្រោយមក ខ្ញុំបានទៅជួប អាយ៉ាតុលឡោះហ្វ៍ អ៊ុស្ម៉ា មូហាំម៉ាដ់ តាគ្គី បាស្ហ៍យ៉ាត់ (العظمى محمد تقی بهجت) ដើម្បីពិភាក្សារឿងកសាងដោមឡើងវិញ ។ លោកមិនបានដឹងជាមុនទេថាខ្ញុំមកជួបលោក ។

ខ្ញុំឆ្ងល់ណាស់ បន្ទាប់ពីបានសម្ដែងសេចក្ដីគួរសម លោកបានសួរសុខទុក្ខខ្ញុំ ហើយបានសួរខ្ញុំដោយខ្លួនឯងថា៖ "ហេតុអ្វីដោមព្រះនាង ហ្វាទីម៉ាស្ហ៍ ម៉ាក់ស៊្ហូម៉ាស្ហ៍ عليها سلام الله មិនជាប់ ? ដោមចាស់ណាស់ ។ សូមលោកចាប់ផ្ដើមធ្វើការនេះ ។ អល់ឡោះហ៊្វ عزّ و جلّ នឹងផ្ដល់ថវិកាសម្រាប់កិច្ចការនេះ ។ ព្រះអង្គ عزّ و جلّ នឹងឲ្យលោកមានអាយុវែងដែរ ។"

ខ្ញុំឆ្ងល់ណាស់ពីព្រោះរឿងសាងសង់ឡើងវិញ បញ្ហាថវិកាពាក់ព័ន្ធនឹងការសំណង់នេះនិងការបម្រុងទុករបស់ខ្ញុំ មិនបានឲ្យសាធារជនដឹងទេ ។ វាជាបញ្ហាដែលពុំមានអ្នកណាទេក្រៅពីអស់លោកដែលបានចូលរួមក្នុងកិច្ចប្រជុំដំបូង ។ ខ្ញុំបានតបថា៖ "ចំណាយក្នុងសំណង់នេះថ្លៃណាស់ ។ ឥឡូវៗនេះយើងពុំមានថវិកាគ្រប់គ្រាន់ទេ ។" ច្រើនថ្ងៃក្រោយមក អាយ៉ាតុលឡោះហ្វ៍ បាស្ហ៍យ៉ាត់ បានទាក់ទងខ្ញុំ លោកមានប្រសាសន៍ថា៖ "លោកចាប់ផ្ដើមការសាងសង់ទៅ ។ អល់ឡោះហ៊្វ عزّ و جلّ នឹងផ្ដល់ថវិកាសម្រាប់ការនេះ ។ ចន្លោះពេលនេះ ចូរលោកប្រាប់

លោកអគ្គប្រមុខអ៊ីរ៉ង់ អាទ្ទុលឡោះហ្ ខ៍ម៉ានេអ៊ី ឲ្យដឹងចុះ ។"

ខ្ញុំបានទៅការិយាល័យលោកអគ្គប្រមុខ បានអធិប្បាយជម្រាបលោកឲ្យជ្រាបរឿងនេះ ។ លោកអគ្គប្រមុខបានតបថា៖ "ខ្ញុំយល់ព្រមនឹងការណែនាំផ្ដាំផ្ញើទាំងអស់របស់អាយ៉ាទ្ទុលឡោះហ្ បាស្ញ៉ាត់ ។"

បន្ទាប់ពីលោកអគ្គប្រមុខយល់ព្រមហើយ ខ្ញុំក៏បានសម្រេចចាប់ផ្ដើមការសាងសង់ដោមព្រះនាង ហ្វាទ្វីម៉ាស្ ម៉ាក់ស៊្វូម៉ាស្ ﷺ ។ អាយ៉ាទ្ទុលឡោះហ្ បាស្ញ៉ាត់ បានប្រគល់ប្រាក់ចំនួន ១០០ ០០០ ០០០ រីយ៉ាល់ឲ្យមកខ្ញុំនិងមាសមួយចំនួនដើម្បីចាប់ផ្ដើមការសំណង់ ។[5]



**ដោមមាសចាស់ព្រះចេតិយព្រះនាង ហ្វាទ្វីម៉ាស្ ម៉ាក់ស៊្វូម៉ាស្ ﷺ**

[5] ដកស្រង់ពីកាសែតប្រចាំខែ[នៃព្រះបូជនីយស្ថាន]ហ្ការ៉ម ប៉ាយ៉ាំ អាស្តាន (پیام آستان) ២៣/០៩/១៣៧៩ ហ៊ីជ្ចរី ស្ញាំស៊ី (هجری شمسی) ទំព័រ ៥ ។

ការសំណង់បានចាប់ផ្ដើមដើមឆ្នាំថ្មីអ៊ីរ៉ង់ កាលពីពីរឆ្នាំមុន នៅតែបន្តទៅទៀតសព្វថ្ងៃនេះ (ទសវត្សរ៍ ២០០០) ។ យើងសង្ឃឹមថានឹងបានសម្រេចជាស្ថាពរក្នុងឆ្នាំ ១៤២៦ សករាជហ៊ីជ្រ៉ោះត៍ (ឆ្នាំសាកល ២០០៥) អ៊ីនស្ហា អល់ឡោះហ៍ ﷻ ។ របាយការណ៍អំពីដំណើរការសាងសង់ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែតប្រចាំខែ[នៃព្រះបូជនីយស្ថាន]ហ្ពាម ប៉ាយ៉ាំ អាស្តាន (پیام آستان) ។

សារៈសំខាន់ក្នុងការថែរក្សាជាប់លាប់ និងការអភិរក្សព្រះបូជនីយស្ថានត្រូវបានបញ្ជាក់ដោយព្រះសាស្តា ﷺ នៅក្នុងពាក្យពេចន៍ព្រះអង្គ ﷺ កាលព្រះអង្គ ﷺ បានប្រាប់អ៊ីមុាំ អាលី صلوات الله عليه والسلام ថា៖

يا عَليُّ مَنْ عَمَّرَ قُبورَكُمْ وَتَعاهَدَها، فَكَأنَّما اَعَانَ سُلَيْمانَ ابْنَ داوُدَ عَلى بِناءِ بَيْتِ الْمُقَدَّس. (بحار الأنوار - الجزء : ١٠٠ صفحة : ١٢١ الحديث: ٢٢)

"អាលី صلوات الله عليه والسلام អើយ ! អ្នកណាថែរក្សាជាប់លាប់ ជួសជុល ស្ថាបនាឲ្យល្អឡើងវិញផ្នូរអស់ទាំងអ្នក عليهم السلام ព្រមលះបង់ខ្លួនជានិច្ចក្នុងកិច្ចការនេះ ដូចអ្នកនោះបានជួយស៊ូឡៃម៉ាន عليه السلام ប៊ិន ដាវុដ عليه السلام សាងសង់ព្រះបូជនីយដ្ឋានមហាគ្រឹះ បៃត៍អាល់-មូកទ្ទដ៉ស ដែរ ។"[6]

# ៣.៨ អក្សរចារឹកនៅក្នុងព្រះបូជនីយដ្ឋាន

នៅលើផ្ទៃជញ្ជាំងអគារព្រះបូជនីយដ្ឋានមានចំណារកំណាព្យ ពាក្យពេចន៍ហាឌីស្ហនិងអាយ៉ាស់គួរអាន ដោយលាយលក្ខណ៍អក្សរផ្សេងៗ ដោយប្រើវត្ថុធាតុផ្សេងៗ ។ ចំណារទាំងនេះតាក់តែងជញ្ជាំង ដំបូលរោងនិងតួប៉ម ។ សូមលើកយកមកនូវគំរូចំណារអក្សរខ្លះក្នុងវគ្គតទៅនេះ ដើម្បីឲ្យលោកអ្នកអានបានស្គាល់ត្រួសៗ ។

[6] ប៊ីហ្ពារ អាល់-អាន់វ៉ារ (بحار الأنوار) ក្បាលទី ១០០ ទំព័រ ១២១ ។

## ៣.៩ អក្សរចារឹកនៅក្នុងដោម

ប៉ែកខាងក្នុងដោមនិងនៅក្នុងបន្ទប់បញ្ចុះព្រះរាជសព ដែលបានសម្ភោធក្នុងឆ្នាំ ១២៤០ សករាជហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ១៨២៤) មានចំណារកំណាព្យជាអក្សរផ្ចង់ក្បាច់ ណាស់តាក់លិក្ទ (نستعليق) ស្នាដៃករបស់កវី ហ្វាត់ហ៊្ អ៊ុលី ខាន ស្វ៊ាបា (فتح على خان صبا) ។ កំណាព្យទាំងពីរសម្តែងនូវថោមនាការដល់ព្រះនាងហ្វាទីម៉ាស្ ម៉ាក់ស៊្ហូម៉ាស្ عليها السلام និង អាស្ហ៍លុល-បៃត៍ عليهم السلام ។

ប៉ែកខាងក្នុងដោម គេបានសាងឡើងដោយប្រើបន្ទះការ៉ូរលោងចម្រុះពណ៌ ។ នៅពីលើផ្ទៃពណ៌ផ្ទៃមេឃរលោង គេចារអាក្សរផ្ចង់ក្បាច់ ស្ហ៊ុលុស្ហ (ثُلث) ពាក្យពេជន៍ហ៉ាឌីស្ហដូចតទៅជាភាសាអារ៉ាប់ (ពាក្យពេចន៍ហ៉ាឌីស្ហរាយការណ៍ដោយលោកអ្នកប្រាជ្ញ ស្ហ៊ីអ៊ុស្ និង អាស្ហ៍លុល-ស៊ុនណាស្) គឺ៖

روى الزّمخشري في تفسيره الموسوم بالكشّاف والثّعلبي في تفسيره الموسوم بكشف البيان، عن رسول الله (ص) قال: ألا ومن مات على حبّ آل محمّد مات شهيداً، ألا ومن مات على حبّ آل محمّد مات مغفوراً، ألا ومن مات على حبّ آل محمّد مات مؤمناً متكمّلاً، ألا ومن مات على حبّ محمّد وآل محمّد بشّره ملك الموت ونكير ومنكر بالجنّة، ألا من مات على حبّ محمّد وآل محمّد زفّ الى الجنّة، ألا من مات على حبّ محمّد وآل محمّد فتح الله له فى قبره بابين الى الجنّة، ألا ومن مات على حبّ محمّد وآل محمّد جعل الله قبره مزار ملائكة الرّحمة، ألا ومن مات على بغض محمّد وآل محمّد جاء يوم القيامة مكتوب بين عينيه آيس من رحمة الله، ألا ومن مات على بغض آل محمّد مات كافراً، ألا ومن مات على بغض آل محمّد لم يشمّ رائحة الجنّة.

មានន័យថា៖

លោក អាល់-ស្ហាម៉ាក់ស្ហារី បានរាយការណ៍នៅក្នុងតាហ្វ៍សៀរលោក អាល់-កាស្ហ៍ស្ហាហ្វ៍ និងលោក ស្ហាក់ឡាប៊ី បានរាយការណ៍នៅក្នុងតាហ្វ៍សៀរលោក កាស្ហ៍ស្ហាហ្វ៍ អាល់-បាយ៉ាន តមកពីរ៉ស៊ូលុលឡោះហ្វ៍ صلى الله عليه وآله وسلم ថា៖ "ចូរដឹងថាអ្នក

ណាស្លាប់ដោយស្រឡាញ់ព្រះរាជវង្សعليهم السلامរបស់មូហាំម៉ាដ់ﷺ អ្នកនោះស្លាប់ក្នុងឋានៈទុក្ករបុគ្គល ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់ព្រះរាជវង្សعليهم السلامរបស់មូហាំម៉ាដ់ﷺ អ្នកនោះស្លាប់ក្នុងឋានៈបុគ្គលដែលត្រូវលើកលែងទោសឲ្យ ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់ព្រះរាជវង្សعليهم السلامរបស់មូហាំម៉ាដ់ﷺ អ្នកនោះស្លាប់ក្នុងឋានៈជាអ្នកមានជំនឿ ជាបុគ្គលសុក្រឹត ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់មូហាំម៉ាដ់ﷺ និងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហាំម៉ាដ់ﷺ ទេវតាយកព្រលឹងعليه السلامនិងទេវតាទាំងពីរ ណាកៀរعليه السلام និង មុនការعليه السلام នឹងប្រាប់ដំណឹងល្អអំពីឋានសួគ៌ឲ្យអ្នកនោះជ្រាប (ថាអ្នកនោះបានចូលឋានសួគ៌) ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់មូហាំម៉ាដ់ﷺ និងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហាំម៉ាដ់ﷺ គេនឹងលើកអ្នកនោះទៅដាក់ក្នុងឋានសួគ៌ ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់មូហាំម៉ាដ់ﷺនិងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហាំម៉ាដ់ﷺ អល់ឡោះហ៍عزّ وجلّនឹងបើកទ្វារពីរទៅកាន់ឋានសួគ៌នៅក្នុងផ្នូរអ្នកនោះ ។ ចូរដឹងថាអ្នកណាស្លាប់ដោយស្រឡាញ់មូហាំម៉ាដ់ﷺ និងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហាំម៉ាដ់ﷺ អល់ឡោះហ៍عزّ وجلّនឹងទុកផ្នូរអ្នកនោះជាបូជនីយដ្ឋានជាទីគោរពសម្រាប់អស់ទេវតានៃព្រះមេត្តាធម៌ ។ ចូរដឹងថាអ្នកណាស្លាប់ក្នុងឋានៈជាសត្រូវមូហាំម៉ាដ់ﷺនិងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហាំម៉ាដ់ﷺ ថ្ងៃជំនុំជម្រះ គេនឹងចារនៅចន្លោះភ្នែកទាំងពីររបស់អ្នកនោះថា៖ "បុគ្គលនេះមិនសង្ឃឹមនឹងបាននូវព្រះមេត្តាធម៌របស់អល់ឡោះហ៍عزّ وجلّទេ ។" ចូរដឹងថាអ្នកណាស្លាប់ក្នុងឋានៈជាសត្រូវរបស់ព្រះរាជវង្សعليهم السلامរបស់មូហាំម៉ាដ់ﷺ អ្នកនោះស្លាប់ក្នុងឋានៈជាមនុស្សអសទ្ធា (កាហ្វៀរ) ។ ចូរដឹងថាអ្នកណាស្លាប់ក្នុងឋានៈជាសត្រូវរបស់ព្រះរាជវង្សعليهم السلامរបស់មូហាំម៉ាដ់ﷺ អ្នកនោះនឹងពុំបានធុំក្លិនឋានសួគ៌ទេ ។

នៅពីក្រោមដោម មានចារថា៖

اَللّٰهُمَّ صَلِّ عَلَى الْمُصْطَفى مُحَمَّدٍ، والمرتضى عليٍّ، والبتول فاطمة، والسّبطين الحسن والحسين، وزين العابدين علي، والباقر محمّد، والصّادق جعفر، والكاظم موسى، والرّضا علي، والتّقي محمّد، والنّقي علي،

والزكيّ الحسن، والحجّة القائم المهدي صاحب الزّمان، ائمَة الهُدى ومصابيح الدّجى، بهم أتولّى، ومن أعدائهم اتبرّءُ

បកប្រែថា៖

អល់ឡោះហ្ទ័(عزّ وجلّ)អឺយ! សូមព្រះអង្គ(عزّ وجلّ)ប្រសិទ្ធព្រះពរដល់ទៅ អាល់-មុស្ទ្វ័ហ្វា មូហាំម៉ាដ្ឋ(صلى الله عليه وآله وسلم) ដល់ទៅ អាល់-មូរតាឌ្ហ៍ អាុលី(صلوات الله عليه والسلام) ដល់ទៅ អាល់-បាទុល ហ្វាទីម៉ាស្ទ(سلام الله عليها) ដល់ទៅព្រះរាជនត្តាទាំងពីរ[របស់ព្រះសាស្តា(صلى الله عليه وآله وسلم)] អាល់-ហាសាន់(صلوات الله عليه والسلام) និង អាល់-ហ៊ូសែន៍(صلوات الله عليه والسلام) ដល់ទៅ ស៊ែណាល់ អាុប៊ីឌីន អាុលី(صلوات الله عليه والسلام) ដល់ទៅ អាល់-បាគៀរ មូហាំម៉ាដ្ឋ(صلوات الله عليه والسلام) ដល់ទៅ អាល់-ស្វ៉ាឌិក យ៉ាក់ហ្វារ(صلوات الله عليه والسلام) ដល់ទៅ អាល់-កាស្ទុឹម មូសា(صلوات الله عليه والسلام) ដល់ទៅ អាល់-រីឌ្ហ៍ អាុលី(صلوات الله عليه والسلام) ដល់ទៅ អាល់-តាគ្គី មូហាំម៉ាដ្ឋ(صلوات الله عليه والسلام) ដល់ទៅ អាល់-ណាគ្គី អាុលី(صلوات الله عليه والسلام) ដល់ទៅ អាល់-ស្វាក់គី អាល់-ហាសាន់(صلوات الله عليه والسلام) ដល់ទៅ អាល់-ហ៊ុច្ចយ៉ាស្ទ អាល់-ក៏អុឹម(عجل الله فرجك) ម្ចាស់សម័យកាល ។ បុគ្គលទាំងអស់នេះ(عليهم السلام)ជាអុីម៉ាំព្រះមគ្គទេសក៍ដឹកនាំ ជាពន្លឺរស្មីនៅក្នុងអន្ធការ ។ ទូលព្រះបង្គំជាខ្ញុំសូមយកអស់ព្រះអង្គ(عليهم السلام)ជាអាណាព្យាបាល ទូលព្រះបង្គំជាខ្ញុំសូមតាំងខ្លួនជាសត្រូវរបស់ពួកសត្រូវរបស់ព្រះអង្គ(عليهم السلام) ។

## ៣.១០ អក្សរចារឹកនៅពីលើព្រះរាជផ្នូរ

ព្រះរាជផ្នូរត្រូវសាងសង់ឡើង ដោយឥដ្ឋតាក់តែងលំអដោយបន្ទះកែវពណ៌បួនជ្រុង ។ នៅពីលើនោះមានចារ ៖

-អាយ៉ាស្ទ អាល់-គូរស៊ី (២:២៥៥) ដោយប្រើអក្សរផ្ទង់ក្បាច់ ណាស់ខ៍ (نسخ)

-អាយ៉ាស្ទផ្សេងៗ ចារដោយប្រើអក្សរផ្ទង់ទឹកមាសក្បាច់ ណាស់ខ៍ (نسخ)

-អាយ៉ាស្ទផ្សេងៗ ចារដោយប្រើអក្សរផ្ទង់ក្បាច់ (كوفي)

-ស៊ូរ៉ោះត៍ អាល់-មុលក៍ ចារដោយប្រើអក្សរផ្ទង់ទឹកមាសក្បាច់ ណាស់ខ៍ (نسخ)

-អាយ៉ាស្ទគួរអានច្រើនទៀត ។

នៅពីក្រោមចំណារ មានចារជាអក្សរផ្ចង់ក្បាច់ ណាស់ខ៍ (نسخ) ថា៖ "សរសេរនិងឆ្លាក់អក្សរដោយ មូហ៊ាំម៉ាដ់ អ៊ីបនូ អាប៊ី ត៍ហ្វៀរ អ៊ីបនូ អាប៊ី អាល់-ហ៊្វសៃន៍ ។"



**ព្រះរាជផ្នូរព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊្វម៉ាស់** سلام الله عليها

នៅពីលើបន្ទះការ៉ូកែវជុំវិញព្រះរាជផ្នូរ ពីលើដល់ក្រោម មានឆ្លាក់ ៖
-ស៊ូរ៉ោះត៍ យ៉ាស៊ីន
-ស៊ូរ៉ោះត៍ អាល់-រ៉ោះហ្មា៍ម៉ាន
-ស៊ូរ៉ោះត៍ អាល់-មុលក៍
-ស៊ូរ៉ោះត៍ ហ្វាល់ អាត៍ (هل اتی ស៊ូរ៉ោះត៍ អាល់-អ៊ីនសាន)
-ស៊ូរ៉ោះត៍ អាល់-ក្វដ់រ៍
និងពាក្យពេចន៍ហា្ឌីស្ស៍ព្រះសាស្តា صلى الله عليه وآله وسلم ច្រើនទៀត មានដូចតទៅ ៖[7]
*ហា្ឌីស្ស៍ ១

[7] ដកស្រង់ពី ហ៊ាដ់រ៉ត់ ម៉ាក់ស៊្វម៉ាស់ ហ្វាទីម៉ាស់ ឌូវម (حضرت معصومه فاطمه دوم) ទំព័រ ២២៧ និង ២២៨ ។

قالَ النَّبِي (ص): مَنْ كَفَّ لِسانَهُ عَنْ اَعْراضِ النّاسِ، اَقالَهُ اللهُ عَثْرَتَهُ يَوْمَ الْقِيامَةِ

"អ្នកណាទប់មាត់ មិននិយាយអាក្រក់អំពីអ្នកដទៃទេ ថ្ងៃជំនុំជម្រះ អល់ឡោះហ៍ ﷻ នឹងអត់ឱនឲ្យដែលបានប្រព្រឹត្តខុស ។"

*ហ្ហាឌីស្ន ២

مَنْ فَرَّقَ بَيْنَ وَالِدَةٍ وَوَلَدِها، فَرَّقَ اللهُ بَيْنَهُ وَبَيْنَ الْجَنَّةِ

"អ្នកណាធ្វើឲ្យម្តាយនិងកូនបែកបាក់គ្នា អល់ឡោះហ៍ ﷻ នឹងឲ្យអ្នកនោះបែកចាកពីឋានសួគ៌ ។"

*ហ្ហាឌីស្ន ៣

حُسْنُ السّؤالِ نِصْفُ الْعِلْمِ

"សំណួរត្រូវជាពាក់កណ្តាលនៃចំណេះ ។"

*ហ្ហាឌីស្ន ៣

اللهُ تَعالى عَوْنُ الْعَبْدِ ما دامَ الْعَبْدُ في عَوْنِ اَخيهُ

"អល់ឡោះហ៍ تعالى ជួយអ្នកណាដែលជួយបងប្អូនខ្លួន ។"

## ៣.១១ អព្ភូតហេតុអស្ចារ្យបានកើតឡើងនៅឯព្រះចេតិយ

ព្រឹត្តិការណ៍អស្ចារ្យបានកើតឡើងនៅឯព្រះបូជនីយចេតិយព្រះនាង ហ្វាទីម៉ាស់ម៉ាក់ស្ហ៊ូម៉ាស់ عليها السلام រៀងសតវត្សរ៍ ។ បូជនីយេសក៍មកទីនេះដោយប៉ងនឹងបាននូវពរពីមហាស្ត្រីថ្លៃថ្លាអង្គនេះ គេមិនដែលខកចិត្តទេ ។ គេកត់ត្រាទុកព្រឹត្តិការណ៍អស្ចារ្យយ៉ាងហ្មត់ចត់ក្នុងការិយាល័យពិសេស នៅក្នុងព្រះបូជនីយដ្ឋាន ។ ព្រឹត្តិការណ៍អស្ចារ្យខ្លះ ត្រូវបានចេញផ្សាយនៅក្នុងកាសែតប្រចាំខែនៃព្រះបូជនីយដ្ឋាន ប៉ាយ៉ាំ អាស្តាន (پيام آستان)

ព្រឹត្តិការណ៍អស្ចារ្យច្រើនដែលបានកើតឡើងនៅឯព្រះមហាបូជនីដ្ឋាននេះ មិនលើកយកមកអធិប្បាយទាំងអស់បានទេ ។ ក្រៅពីព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្ហូម៉ាស្ញ់ﷺ ព្រឹត្តិការអស្ចារ្យឯទៀតបានកើតឡើងនៅឯបូជនីយដ្ឋានវរបុរស អ៊ីម៉ាម រ៉ោះ នៅឯការបាឡាអ៊្វ័ និងព្រះនាង ស៊ែយណាប់ﷺ នៅឯនគរដ្ហាម៉ាស់ ។ តទៅនេះសូមលើកឡើងនូវព្រឹត្តិការអស្ចារ្យខ្លះមកជូនលោកអ្នកអាន ។

# ១. ព្យាបាលដំបៅរលួយ

បុរសម្នាក់ឈ្មោះ មៀរស៊្សា អាសាឌុលឡោះហ្វ៍ (ميرزا أسد الله) មុខងារជាឆ្មាំព្រះបូជនីយដ្ឋានព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្ហូម៉ាស្ញ់ﷺ កើតរោគលំបៅរលួយនៅលើជើងម្ខាង ។ រោគនេះបានក្លាយទៅជាធ្ងន់ដល់ថ្នាក់គ្រូពេទ្យស្នើឲ្យកាត់ជើងនោះចោលដើម្បីកុំឲ្យរោគរាលដាល ។

យប់មុនថ្ងៃចូលមន្ទីរពេទ្យវះកាត់ជើង លោក មៀរស៊្សា អាសាឌុលឡោះហ្វ៍ បានសម្រេចចិត្តទៅឯព្រះរាជបូជនីយដ្ឋានព្រះនាង ហ្វាទីម៉ាស្ញ់ ម៉ាក់ស៊្ហូម៉ាស្ញ់ﷺ ធ្វើនមស្ការចំពោះអល់ឡោះហ្វ៍ عزوجل សូមនូវជំនួយអព្ភូត ។ លោកធ្វើនមស្ការដោយស្មោះអស់ពីចិត្តចំពោះអល់ឡោះហ្វ៍ عزوجل នៅក្នុងព្រះរាជបូជនីយដ្ឋានក្នុងពេលយប់ជ្រៅ ទាល់តែគេបិទទ្វារព្រះបូជនីយដ្ឋានលែងទទួលភ្ញៀវ ។ លោកបាននៅក្នុងទីនោះ យំសូមឲ្យព្រះនាងﷺជួយ ។ ស្អែកព្រឹកព្រលឹម ថ្ងៃមិនទាន់រះទេ ឆ្មាំដែលមកបើកទ្វារព្រះបូជនីយដ្ឋានវិញ បានឮលោកស្រែកថា៖ "បើកទ្វារ ! ព្រះនាងﷺចិត្តល្អចំពោះរូបខ្ញុំ បានធ្វើអន្តរាគមន៍ឲ្យខ្ញុំ ខ្ញុំជាហើយ !" ពួកឆ្មាំបានបើកទ្វារ ឃើញលោក មៀរស៊្សា អាសាឌុលឡោះហ្វ៍ ឈរនៅពីក្រោយទ្វា ជាអស់ពីរោគដំបៅរលួយ ។ លោកបាននិយាយរៀបរាប់ព្រឹត្តិការណ៍នោះ រហូតដល់បានជាអស់ពីជម្ងឺថា៖ "នារីថ្លៃថ្លាម្នាក់បានមកក្បែរខ្ញុំ សួរខ្ញុំថា៖ "លោកត្រូវការអ្វី ?" ខ្ញុំ

បានតបថា៖ "ទូលបង្គំចង់ឲ្យជាពីរោគនៅលើជើងទូលបង្គំ ។ សូមព្រះនាងមេត្តាជួយសូមអល់ឡោះហ៍ عزّ وجلّ ឲ្យទូលបង្គំបានជា ឬឲ្យទូលបង្គំបានស្លាប់ ។" ព្រះនាងបានយកចុងកន្សែងព្រះនាងជូតលើជើងខ្ញុំច្រើនដង ហើយថា៖ "អល់ឡោះហ៍ عزّ وجلّ បានឲ្យលោកជាហើយ ។" ខ្ញុំក៏មានអាការប្រសើរឡើងភ្លាមៗ ឯអាការឈឺឥតស្រាកនៅលើជើងខ្ញុំនោះក៏បាត់ភ្លាមដែរ ។ ខ្ញុំបានសួរសូមស្គាល់អត្តសញ្ញាណព្រះនាងៗបានតបថា៖ "ម្ដេចក៏លោកមិនស្គាល់ខ្ញុំ سلام الله عليها ដ្បិតលោកជាឆ្មាំព្រះបូជនីយដ្ឋានខ្ញុំ سلام الله عليها ? ខ្ញុំ سلام الله عليها ហ្វាទីម៉ាស់ سلام الله عليها បុត្រីរបស់ មូសា អ៊ីបនូ យ៉ាក់ហ្វារ صلوات الله عليه والسلام ។""[8]

## ២. មូឡា ស្វដ្រ័ (ملا صدرا) សូមការណែនាំពីព្រះនាង ហ្វាទីម៉ាស់ម៉ាក់ស៊្វម៉ាស់ سلام الله عليها

ស្វដ្រ័ អាល់-ឌីន មូហ៊ាំម៉ាដ អ៊ីបនូ អ៊ីបរ៉ហ៊ីម ស្ស៊ីរ៉ស៊ី ( صدر الدين محمد بن إبراهيم الشيرازي) ដែលគេស្គាល់ឈ្មោះថា មូឡា ស្វដ្រ័ (ملا صدرا) ឬ ស្វដ្រ័ អាល់-មូតាអាល្លីហ៊ីន (صدر المتألهين) ជាទស្សនវិទូល្បីល្បាញមួយរូបក្នុងសម័យស្ដេចត្រកូលស្វ័ហ្វាវីសោយរាជ្យ ។ ក្រោយពីឪពុកលោកទទួលអនិច្ចកម្ម លោកបានចាកមាតុភូមិទៅកាន់ភូមិមួយទៀតឈ្មោះ "កាហ្វាក់ (كهك)" (ក្បែរខេត្តគូម) លោកបានលះបង់ពេលវេលាច្រើនក្នុងការរិះគិតផ្នែកចិត្តសាស្រ្ត និងផ្នែកព្រះធម៌ ។

មូឡា ស្វដ្រ័ តែងតែទៅធ្វើធម្មយាត្រានានគរម៉ាក់កាស់ឥតខាន ។ ពេលត្រឡប់មកពីធ្វើធម្មយាត្រាលើកទី ៧ លោកបានទទួលអនិច្ចកម្មនៅឯស្រុកបាស្វ័រ៉ោះត៍ ឆ្នាំ ១០៥០ សករាជហ៊ីជ្ជរ៉ោះត៍ (ឆ្នាំសាកល ១៦៤០) ។

វណ្ណកម្មផ្នែកអក្សរសាស្រ្តរបស់លោកមានដូចតទៅ គឺ៖

---

[8] អាន់វ៉ារ អាល់-ម៉ាស្ស៊ាអ៊្សាអ៊ីន (أنوار المشعشعين) ក្បាលទី ១ ទំព័រ ២១៦ ។

-ហ៊ីកម៉ាស់ អាល់-មូតាអាលីយ៉ាស់ ហ៊ី អាល់-អាស់ហ្វារ អាល់-អាក់លីយ៉ាស់ អាល់-អារប៊ីអាស់ (الحكمة المتعالية في الأسفار العقلية الأربعة - ដំណើរទាំងបួនរបស់ប្រាជ្ញាញាណ)

-គីតាម អាល់-ម៉ាស្សាអៀរ (كتاب المشاعر - The Book of Metaphysical Penetrations)

-ហ៊ីកម៉ាស់ អាល់-អារស៊ីយ៉ាស់ (الحكمة العرشية-The Wisdom of the Throne)

រាល់គ្រាដែល មូឡា សូដ្រ៉ា ជួបប្រទះបញ្ហាផ្លូវប្រាជ្ញា លោកធ្វើដំណើរទៅកាន់ខេត្តគុម ទៅគោរពព្រះនាង ហ្វាទីម៉ាស់ ម៉ាក់សូម៉ាស់ سلام الله عليها ។ អាស្រ័យការណែនាំរបស់ព្រះនាង سلام الله عليها លោកអាចដោះស្រាយបញ្ហាទាំងនោះបាន ។[9]

សៃយីដ ស្សាហ្វាប់ អាល់-ឌីន អាល់-ម៉ារអាស៊ី អាល់-ណាយ៉ាហ្វី (السيد شهاب الدين المرعشي النجفي) ដែលទទួលអនិច្ចកម្មទៅហើយ ធ្លាប់មានប្រសាសន៍ថា៖ "រាល់គ្រាដែល មូឡា សូដ្រ៉ា ជួបប្រទះបញ្ហាផ្នែកទស្សនវិជ្ជាឬប្រការនីមួយដែលលោកពិបាកយល់ លោកមកកាន់ព្រះបូជនីយដ្ឋានព្រះនាង ហ្វាទីម៉ាស់ ម៉ាក់សូម៉ាស់ سلام الله عليها សូមជំនួយពីព្រះនាង سلام الله عليها ។ អាស្រ័យការជួយជ្រោមជ្រែងរបស់ព្រះនាង سلام الله عليها លោកអាចរកឃើញនូវចម្លើយដែលលោកស្វែងរក ។"[10]

## ៣. ដំណោះស្រាយបញ្ហារបស់ អាយ៉ាតុលឡោះហ៍ ណាយ៉ាហ្វី ដោយព្រះនាង ហ្វាទីម៉ាស់ ម៉ាក់សូម៉ាស់ سلام الله عليها

[9] ស្ហៃខ៍ អាប់បាស់ គុម្មី (الشيخ عباس القمي) ហ្វាវ៉ាអ៊ីដ អាល់-រ៉ាដាវីយ៉ាស់ (الفوائد الرضوية) ទំព័រ ៣៧៩ ។

[10] កាន់យ៉ីណាស់ ដានេស្សម៉ាន់ដាន់ (گنجینه دانشمندان) ក្បាលទី ១ ទំព័រ១៦ និង ៣៩ ។

សែយីដុ ស្វាហ្វាប់ អាល់-ឌីន អាល់-ម៉ារអាស៊ី អាល់-ណាយ៉ាហ្វី ដែលទទួលអនិច្ចកម្មទៅហើយ បានតំណាលថា៖ "កាលខ្ញុំនៅក្មេង ខ្ញុំបានជួបប្រទះពេលលំបាក ។ ពេលលំបាកបំផុតគឺពេលខ្ញុំចង់រៀបការឲ្យកូនស្រីតែពុំមានថវិកាសម្រាប់សម្ភារកូនក្រមុំទេ ។

ទាំងខ្លោចចិត្ត ខ្ញុំបានទៅឯព្រះបូជនីយដ្ឋានព្រះនាង ហ្វាទីម៉ាស្ស៊ុ ម៉ាក់ស៊្វូម៉ាស្ស៊ុ سلام الله عليها ដោយទឹកភ្នែក អង្វរព្រះនាង سلام الله عليها ដោយបន្ទោសថា៖ "ព្រះនាង سلام الله عليها ម្ចាស់ស្ត្រី سلام الله عليها ! ហេតុអ្វីព្រះនាង سلام الله عليها មិនអើពើចំពោះជីវិតទូលបង្គំ ? ឲ្យទូលបង្គំរៀបការឲ្យកូនស្រីបានដូចម្ដេចបើមានតែបាតដៃទទេ ?"

បន្ទាប់ពីបានសុំព្រះនាង سلام الله عليها ដូចនេះ ខ្ញុំបានត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំបានដេករលីវៗ យល់សប្តិឃើញគេគោះទ្វារ ។ ខ្ញុំបានបើកទ្វារ ឃើញគេឈរនៅឯមាត់ទ្វារ ប្រាប់ខ្ញុំថា៖ "ព្រះនាង سلام الله عليها រង់ចាំលោក ។" ខ្ញុំក៏បានទៅឯព្រះបូជនីយដ្ឋានយ៉ាងរួសរាន់ ។

ពេលទៅដល់បរិវេណ ខ្ញុំបានឃើញនារីច្រើននាក់កំពុងបោសសម្អាតសំយាបមាស ! ខ្ញុំបានសួរអស់ស្ត្រីទាំងនោះថាហេតុបោសសម្អាតយ៉ាងហ្មត់ចត់ដូច្នេះ ។ អស់ទាំងស្ត្រីនោះបានប្រាប់ខ្ញុំថាម្ចាស់ស្ត្រីជិតមកដល់ហើយ ។ មិនយូរប៉ុន្មានព្រះនាង ហ្វាទីម៉ាស្ស៊ុ ម៉ាក់ស៊្វូម៉ាស្ស៊ុ سلام الله عليها បានប្រាកដខ្លួនឡើង ។ រូបរាងនិងចរិយាព្រះនាង سلام الله عليها ដូចព្រះអយ្យិកា (យាយ) របស់ខ្ញុំ ព្រះនាង ហ្វាទីម៉ាស្ស៊ុ ស្វាស្ស៊ុរ៉អ៊ុ سلام الله عليها ដែលខ្ញុំធ្លាប់បានឃើញរួចមកហើយបីដងក្នុងយល់សប្តិ ។

ខ្ញុំបានចូលទៅជិតព្រះបិតុលានី سلام الله عليها (ម្ដាយធំ ឬ ម្ដាយមីង) របស់ខ្ញុំ ព្រះនាង ហ្វាទីម៉ាស្ស៊ុ ម៉ាក់ស៊្វូម៉ាស្ស៊ុ سلام الله عليها ហើយខ្ញុំបានថើបដៃព្រះនាង سلام الله عليها ។ ព្រះនាង سلام الله عليها បាននិយាយរកខ្ញុំថា៖ "ស្វាហ្វាប់ អើយ ! អ្នកគិតថាយើងមិននឹកនាដល់អ្នកទេ ? អ្នកគិតថាយើងគ្មានទឹកចិត្ត ធ្វើឲ្យអ្នកត្អូញត្អែរ ? អ្នកនៅក្រោមខ្សែភ្នែកយើងតាំងអ្នកបានមកដល់នគរគុម្មម៉្លេះ ។ យើងបានបំពេញបំណងអ្នកហើយ ។"

ពេលភ្ញាក់ពីដំណេក ខ្ញុំដឹងខ្លួនថាបានប្រព្រឹត្តអគប្បីដែលបានស្ដីបន្ទោសព្រះនាង ហ្វាទីម៉ាស្ស៊ុ ម៉ាក់ស៊្វូម៉ាស្ស៊ុ سلام الله عليها ហើយក៏បានប្រញាប់ទៅកាន់ព្រះបូជនីយដ្ឋានដើម្បីសូមខមាទោស សូមព្រះនាង سلام الله عليها អត់ឱនកុំយកទោសពៃរ៍ ។ ក្រោយពីនោះ

មិនយូរប៉ុន្មាន បញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំក៏មានដំណោះស្រាយ ជីវភាពខ្ញុំក៏ប្រសើរឡើងដែរ ។[11]

នេះគឺអព្ភូតហេតុអស្ចារ្យមួយ ក្នុងបណ្តាអព្ភូតហេតុអស្ចារ្យច្រើនទៀត ពុំអាចលើកយកអធិប្បាយទាំងអស់នៅក្នុងកូនភៅដ៏តូចនេះបានទេ ។ ក៏ប៉ុន្តែអព្ភូតហេតុអស្ចារ្យដែលធំជាច់អស់អព្ភូតហេតុនោះ គឺឥទ្ធិពលព្រះនាងﷺដែលជះទៅលើទឹកដីគុម្មនេះដែលឈានដល់ដំណាក់ការ ដែលគេបានឃើញស្រាប់ហើយសព្វថ្ងៃនេះ ដោយសារវត្តមានព្រះនាងﷺ ដោយសារការណែនាំ ដោយសារការជួយបណ្តុះចិត្តនិងព្រះពររបស់ព្រះនាងﷺ ។



**ទឹកដីស័ក្តិសិទ្ធ - ព្រះបូជនីយដ្ឋានព្រះនាង ហ្វាទីម៉ាស្ម៉ាក់ស៊្សូម៉ាស្ﷺ**

11 អាុលី រ៉ហ្វីអ៊ី (علی رفیعی), ស្ហាហ្វាប់ ស្ហារីអាត់ (شهاب شریعت ជីវប្រវត្តិរបស់អាយ៉ាទុលឡោះហ្វ៍ ម៉ារអាុស្ស៊ី ណាយ៉ាហ្វី) ទំព័រ ២៨៨ ។

# ៤. ព្រះបូជនីយរាជធានីគុម

## ៤.១ អារម្ភកថា

គុមជាអាណាខេត្តតូចមួយនៃប្រទេសអ៊ីរ៉ង់ ។ កាលពីដើមគុមនៅក្នុងចំណុះរដ្ឋអារ៉ាក់ (اراک) ក្រោយមកត្រូវភ្ជាប់មកនឹងតេះរ៉ន់ (ឬ តេហេរ៉ង់ تهران) ទាល់តែគេទទួលស្គាល់ថាជាខេត្តឯករាជមិននៅក្នុងចំណុះរដ្ឋដទៃ ។ ខេត្តគុមមានផ្ទៃដី ១២ ០០០ គីឡូម៉ែត្រក្រឡា ។ គុមមានគមនាគមន៍ជាប់នឹងខេត្តតេះរ៉ន់និងខេត្តសាវ៉េះហ្វ៍នៅប៉ែកខាងជើង ជាប់នឹងខេត្តដេលីយ៉ាន់ (دلیجان) និងខេត្តកាស្ហាន់ (کاشان) នៅប៉ែកខាងត្បូង ជាប់នឹងបឹងអំបិលនិងខេត្តតាហ្វ៉េរស្ហ (تفرش) នៅប៉ែកខាងកើត ។ ខេត្តនេះមានទីក្រុងមួយ មាន ៤ តំបន់ មាន ៩ តំបន់ជនបទ មាន ២៥៦ ភូមិ ។ ព្រោះតែខេត្តគុមនៅជាប់នឹងវាលខ្សាច់ បានជាមានអាកាសធាតុស្ងួតពាក់កណ្តាល ។

ឆ្នាំ ១៩៤៧ (ឆ្នាំសាកល) ប្រជារាស្ត្រខេត្តគុមមិនលើសពី ១៥០ ០០០ នាក់ទេ តែចាប់ពីសម័យបដិវត្តន៍អ៊ីស្លាមឆ្នាំ ១៩៧៩ ឆ្នាំសាកល ប្រជាពលរដ្ឋខេត្តគុមបានកើនឡើងដល់ ៤០០ ០០០ នាក់ ។ ក្រោយបដិវត្តន៍ ទីក្រុងបានរីកចម្រើនគួរឲ្យស្ញើច ប្រជារាស្ត្របានកើនឡើងជិត ១០០០ ០០០ នាក់ ។ ភាគច្រើនអ្នកស្រុកនេះជានិស្សិតដែលមកពីគ្រប់ប្រទេស ដើម្បីសិក្សាសាសនានៅឯមជ្ឈមណ្ឌលសិក្សាអ៊ីស្លាម ក្រោមព្រះបរិរក្សនិងព្រះសិរីវត្តមានរបស់ព្រះនាងហ្វាទីម៉ាស្ហ់ ម៉ាក់ស៊្ហូម៉ាស្ហ់ سلام الله علیها ។

គុមមិនត្រឹមតែជាមជ្ឈមណ្ឌលសិក្សាអ៊ីស្លាម ល្បីពេញពិភពលោកតែម្យ៉ាងទេ ថែមទាំងជា៖

-ទីក្រុងកសិកម្ម ផលិតស្រូវសាលី កប្បាស ផ្លែទទឹម ផ្លែល្វា ផ្លែ "ពីស្តាច់ឆូ" និងគ្រសក់ស្រូវផ្អែម ។

-ទីក្រុងឧស្សាហាកម្ម ផលិតព្រំបែបសិប្បកម្ម ផលិតកុម្ភភណ្ឌ (ផលិតចានឆ្នាំងដី) ផលិតវត្ថុធ្វើពីផ្លាស្ទិចនិងគ្រឿងសំណង់ ។
-ទីក្រុងពាណិជ្ជកម្ម ព្រោះតែនៅចំកណ្ដាលទីប្រជុំជនដែលតភ្ជាប់ប៉ែកខាងជើងជាមួយនឹងប៉ែកខាងត្បូងនៃប្រទេសអ៊ីរ៉ង់ និងបូជយេសក៍ច្រើនមហិមា ។

ផលវិបាកស្រាលគឺទីតាំងខេត្តគុម ។ ការផ្ដល់ទឹកសាបសម្រាប់ខេត្តគុមមកពីបណ្ដាស្ទឹងទឹកប្រៃដែលហូរមកពីបណ្ដាភ្នំនៅជុំវិញនោះ ។

# ៤.២ ប្រវត្តិខេត្តគុម

នាយុគមុនសម័យអ៊ីស្លាម ប្រជារាស្ត្រស្រុកគុមជាអ្នកកាន់សាសនា "ស្សូរ៉អាស់ត្រ៍" (Zoroastrianism) ។ ពួកមុស្លីមបានវាយយកបានក្រុងគុមក្រោមបញ្ជារបស់ អាប៊ូ មូសា អាស្ជ៉អារី (أَبُو مُوسَى ٱلْأَشْعَرِي) ក្នុងឆ្នាំ ២៣ សករាជហ្ហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ៦៤៣) ហើយក៏បានទៅជាមុស្លីមតាំងពីពេលនោះតរៀងមក ។[1]
ឆ្នាំ ៦៦ សករាជហ្ហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ៦៨៥) ក្រោយពី មុក្តារ បានបះបោរ (ដើម្បីសងសឹកឃាតកម្មអ៊ីម៉ាំហ្ហ៊ូសែន៍صلوات الله عليه والسلامនៅការបាឡាអ៊ុ៍) ស្ជីអាស់ ចេះដឹងបានី អាសាដ់ មួយក្រុមបានចាកចេញពីគូហ្វាស់ទៅកាន់ខេត្តគុម ហើយបានតាំងលំនៅនៅឯតំបន់ឃ្ជាំការ៉ន់ (جمكران) ។[2]
ឆ្នាំ ៨៣ សករាជហ្ហ៊ីជ្រ៉េះត៍ (ឆ្នាំសាកល ៧០២) ពួកអារ៉ាប់ប្រជាជាតិ អាស្ជ៉អារីច្រើននៃប្រទេសយេមេន បានភៀសខ្លួនហើយបានមករស់នៅឯតំបន់នេះបានទៅជាប្រជារាស្ត្ររបស់ទីក្រុងនេះ ។

---

[1] អាល់-បាឡាស្ជូរី (أحمد بن يحيى بن جابر البلاذري), ហ្វាត់ហ៊ុ អាល់-ប៊ូលដ្ទាន់ (فتوح البلدان) ទំព័រ ៣៨៤ ។ តារីក្ កាឌ្ទីម គុម (تاريخ قم) ទំព័រ ២៥-២៦ ។
[2] តារីក្ កាឌ្ទីម គុម (تاريخ قم) ទំព័រ ៣៨ ។

ចាប់តាំងពីដើមប្រវត្តិអ៊ីស្លាមរបស់ទីក្រុងនេះមក ទីក្រុងគុមបានក្លាយទៅជាមជ្ឈមណ្ឌលសិក្សាស្ហ៊ីអាស់ ។ ស្ហ៊ីអាស់ ៦០០០ នាក់បានរស់នៅឯទីក្រុងនេះចុងសតវត្សរ៍ទីមួយនៃសករាជអ៊ីស្លាម ។

ស្ហ៊ីអាស់ទីក្រុងនេះបានបះបោរប្រឆាំងពួកស្តេចត្រកូលអ៊ូម៉ៃយ៉ាស់ ។ បន្ទាប់ពីស្តេចខ៉លិហ្វត្រកូលអាប់បាស់បានដណ្តើបរាជ្យក្នុងឆ្នាំ ១៣២ សករាជហ៊ីច្រ៉េះត៍ (ឆ្នាំសាកល ៧៤៩) ពួកស្ហ៊ីអាស់ក៏នៅតែមិនចុះសម្រុងនឹងពួកស្តេចខ៉លិហ្វត្រកូលអាប់បាស់ដែរ ។

ឆ្នាំ ២០០ សករាជហ៊ីច្រ៉េះត៍ (ឆ្នាំសាកល ៨១៥) កាលអ៊ីម៉ាំ អាល់-រីដ្ហ៊ صلوات الله عليه والسلام បានចាកចេញពីម៉ាឌីណាស់ទៅកាន់តំបន់ឃូរ៉សាន ព្រះអង្គ صلوات الله عليه والسلام បានកាត់តាមខេត្តគុម ។ ផ្ទះដែលព្រះអង្គ صلوات الله عليه والسلام បានស្នាក់នៅបានក្លាយទៅជាមជ្ឈមណ្ឌលសិក្សាអ៊ីស្លាម (ម៉ាដ្រ៉សាស់ مَدْرَسَة) ក្រោយមក ។[3]

ឆ្នាំ ២០១ សករាជហ៊ីច្រ៉េះត៍ (ឆ្នាំសាកល ៨១៦) ព្រះនាង ហ្វាទីម៉ាស់ ម៉ាក់ស៊ូម៉ាស់ سلام الله عليها បានមកដល់ទីក្រុង ក្រោយពីមានជម្ងឺមួយរយៈពេលខ្លី បានសោយព្រះទិវង្គតហើយត្រូវបានបញ្ចុះព្រះរាជសពនៅក្នុងទីក្រុងនេះ ។ ព្រះបូជនីយផ្នូរព្រះនាង سلام الله عليها បានទៅជាបូជនីយដ្ឋាន សម្រាប់សម្តែងសេចក្តីគោរពរបស់ស្ហ៊ីអាស់ ។ បន្ទាប់មកទីក្រុងត្រូវហៅជាទូទៅថា "គុម អាល់-មូក្កូដ្ដាស់ قم المقدس គុមពិសិដ្ឋ" ។

រាប់សតវត្សរ៍តរៀងមក កិត្តិសព្ទទីក្រុងគុមឮសុសសាយនិងមានឥទ្ធិពល ព្រោះទីក្រុងនេះជាមជ្ឈមណ្ឌលសិក្សាស្ហ៊ីអាស់ធំបំផុត ។ សិក្ខាសាលាអ៊ីស្លាម (الحوزة العلمية) នៅទីក្រុងគុមទៅជាពេញនិយមណាស់ក្រោយពីបដិវត្តន៍អ៊ីស្លាមនៃប្រទេសអ៊ីរ៉ង់ និងដោយសារសិក្ខាសាលាអ៊ីស្លាមនៃទីក្រុងណាយ៉ាហ្វាបានអន់ថយដោយសារការសង្កត់សង្កិនពីរបបប្រឆាំងនៅប្រទេសអ៊ីរ៉ាក់ ។

[3] សៃយីដ្ អ៊ីបនូ ត៊ាវុស (سيد بن طاووس), ហ្វារហ្វាស់ អាល់-ក៊ឺរី (فرحة الغري) ទំព័រ ១០៥ ។

# ៤.៣ សិក្ខាសាលាទីក្រុងគុម

ទីក្រុងគុមល្បីខាងសិក្ខាសាលានិងវិទ្យាស្ថានអ៊ីស្លាមច្រើន ដែលផ្តល់នូវការសិក្សាលំដាប់ខ្ពស់ ។ ទាំងអស់នេះសរុបជាហ្ហៅស្ហាស្ទ់ (ហ្ហៅស្ហាស្ទ់ អាល់-អ៊ីលមីយ៉ាស្ទ់ - សិក្ខាសាលាអ៊ីស្លាម (الحوزة العلمية) - ប្រភេទខ្លី) ដែលប្រជុំមជ្ឈមណ្ឌលនិងអង្គការអប់រំនិងស្រាវជ្រាវជាង ២០០ ដោយមានលោកអ្នកប្រាជ្ញនិងនិស្សិតមកពីជាង ៨0 ប្រទេស ជាង ៤0 000 នាក់ ។

ចាប់តាំងពីស្ហ៊ីអាស្ទ់ដំបូងបានមកដល់ក្នុងសតវត្សរ៍អ៊ីស្លាមទីមួយ សាលានិងម៉ាដ្ទ័រសាស្ទ់ (មជ្ឈមណ្ឌលអប់រំ) ត្រូវបានរៀបចំឡើង ដើម្បីសិក្សានិងបណ្តុះបណ្តាលផ្សព្វផ្សាយសិក្ខាបទព្រះធម៌របស់ព្រះសាស្តាصلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គصلى الله عليه وآله وسلمعليهم السلام ។
អ្នកដែលបានរៀបចំម៉ាដ្ទ័រសាស្ទ់ដំបូងបង្អស់គឺត្រកូល អាស្ហ៍អារី ដែលបានតាំងលំនៅនៅឯទីក្រុងគុមនាចុងសតវត្សរ៍ទីមួយនៃសករាជហ៊្ហិច្រ៉េះត៍ ហើយបានបង្កើតហ្ហៅស្ហាស្ទ់នៅទីនេះ ។ ពេលអ៊ីម៉ាំ អាល់-ស្វ៍ឌិក្ហុصلوات الله عليه والسلام បានឮឈ្មោះមជ្ឈមណ្ឌលនេះ ព្រះអង្គصلوات الله عليه والسلامបានប្រាប់ដំណឹងអនាគតរុងរឿងរបស់ទីក្រុងគុម ។[4]
ហ្ហៅស្ហាស្ទ់បានក្លាយទៅជាមជ្ឈមណ្ឌលសំខាន់ ដោយសារបុណ្យបារមីអ៊ីម៉ាំ អាល់-រីឌ្ហ៍صلوات الله عليه والسلامនាដើមសតវត្សរ៍ទីបីនៃសករាជហ៊្ហិច្រ៉េះត៍ កាលព្រះអង្គصلوات الله عليه والسلامបានមកកាន់ទីនេះ (ស្នាក់នៅមុនទៅកាន់តំបន់ឃ្ហូរ៉សាន) ។ ក្រោយមក ផ្ទះដែលអ៊ីម៉ាំصلوات الله عليه والسلامបានស្នាក់នៅត្រូវផ្លាស់ទៅជាម៉ាដ្ទ័រសាស្ទ់ ឈ្មោះថា "អាល់-រ៉ឌ្ហ៍វីយ៉ាស្ទ់" ។[5]
ក៏ប៉ុន្តែក្រោយពីបានបញ្ចុះព្រះរាជសពព្រះនាង ហ្វាទ្ធិម៉ាស្ទ់ ម៉ាក់ស្ហូម៉ាស្ទ់سلام الله عليها នៅឯគុម ទើបអស់លោកអ្នកប្រាជ្ញស្ហ៊ីអាស្ទ់ចាប់ផ្តើមទៅប្រជុំគ្នាជុំវិញព្រះចេតិយព្រះនាងسلام الله عليها គុមក៏មានឈ្មោះល្បីល្បាញជាមជ្ឈមណ្ឌលអប់រំសាសនាជាន់

[4] មើលវគ្គទី ៤.៥ ខាងក្រោមស្តីអំពីបារមីទីក្រុងគុម ។

[5] ហ្វារហ្ហាស្ទ់ អាល់-ក៏រី (فرحة الغري) ទំព័រ ១០៥ ។

ខ្ពស់តាំងពីពេលនោះមក ។

ក្នុងអំឡុងពេលនេះមានលោកអ្នកប្រាជ្ញល្បីៗច្រើននាក់ ដូចជាលោក អាស់ម៉ាដ់ អ៊ីបនូ អ៊ីសហាក់ អាស់អារី គុម្មី (أحمد بن إسحاق الأشعري القمي - ទទួលអនិច្ចកម្មចន្លោះឆ្នាំ ២៦០ ស.ហ្វ./ឆ្នាំសាកល ៨៧៣) និងឆ្នាំ ២៦០ ស.ហ្វ./ឆ្នាំសាកល ៨៧៦) ជាដើម ដែលជាតំណាងរបស់អ៊ីមុាំ អាល់-អាស់ការី صلوات الله عليه والسلام នៅទីក្រុងគុម ។ លោក អាស់ម៉ាដ់ អ៊ីបនូ អ៊ីសហាក់ អាស់អារី គុម្មី មានសំណាងបានទទួលនូវព្រះឯកសិទ្ធិបានឃើញព្រះរាជកុមារ អ៊ីមុាំ អាល់-ម៉ាស្ទ់ឌី عجل الله فرجك ។

លោក អាស់ម៉ាដ់ អ៊ីបនូ អ៊ីសហាក់ អាស់អារី គុម្មី បានទទួលព្រះរាជបញ្ជាពីអ៊ីមុាំ អាល់-អាស់ការី صلوات الله عليه والسلام ឲ្យសាងម៉ាស់យ៉ិដមួយដែលចាស់ជាងគេសព្វថ្ងៃនេះនៅទីក្រុងគុម ឈ្មោះ អាល់-ម៉ាស់យ៉ិដ អ៊ីមុាំ ។[6]

លោកអ្នកប្រាជ្ញត្រកូលគុម្មីដែលល្បីជាងគេ ក្នុងសតវត្សរ៍ទីបួននៃសករាជហ្ស៊ីច្រ៉េះត៍អាចជាលោក ស្ហៃខ៍ អាប៊ូ យ៉ាក់ហ្វារ មូហាំម៉ាដ់ អ៊ីបនូ អាលីបាបាវ៉ៃហ៍ គុម្មី (أَبُو جَعْفَر مُحَمَّد ٱبْن عَلِيّ بَابَوَيْه ٱلْقُمِيّ) ដែលហៅជាសាមញ្ញថា ស្ហៃខ៍ ស្វ៊ឌូក (អនិច្ចកម្មឆ្នាំ ៣៨១ ស.ហ្វ./ឆ្នាំសាកល ៩៩១) ។ គេបានរាយការណ៍ថាលោកបានចាប់កំណើតមកដោយសារអ៊ីមុាំ អាល់-ម៉ាស្ទ់ឌី عجل الله فرجك បានបួងសួងសូមអល់ឡោះហ្វ៍ عز وجل ។

ហ្ស៊ីអាស់កាន់តែមានឥទ្ធិពលឡើង ។ លោកអ្នកនិពន្ធនៃសតវត្សរ៍ទី ៦ ឈ្មោះ ស្ហៃខ៍ អាប់ដ្វាល់-យ៉ាលិល រ៉ាស៊ី (عبد الجليل الرازی) បានរាយការណ៍ថាមានម៉ាដ់រ៉សាស់ដំណើរការជាង ១០ នៅទីក្រុងគុមសម័យលោក ។

ស្តេចត្រកូល ស្វ៊ហ្វាវី ដែលបានសោយរាជ្យប្រទេសអ៊ីរ៉ង់ពីឆ្នាំ ៩០៥ សករាជហ្ស៊ីច្រ៉េះត៍ (ឆ្នាំសាកល ១៥០០) ដល់ឆ្នាំ ១១៣៥ សករាជហ្ស៊ីច្រ៉េះត៍ (ឆ្នាំសាកល ១៧២៣) ជាអ្នកឧបត្ថម្ភហ្ស៊ីអាស់ ជួយផ្តល់ថវិកានិងគាំទ្រការ

[6] អាក់យ៉ាន់ អាល់-ស្ហ៊ីអាស់ (أعيان الشيعة) ក្បាលទី ២ ទំព័រ ៤៧៨ ។

